សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ មិថុនា ឆ្នាំ ២០២០

# លីអាហូណា



## ព្រឹត្តិការណ៍ដែលប្រាប់ឲ្យដឹងនៃឆ្នាំ ១៨២៩

ទំព័រ ១២

តើកូនរបស់ខ្ញុំដែលពិការត្រៀមខ្លួនរួចរាល់ដើម្បីទទួលបុណ្យជ្រមុជទឹកហើយឬនៅ ?
ទំព័រ ១៨

ការប្រតិកម្មចំណីអាហារ ៖ ការធ្វើឲ្យព្រះវិហារជាកន្លែងដែលកាន់តែមានសុវត្ថិភាព
ទំព័រ ២២

ត្រូវបានកំណត់ដោយសមត្ថភាព មិនមែនដោយពិការភាពទេ
ទំព័រ ២៨

សាសនាចក្រ
នៅទីនេះ

# ទីប្រជុំជនអូកលែន
# រដ្ឋផែនសីលវេញ៉ា



# ស.រ.អា.

ផ្ទះនៅឯទីតាំងនៃការស្ដារបព្វជិតភាពឡើងវិញនេះ គឺជាការសាងសង់ឡើងវិញនូវផ្ទះរបស់យ៉ូសែប និងអិមម៉ា នៅក្នុងភូមិហាម៉ូនី ដែលឥឡូវនេះស្គាល់ថាជា ទីប្រជុំជនអូកលែន ។

**១០** — វួដ និងសាខាទាំងឡាយ រួមទាំងសាខាសុសគ្វីហាណា នៅក្នុងស្តេកស្រ្តេនបុន ផែនស៊ីលវេញ៉ា ។

**២៦០** — គីឡូម៉ែត្រ ពីទីតាំងនៃការស្ដារបព្វជិតភាពឡើងវិញ ទៅព្រះវិហារបរិសុទ្ធ ប៉ាលម៉ៃរ៉ា នូវ យ៉ោក ។

**១៥** — វិវរណៈត្រូវបានទទួលនៅក្នុងភូមិហាម៉ូនី រដ្ឋផែនស៊ីលវេញ៉ា ដែលមានបញ្ចូលទៅក្នុងព្រះគម្ពីរ គោលលទ្ធិ និងសេចក្ដីសញ្ញា ។

**ប្រហែល ៧០** — ភាគរយនៃព្រះគម្ពីរមរមនត្រូវបានបកប្រែនៅក្នុងផ្ទះរបស់យ៉ូសែប និងអិមម៉ា ។

**ឆ្នាំ ១៨០៤** អិមម៉ា ហេល ( ក្រោយមករៀបការជាមួយយ៉ូសែប ស្ម៊ីធ ) បានកើតនៅក្នុងភូមិហាម៉ូនី ។

**ឆ្នាំ ១៨២៩** យ៉ូហាន បាទីស្ទ ប្រគល់បព្វជិតភាពអើរ៉ុនមកឲ្យយ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ។ ក្រោយមកពេត្រុស យ៉ាកុប និង យ៉ូហាន ប្រគល់បព្វជិតភាពមិលគីស្សាដែកដល់ពួកលោក ។

**ឆ្នាំ ១៩៦០** បូជនីយដ្ឋានទុកជាការគោរពដល់ការស្ដារឡើងវិញនៃបព្វជិតភាព ត្រូវបានសាងសង់នៅទីតាំងនេះ ។

**ឆ្នាំ ២០១៥** ប្រធាន រ័សុល អិម ណិលសុន ឧទ្ទិសឆ្លងទីតាំងនៃការស្ដារបព្វជិតភាពឡើងវិញ ។



រូបថតដោយ ឡេស្លី និលសុន



សូមរៀនបន្ថែមទៀតអំពីប្រវត្តិសាសនាចក្រនៅគេហទំព័រ **history.ChurchofJesusChrist.org** ។












ការងារបម្រើតាមរយៈ
ការប្រជុំសាក្រាម៉ង់
៨

តួនាទីដ៏សំខាន់របស់បព្វជិតភាពក្នុង
ការស្ដារឡើងវិញ
*អែលឌើរ ហ្គែរី អ៊ី ស្ទីវ៉ែនសុន*
១២

ការគ្រប់គ្រងការប្រតិកម្មចំណីអាហារនៅព្រះវិហារ
*លីហ្សា អែន ថមសុន*
២២

មនុស្សដែលមានតម្រូវការពិសេស មេរៀនពិសេស
*អែលឌើរ ប៉ូល បី ផៃបកើរ*
*និង ម៉ែលីស្សា ជី ផៃបកើរ*
២៨


# ការសម្រេចចិត្តលើបុណ្យជ្រមុជទឹក

ថ្មីៗនេះ ស្វាមីខ្ញុំ និងខ្ញុំព្យាយាមធ្វើការសម្រេចចិត្ត ថាបើកូនប្រុសអាយុប្រាំពីរឆ្នាំរបស់យើងបានត្រៀមខ្លួនដើម្បីទទួលបុណ្យជ្រមុជទឹកហើយឬនៅ ។ គាត់មានជំងឺអធីហ្សឹម ដូច្នេះយើងមិនប្រាកដថាបើគាត់យល់គ្រប់គ្រាន់ដើម្បីទទួលខុសត្រូវលើការសម្រេចចិត្តនេះឬទេ ។ នៅទំព័រ ១៨ អ្នកអាចអានអំពីរឿងជាច្រើនដែលយើងបានពិចារណា ពេលដែលយើងបានព្យាយាមដើម្បីធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវ ។

ក្នុងនាមជាអ្នកជំនាញខាងផ្នែកពិការភាពប្រចាំសាសនាចក្រ ខ្ញុំដឹងថា មានមនុស្សពិការដ៏ល្អៗជាច្រើនដែលមានបំណងប្រាថ្នាចង់មានអារម្មណ៍ថាត្រូវគេរាប់បញ្ចូលក្នុងចំណោមសមាជិកនៅឯព្រះវិហារ ។ ចំពោះបងប្អូនប្រុសស្រីគ្រប់រូបរបស់យើង ដែលមានពិការភាព ទោះជាពិការភាពអ្វីក៏ដោយ និងចំពោះគ្រួសាររបស់ពួកគាត់ យើងសូមនិយាយថា ៖ យើងស្រឡាញ់បងប្អូន យើងត្រូវការបងប្អូន ហើយយើងចង់រៀនពីរបៀបដើម្បីបម្រើបងប្អូនឲ្យបានកាន់តែប្រសើរឡើង ។

អត្ថបទមួយចំនួននៅក្នុងច្បាប់នេះ ជួយយើងឲ្យយល់ពីពិការភាព និងរបៀបដែលយើងអាចបង្កើនការរាប់បញ្ចូលឲ្យកាន់តែប្រសើរឡើងនៅក្នុងវួដ និងសហគមន៍របស់យើង ៖

- ទំព័រ ២៨ ៖ អែលឌើរ ប៉ូល បី ផៃបកើរ នៃពួកចិតសិបនាក់ និងភរិយាលោក ម៉ែលីស្សា ដែលមានកូនម្នាក់មានពិការភាព ផ្ដល់នូវក្ដីសង្ឃឹម និងការលើកទឹកចិត្តដល់យើងដែលជាឪពុកម្ដាយទាំងឡាយ ។
- ទំព័រ ២១ ៖ នៅចុងបញ្ចប់នៃអត្ថបទរបស់ខ្ញុំ បងប្អូនអាចស្វែងរកគំនិតនានាពីរបៀបដើម្បីសម្របសម្រួលមេរៀននៅព្រះវិហារ និងការហៅបម្រើឲ្យកាន់តែប្រសើរសម្រាប់សមាជិកដែលមានពិការភាព ។
- ទំព័រ ខ១៦ ៖ ឪពុកម្ដាយអាចប្រើប្រាស់រឿងនេះនៅក្នុង *ប្រិយមិត្ត* ដើម្បីជួយកូនៗរបស់ពួកគេឃើញពីគំរូមួយនៃការធ្វើជាមិត្តដល់នរណាម្នាក់ដែលមានពិការភាព ។

កាលដែលអ្នកអានច្បាប់នេះ សូមចាំថា « តម្លៃនៃព្រលឹងទាំងឡាយគឺមហិមាណាស់ចំពោះព្រះនេត្រនៃព្រះ » ( គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១០ ) ។ យើងអាចជួយបង្កើតឲ្យមានបរិយាកាសក្នុងគេហដ្ឋាន និងសាសនាចក្រដែលពោរពេញដោយក្ដីស្រឡាញ់ និងការស្វាគមន៍ ដើម្បីឲ្យមនុស្សទាំងអស់ណាដែលចង់មក ហើយប្រែក្លាយដូចជាព្រះយេស៊ូវ មានឱកាសបែបនោះ ។

ដោយក្ដីស្រឡាញ់
ខាធី អែឌណា ស្ទីដ
នាយកដ្ឋានបព្វជិតភាព និងគ្រួសារ អ្នកជំនាញផ្នែកពិការភាព

# មាតិកា


៥ **ការស្ដារឡើងវិញនៃបព្វជិតភាពអើរ៉ុន**

៦ **ការបង្ហាញអំពីសេចក្ដីជំនឿ**
**លីនី យូអ៊ីឡាអៅ**
លីនីធ្លាប់មានការលំបាកជាមួយនឹងអារម្មណ៍ខឹង ។ ប៉ុន្តែដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទបានជួយគាត់ឲ្យផ្លាស់ប្ដូរកំហឹងរបស់គាត់ទៅជាភាពសុខសាន្តវិញ ។

៨ **គោលការណ៍នៃការងារបម្រើការងារបម្រើតាមរយៈការប្រជុំសាក្រាម៉ង់**
ការប្រជុំសាក្រាម៉ង់ផ្ដល់ដល់យើងនូវឱកាសដើម្បីភ្ជាប់ទំនាក់ទំនង និងផ្ដល់ការងារបម្រើដល់អ្នកដទៃទៀត ។

១២ **តួនាទីដ៏សំខាន់របស់បព្វជិតភាពក្នុងការស្ដារឡើងវិញ**
*ដោយ អែលឌើរ ហ្គែរី អ៊ី ស្ទីវ៉ែនសុន*
សូមអរគុណចំពោះការត្រឡប់មកវិញនៃបព្វជិតភាពមកដល់ផែនដី ទើបការស្ដារឡើងវិញអាចមានលទ្ធភាពដំណើរការបាន ។

១៨ **តើកូនរបស់ខ្ញុំដែលពិការបានត្រៀមខ្លួនដើម្បីទទួលបុណ្យជ្រមុជទឹកហើយឬនៅ ?**
*ដោយ យេធី អែឌណា ស្មីដ*
កូនប្រុសរបស់យើងជិតឈានចូលអាយុប្រាំបីឆ្នាំហើយ ។ ប៉ុន្តែតើយើងអាចមានចិត្តប្រាកដថា គាត់បានត្រៀមខ្លួនដើម្បីទទួលបុណ្យជ្រមុជទឹកហើយឬនៅ ។

២២ **ការគ្រប់គ្រងការប្រតិកម្មចំណីអាហារនៅព្រះវិហារ**
*ដោយ លីហ្សា អែន ថមសុន*
ជួនកាលយើងប្រើប្រាស់អាហារដើម្បីបង្ហាញសេចក្ដីស្រឡាញ់របស់យើង ។ ប៉ុន្តែនៅក្នុងករណីមានប្រតិកម្មម្ហូបអាហារធ្ងន់ធ្ងរ *កង្វះ*ម្ហូបអាហារក៏អាចជាការបង្ហាញនូវសេចក្ដីស្រឡាញ់ផងដែរ ។

២៨ **មនុស្សដែលមានតម្រូវការពិសេស មេរៀនពិសេស**
*ដោយ អែលឌើរ ប៉ូល ប៊ី ផៃបភើរ និង ម៉ែលីស្សា ជី ផៃបភើរ*
កូនស្រីរបស់យើងមានតម្រូវការពិសេស ។ យើងបានរៀនពីនាងច្រើនជាងដែលយើងអាចស្រមៃឃើញ ។

៣២ **សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**
គ្រូបង្រៀនម្នាក់ឮសំឡេងរបស់ព្យាការីនៅក្នុងកន្លែងដ៏មិនរំពឹងទុកមួយ ។ បុរសម្នាក់ជ្រើសរើសរវាងការងាររបស់គាត់ និងដំណឹងល្អ ។ គូស្វាមីភរិយាមួយគូអធិស្ឋានសម្រាប់សុវត្ថិភាពរបស់កូនដែលមិនទាន់កើតរបស់ពួកគេ ។ ដួងចិត្តរបស់បុរសម្នាក់ត្រូវបានបើកដោយសារការទៅទស្សនកិច្ចព្រះវិហារបរិសុទ្ធ ។

៣៦ **គេហដ្ឋានរបស់យើង ក្រុមគ្រួសាររបស់យើង**
**អំណោយនៃសេចក្ដីស្រឡាញ់**
*ដោយ ហ្វេស អេស វ៉ាត់សុន*
ខ្ញុំបានឃើញសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ជាអំណោយមួយដល់យើង នៅក្នុងការផ្ដល់ពរជ័យបព្វជិតភាពដ៏ទន់ភ្លន់របស់ស្វាមីខ្ញុំទៅកាន់កូនស្រីតូចរបស់យើង ។

៣៨ **ចូរមកតាមខ្ញុំ ៖ព្រះគម្ពីរមរមន**
អត្ថបទប្រចាំសប្ដាហ៍ទាំងនេះអាចគាំទ្រការសិក្សាព្រះគម្ពីរមរមនរបស់បងប្អូននៅខែនេះ ។


ការអានខ្លីៗ

ការគាំទ្រ *ចូរមកតាមខ្ញុំ*



**នៅលើក្របមុខ**
*នៅលើអ្នក ជាពួកអ្នកបម្រើដូចរូបខ្ញុំអើយ* ដោយ លីនដា ឃើរលី គ្រីស្ទានសិន និង ម៉ៃឃើល ម៉លម៍

# វគ្គ


យុវមជ្ឈិមវ័យ
៤២
**ការចាត់ចែងជីវិតការណាត់ជួបជាគូរបស់**អ្នកអាចជារឿងគួរឲ្យភ័យខ្លាច—ប៉ុន្តែវាមិនចាំបាច់ដូច្នោះនោះទេ ។ សូមអានរឿងរ៉ាវទាំងនេះមកពីយុវមជ្ឈិមវ័យដែលបាន**ដកភាពតានតឹងចេញពីការស្វែងរកដៃគូអស់កល្ប**
បានដោយជោគជ័យ ។





យុវវ័យ
៥០
រៀនបន្ថែមទៀតអំពីប្រវត្តិនៃអង្គការយុវនារី









កូនចៅ
*ប្រិយមិត្ត*
**រៀនអំពីអ័ប៊ីស និងជួបមិត្តភក្តិ**មកពីប្រទេសអាល្លឺម៉ង់ ។






## អត្ថបទមានតែឌីជីថលប៉ុណ្ណោះសម្រាប់ខែមិថុនា



**គាត់ត្រូវការការប្រសិទ្ធពរបព្វជិតភាពមួយ ។ តើខ្ញុំអាចធ្វើវាបានទេ ?**

*ដោយ អូឌេល ចនសុន*

យុវមជ្ឈិមវ័យម្នាក់ចែកចាយរបៀបដែលគាត់បានយកឈ្នះលើការភ័យខ្លាចរបស់គាត់ក្នុងការផ្ដល់ការប្រសិទ្ធពរបព្វជិតភាព ។



**អ្វីដែលពិការភាពរបស់កូនស្រីខ្ញុំបានបង្រៀនខ្ញុំអំពីព្រះគុណ**

*ដោយ ម៉ាក់ក្វាន*

ឪពុកម្នាក់ផ្ដល់នូវការយល់ដឹងអំពីរបៀបដែលព្រះគុណរបស់ព្រះយេស៊ូវគ្រីស្ទផ្ដល់ក្ដីសង្ឃឹមដល់គាត់នៅក្នុងកាលៈទេសៈរបស់គាត់ ។



**ការទុកចិត្តលើចំណាប់អារម្មណ៍ទីពីរ និងលើការដឹកនាំពីព្រះវិញ្ញាណ**

*ដោយ ម៉ារី ណិតស្ល័រ*

យុវមជ្ឈិមវ័យមកពីប្រទេសអូស្ត្រាលីម្នាក់ចែកចាយពីរបៀបដែលការផ្ដល់ឱកាសលើកទីពីរដល់នរណាម្នាក់បានធ្វើឲ្យមានការផ្លាស់ប្ដូរនៅក្នុងជីវិតនាង ។



**ការនៅលីវរំឭកខ្ញុំឲ្យទុកចិត្តទៅលើផែនការរបស់ព្រះទាំងស្រុងសម្រាប់ខ្ញុំ**

*ដោយ គ្រីស្ទីណា ខុតតេរ៉ែល*

យុវមជ្ឈិមវ័យម្នាក់ចែកចាយពីរបៀបដែលនាងបានរកឃើញក្ដីសង្ឃឹមថ្មីសម្រាប់ជីវិតនាង ពេលដែលអ្វីៗពុំបានកើតឡើងដូចជានាងបានគ្រោងទុក ។

## ស្វែងរកបន្ថែមទៀត

នៅក្នុងកម្មវិធី បណ្ណាល័យដំណឹងល្អ និងនៅគេហទំព័រ liahona.ChurchofJesusChrist.org អ្នកអាច ៖

- ស្វែងរកច្បាប់ចេញផ្សាយបច្ចុប្បន្ន ។
- រកឃើញមាតិកាមានតែឌីជីថលប៉ុណ្ណោះ ។
- ស្វែងរកលេខចេញផ្សាយមុនៗ ។
- ដាក់បញ្ជូនរឿង និងមតិកែលម្អរបស់អ្នក ។
- ជាវ ឬជាវដើម្បីផ្ដល់ជាអំណោយ ។
- ពង្រីកការសិក្សាជាមួយឧបករណ៍ឌីជីថល ។
- ចែកចាយអត្ថបទ និងវីដេអូដែលចូលចិត្ត ។
- ទាញយក ឬបោះពុម្ពអត្ថបទ ។
- ស្ដាប់អត្ថបទដែលអ្នកចូលចិត្ត ។

## ទំនាក់ទំនងមកកាន់យើងខ្ញុំ

សូមផ្ញើសំណួរ និងមតិកែលម្អរបស់អ្នកទៅកាន់ liahona@ChurchofJesusChrist.org ។

សូមដាក់បញ្ជូនរឿងរបស់អ្នកនៅគេហទំព័ liahona.ChurchofJesusChrist.org ឬផ្ញើសំបុត្រទៅកាន់ ៖
*Liahona*, flr. 23
50 E. North Temple Street
Salt Lake City, UT 84150-0023, USA

**ខែ មិថុនា ឆ្នាំ ២០២០ វ៉ុល ១៩ លេខ ៤**
**លីអាហូណា ១៦៧២១ ២៥៨**

ទស្សនាវដ្ដីជាអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** រ័សុល អិម ណិលសុន, ដាល្លិន អេក អូក, ហិនរី ប៊ី អាវរិង

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** អិម រ័សុល បាឡឺដ, ជែហ្វ្រី អ័រ ហូឡិន, ឌៀថើរ អេហ្វ អុជដូហ្វ, ដេវីឌ អេ បែដណា, ឃ្វីនថិន អិល យុក, ឌី ថត គ្រីស្តូហ្វឺសិន, នែល អិល អាន់ឌើរសិន, រ៉ូណាល អេ រ៉ាសបាន, ហ្គែរី អ៊ី ស្ទីវែនសុន, ឌេល ជី រេនឡាន់, ជើរិត ដបុលយូ ហ្គង, អូលីសេស សូរ៉េស

**អ្នកនិពន្ធ ៖** រ៉ាន់ឌី ឌី ហ្វាំង

**អ្នកប្រឹក្សា ៖** ប៉ែកឃី ក្រាវិន, ស្ការ៉ុន អ៊ូបែង, គ្រីស្ទីណា ប៊ី ហ្វ្រានកូ, វ៉លធើរ ហ្វេស. ហ្គន់ហ្សាលេស, ឡារី អេស ខាឈើរ, ចេន អ៊ី ញូវមែន ,អែឌ្រាន អូឆៅ, ម៉ៃឃើល ជី រីងវូដ, ជើន ភី ស្ដេនហ្វីល

**នាយកគ្រប់គ្រង ៖** រីឆាដ អាយ ហ៊ីតុន

**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ ឡយបិហ្គ

**អ្នកចាត់ការពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណាន់

**និពន្ធនាយកគ្រប់គ្រង ៖** អ័ដាម ស៊ី អូសុន

**ជំនួយការនិពន្ធនាយកគ្រប់គ្រង ៖** រ៉ាយអិន ខារ

**ជំនួយការបោះពុម្ពផ្សាយ ៖** កាមីឡា ខាស្ទ្រីលលុន

**និពន្ធ និង បោះពុម្ព ៖** ម៉ារីស្សា ខែននីស, ដេវីឌ ឌិកសុន, ដេវីដ អេ អ៊ែតវើត, ម៉ាធ្យូ ឌី ហ្វ៊ីតុន, ហ្គារ៉េត អេច ហ្គាហ្វ, អ៊ើរ៉ុន ចន ស្ដុន, ចន រ៉ាយអ៊ិន ជិនសិន, ឆាលឡុត ឡាកាបាល់, ម៉ៃយល អរ ម៉ូរីស, អ៊ីរិក ប៊ី ម៉ដុក, យ៉ូស្វេ ដេ ភីគី, ចាន ភីនបូរ៉ាហ្វ, រីឆាត អិម រ៉មនី, មីនឌី សេលូ, ឡូរី ហ្វូលើរ សូសា, ឆាកខែល វូដឡេ, ម៉ារីសា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ ស្កត នូដស៊ិន

**នាយកផ្នែកសិល្បៈ ៖** ថែដ អ័រ ភីធើរសុន

**របនាប្លង់ ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី អាន់ត្រួស, មែនឌី បិនធ្លី, ស៊ី ឃីមប៊ឹល បុត, ថូម៉ាស ឆាល, ចូស្វ័រ ដេននីស ដេវីឌ ហ្គ្រីន, ខូលីន ហ៊ីងគ្លី, អេរិក ភី ចនសិន, ស៊ូសាន ឡូហ្វ្រីន, ស្កត អិម ម៉ូយ, អេលេនី រេហ្គើរ, ម៉ាក ដ័បុលយូ រ៉ូប៊ីសុន, យេ នីកូល វ៉ែកឃិនហូស

**អ្នកសម្របសម្រួលកម្មសិទ្ធិបញ្ញា ៖** ខូលែត នៃបេឃើ អាននី

**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍

**ផលិតកម្ម ៖** អ៊ីវ៉ា ហ្វែន អាឌៀ, ជូលី ប៊ីដេត, ថូម៉ាស ជី ខ្រូនីន, ប្រាយអែន ដ័បុលយូ ហ្គីជី, ជីននី ដេ នីលសុន, ម៉ារីសា អិម ស្មីធ

**មុនការបោះពុម្ព ៖** យ៉ូស្វេ ដែននីស, អាំមុន ហារីស

**នាយកផ្នែកបោះពុម្ព ៖** ស្ទេវិន ធី លេវីស

**នាយកចែកចាយ ៖** ត្រយ អ័រ ប៉ាឃើរ

សូមផ្ញើអត្ថបទ និង សំណួរនានា តាមអ៊ិនធើរណែតនៅគេហទំព័រ liahona.ChurchofJesusChrist.org តាមអ៊ីម៉ែលទៅកាន់ liahona@ChurchofJesusChrist.org ឬ តាមសំបុត្រទៅកាន់ *Liahona*, flr.23, 50 E. North Temple St., Salt Lake City, UT 84150–0023, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមៀ, ប៊ុលហ្គារី, ខ្មែរ, ស៊ីប៊ូអាណូ, ចិន, ចិន ( សម្រាយ ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូនី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងគ្រី, អ៊ីស្លង់, ឥណ្ឌូណេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាត់វៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី, នរវ៉េ, ប៉ូឡូញ, ព័រទុយហ្គាយ, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញផ្សាយញឹកញាប់មានផ្សេងៗគ្នាទៅតាមភាសា ) ។

© 2020 by Intellectual Reserve, Inc. All rights reserved. បោះពុម្ពនៅសហរដ្ឋអាមេរិក ។

**For Readers in the United States and Canada:** June 2020 Vol. 19 No. 4. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.50 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.ChurchofJesusChrist.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 507.1.5.2). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.



# ការស្ដារឡើងវិញនៃបព្វជិតភាពអើរ៉ុន

នៅថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៨២៩ យ៉ូហាន បាទីស្ទ បានផ្ដល់បព្វជិតភាពអើរ៉ុនដល់ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ។ ការដកស្រង់ទាំងនេះអំពីការចងចាំរបស់ពួកលោកអំពីថ្ងៃដ៏សំខាន់នោះ បង្ហាញថា ព្រឹត្តិការណ៍នេះអស្ចារ្យខ្លាំងណាស់ ។

« ទូតដែលមកឯយើងពេលនោះ ហើយដែលបានប្រគល់បព្វជិតភាពដល់យើង បានប្រាប់ថា **ឈ្មោះលោកគឺ យ៉ូហាន ជាបុគ្គលដដែល ដែលហៅថា យ៉ូហានបាទីស្ទ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី** ហើយថាលោកបានធ្វើការនៅក្រោមការដឹកនាំពីពេត្រុស យ៉ាកុប និងយ៉ូហាន ដែលកាន់កូនសោទាំងឡាយនៃបព្វជិតភាពម៉ិលគីស្សាដែក » ។

យ៉ូសែប ស្ម៊ីធ នៅក្នុង យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៧២ ការសង្កត់ន័យត្រូវបានបន្ថែម





*អូលីវើរ ខៅឌើរី ក៏បាននៅជាមួយ យ៉ូសែប ស្ម៊ីធ ផងដែរនៅក្នុងឆ្នាំ ១៨៣៦ ពេលដែលកូនសោបព្វជិតភាពត្រូវបានស្ដារឡើងវិញនៅក្នុងព្រះវិហារបរិសុទ្ធ ឃើតឡង់ ។*

« ហាក់ដូចជាពីកណ្ដាលភាពអស់កល្បជានិច្ច **នោះស្រាប់តែសំឡេងនៃព្រះដ៏ប្រោសលោះ ទ្រង់មានព្រះបន្ទូលប្រាប់ពីសេចក្ដីសុខសាន្តដល់យើង កាលវាំងននបើកចេញទៅ ហើយមានទេវតាពីព្រះបានចុះមកពាក់ដោយសិរីល្អ** ហើយបានប្រាប់នូវសារដែលបានទន្ទឹងចាំ និងកូនសោទាំងឡាយនៃដំណឹងល្អខាងការប្រែចិត្ត ។ **សេចក្ដីអំណរអ្វីហ្ន៎ ! សេចក្ដីអស្ចារ្យអ្វីហ្ន៎ ! សេចក្ដីចម្លែកអ្វីហ្ន៎ !** »

អូលីវើរ ខៅឌើរី នៅក្នុង យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៧១ ការសង្កត់ន័យត្រូវបានបន្ថែម



*ការបរិយាយវីដេអូព្រះគម្ពីរប៊ីប អំពីយ៉ូហាន បាទីស្ទ ជ្រមុជទឹកឲ្យព្រះយេស៊ូវគ្រីស្ទ ។*



*ទន្លេសុសគ្វីហាណានៅភូមិហាម៉ូនី រដ្ឋផែនស៊ីលវេញ៉ា នៅក្បែរកន្លែងដែល យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី បានទទួលបុណ្យជ្រមុជទឹកនៅថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៨២៩ ។*

*ដើម្បីរៀនបន្ថែមទៀតអំពីការស្ដារឡើងវិញនៃបព្វជិតភាព និងតួនាទីដ៏ចាំបាច់របស់វា សូមមើល អត្ថបទរបស់អែលឌើរ ហ្គែរី អ៊ី ស្ទីវ៉ែនសុន « តួនាទីដ៏សំខាន់របស់បព្វជិតភាពក្នុងការស្ដារឡើងវិញ » នៅទំព័រ ១២ ។*

*នៅលើអ្នក ជាពួកអ្នកបម្រើដូចរូបខ្ញុំអើយ* ដោយ លីនដា ឃើរលី គ្រីស្ទានសិន និង ម៉ៃឃើល ម៉លម៍
រូបថតនៃ ទន្លេសុសគ្វីហាណា ដោយ ប្រេដ វៃកឃ័រ ស្ទីវិន

# លីនី យូអ៊ីឡាអៅ

*សាវ៉ៃអ៊ី សាម័រ*



*លីនីធ្លាប់មានការលំបាកជាមួយនឹងអារម្មណ៍ខឹង និងការខ្វះភាពអត់ធ្មត់ ។ ប៉ុន្ដែនៅពេលគាត់ និងស្វាមីគាត់បានចូលសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ លីនីបានមានអារម្មណ៍ថា អារម្មណ៍ទាំងនោះបានបាត់បង់ទៅពេលដែលគាត់រស់នៅតាមដំណឹងល្អ ។*
**ឡេសលី នីលសុន ជាងថតរូប**



ខ្ញុំបានចាប់ផ្ដើមសិក្សាដំណឹងល្អ ហើយបានរៀនសូត្រតាមរយៈការបង្រៀនរបស់សាសនាចក្រពីរបៀបដែលព្រះយេស៊ូវស្រឡាញ់កុមារ ។ ទ្រង់តែងតែមានព្រះទ័យសណ្ដោសដល់ពួកគេ ។

ខ្ញុំបានចាប់ផ្ដើមខិតខំក្លាយដូចជាព្រះយេស៊ូវ ។ ឥឡូវនេះ ខ្ញុំព្យាយាមស្រឡាញ់សមាជិកគ្រួសារខ្ញុំទាំងអស់ឲ្យខ្លាំងជាងមុន ។ ខ្ញុំចំណាយពេលជាមួយពួកគេច្រើនជាងមុន ហើយចំណាយពេលច្រើនជាងមុនដើម្បីស្គាល់ពីសេចក្ដីត្រូវការរបស់ពួកគេ ។ យើងអានព្រះគម្ពីរជាគ្រួសារ ហើយអធិស្ឋានជាមួយគ្នាជារៀងរាល់យប់ ។

ឥឡូវនេះ ដួងចិត្តរបស់ខ្ញុំទន់ភ្លន់ជាងមុនច្រើន ។ ខ្ញុំមានអារម្មណ៍នៃសេចក្ដីស្រឡាញ់ និងសុខសាន្តព្រមទាំងភាពរីករាយកាន់តែច្រើននៅក្នុងផ្ទះយើង ពេលដែលយើងធ្វើតាមការបង្រៀនទាំងឡាយរបស់ព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំមានអំណរគុណចំពោះដំណឹងល្អដែលជួយឲ្យខ្ញុំរៀនពីរបៀបធ្វើជាភរិយា ម្ដាយ និងជាយាយកាន់តែល្អជាងមុន ។



### ស្វែងរកបន្ថែម

សូមមើលបន្ថែមទៀតអំពីដំណើរនៃសេចក្ដីជំនឿរបស់លីនី រួមទាំងរូបថតជាច្រើនបន្ថែមទៀត នៅក្នុងកំណែនៃអត្ថបទនេះនៅលើអ៊ិនធើរណែត ឬ Gospel Library នៅគេហទំព័រ **ChurchofJesusChrist.org/go/6206** ។

សូមអានពីរបៀបដែលអែលឌើរ នែល អិល អាន់ឌើរសិន បង្រៀនថាតើសេចក្ដីស្រឡាញ់របស់យើងសម្រាប់ព្រះអម្ចាស់ បំផុសយើងឲ្យក្លាយកាន់តែប្រសើរឡើងដោយរបៀបណា ៖ **ChurchofJesusChrist.org/go/6207** ។

## គោលការណ៍នៃការងារបម្រើ

# ការងារបម្រើតាមរយៈការប្រជុំសាក្រាម៉ង់

*ការប្រជុំសាក្រាម៉ង់ផ្ដល់ឱកាសដើម្បីភ្ជាប់ទំនាក់ទំនង និងផ្ដល់ការងារបម្រើដល់អ្នកដទៃទៀត ។*

ការប្រជុំសាក្រាម៉ង់គឺជាពេលវេលាមួយសម្រាប់ការចិញ្ចឹមបីបាច់ខាងវិញ្ញាណ និងជាការសញ្ជឹងគិតដោយផ្ទាល់ពីព្រះអង្គសង្គ្រោះ និងដង្វាយធួនរបស់ទ្រង់ ។ ពេលយើងទទួលទានសាក្រាម៉ង់ជារៀងរាល់សប្ដាហ៍ យើងត្រូវបានស្អាងឡើងជាមួយគ្នា ( សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:១១០ ) ។ ប៉ុន្តែមនុស្សមួយចំនួននៅក្នុងវួដ និងសាខារបស់យើងមកជាមួយនឹងបន្ទុកដ៏ធ្ងន់ ឬមិនបាននៅទីនោះទាល់តែសោះ ។

នេះជាឱកាសមួយចំនួនពីរបៀបដែលយើងអាចប្រើពេលវេលាដ៏ពិសិដ្ឋនោះ ដើម្បីផ្ដល់ការងារបម្រើដល់អ្នកដទៃទៀត ហើយធ្វើឲ្យមានការផ្លាស់ប្ដូរមួយក្នុងជីវិតរបស់ពួកគេ ។

### ជួយធ្វើឲ្យការប្រជុំសាក្រាម៉ង់កាន់តែប្រសើរឡើងសម្រាប់មនុស្សដែលអ្នកផ្ដល់ការងារបម្រើដល់

ជំហានទីមួយនៅក្នុងការរៀនពីរបៀបដើម្បីផ្ដល់ការងារបម្រើ គឺការស្គាល់បុគ្គល ឬគ្រួសារនោះ និងតម្រូវការរបស់ពួកគេ ។ ប្រហែលជាមានរបៀបនានាដែលអ្នកអាចជួយធ្វើឲ្យបទពិសោធន៍នៃការថ្វាយបង្គំសាក្រាម៉ង់របស់ពួកគេកាន់តែប្រសើរឡើង ដោយគ្រាន់តែរៀនបន្ថែមទៀតអំពីពួកគេ ។

រចនារូបភាពដោយ អែឌរ៉ៃដ ម៉ាក់គូវ៉ាន



សម្រាប់មីនឌី ជាម្ដាយវ័យក្មេងដែលមានកូនភ្លោះតូចៗ កិច្ចប្រឹងប្រែងយ៉ាងសាមញ្ញរបស់បងស្រីដែលផ្ដល់ការងារបម្រើដល់នាង បានធ្វើឲ្យមានការផ្លាស់ប្ដូរដ៏ធំនៅក្នុងបទពិសោធន៍នៃការប្រជុំសាក្រាម៉ង់របស់នាងជារៀងរាល់សប្ដាហ៍ ។

មីនឌីពន្យល់ថា « ដោយសារកាលវិភាគការងាររបស់ស្វាមីខ្ញុំ ខ្ញុំយកកូនស្រីភ្លោះទាំងពីររបស់ខ្ញុំទៅព្រះវិហារដោយខ្លួនឯងជារៀងរាល់សប្ដាហ៍ » ។ « វាពិតជាមានអារម្មណ៍សន្ធប់ណាស់ ក្នុងការព្យាយាមនៅឲ្យចប់ការប្រជុំសាក្រាម៉ង់ជាមួយនឹងកូនតូចៗដ៏រពឹសពីរនាក់នោះ ប៉ុន្ដែបងស្រីដែលផ្ដល់ការងារបម្រើរបស់ខ្ញុំបានយកបន្ទុកនោះដាក់ខ្លួនគាត់ដើម្បីជួយខ្ញុំ ។



« គាត់អង្គុយក្បែរខ្ញុំ ហើយជួយខ្ញុំថែទាំកូនស្រីខ្ញុំជារៀងរាល់សប្ដាហ៍ ។ គ្រាន់តែមានគាត់អង្គុយជិតខ្ញុំគឺមានន័យខ្លាំងណាស់ចំពោះខ្ញុំ ហើយពិតជាជួយសម្រួលដល់ការថប់បារម្ភរបស់ខ្ញុំនៅពេលពួកគេម៉ូម៉ៅខ្លាំង ។ ខ្ញុំគិតថា គាត់ពុំដែលបានដឹងទេថា ទង្វើរបស់គាត់បានមានផលប៉ះពាល់យ៉ាងណាចំពោះខ្ញុំនៅគ្រានោះនៃជីវិតរបស់ខ្ញុំ ។ គាត់បានឃើញពីតម្រូវការរបស់ខ្ញុំក្នុងនាមជាម្ដាយវ័យក្មេងដែលពោរពេញដោយការថប់បារម្ភ ហើយគាត់ជួយធ្វើឲ្យព្រះវិហារជាកន្លែងនៃភាពសុខសាន្ត និងរីករាយសម្រាប់យើងទាំងអស់គ្នា » ។

## គំនិតដើម្បីជួយដល់ពួកអ្នកដែលមានតម្រូវការជាក់លាក់

- សូមប្រឹក្សាជាមួយនឹងថ្នាក់ដឹកនាំកូរ៉ុមអែលឌើរ និងថ្នាក់ដឹកនាំសមាគមសង្គ្រោះ អំពីតម្រូវការរបស់សមាជិក ។
- ថ្នាក់ដឹកនាំដាក់ផែនការការឡើងនិយាយនៅការប្រជុំសាក្រាម៉ង់ ដើម្បីជួយបំពេញតាមតម្រូវការរបស់សមាជិក ។ ប្រសិនបើពួកអ្នកដែលអ្នកផ្ដល់ការងារបម្រើដល់ នឹងទទួលបានប្រយោជន៍ពីការស្ដាប់ឮសារជាក់លាក់មួយ នោះសូមចែកចាយគំនិតនោះជាមួយថ្នាក់ដឹកនាំរបស់អ្នក ។
- ប្រសិនបើអ្នកស្គាល់នរណាម្នាក់ដែលមានពិការភាព ឬមានប្រតិកម្មម្ហូបអាហារ ដែលរារាំងពួកគេពីការរីករាយនឹងពរជ័យនៃសាក្រាម៉ង់ សូមសុំព័ត៌មានពិស្ដារពីពួកគេ និងពីដំណោះស្រាយអ្វីដែលអាចត្រូវបានធ្វើឡើង ដើម្បីធ្វើឲ្យបទពិសោធន៍នៃការថ្វាយបង្គំរបស់ពួកគេបានប្រសើរឡើង ។ សូមចែកចាយព័ត៌មាននេះជាមួយនឹងថ្នាក់ដឹកនាំរបស់អ្នក ។[1]
- ប្រសិនបើនរណាម្នាក់ដែលអ្នកផ្ដល់ការងារបម្រើដល់ ឬស្គាល់ ជាប់នៅក្នុងផ្ទះដោយប្រការណាមួយដោយអចិន្ត្រៃយ៍ ឬបណ្ដោះអាសន្នក្ដី សូមសួរដល់ប៊ីស្សពរបស់អ្នកថាប្រសិនបើអាចផ្ដល់សាក្រាម៉ង់ដល់ពួកគេនៅផ្ទះ ។ ម៉្យាងទៀតអ្នកអាចសូម្បីតែធ្វើការកត់ត្រាទុកនូវអ្វីដែលបាននិយាយនៅអំឡុងការប្រជុំសាក្រាម៉ង់ ហើយចែកចាយដល់ពួកគេតាមទូរសព្ទ តាមអ៊ីម៉ែល ឬដោយផ្ទាល់ក៏បាន ។
- ប្រសិនបើនរណាម្នាក់ដែលអ្នកផ្ដល់ការងារបម្រើដល់ មានកូនតូចៗ អ្នកអាចជួយពួកគេនៅអំឡុងការប្រជុំសាក្រាម៉ង់ ។
- ប្រសិនបើអ្នកដែលអ្នកផ្ដល់ការងារបម្រើដល់ ពុំមកការប្រជុំសាក្រាម៉ង់ជាញឹកញាប់ទេ សូមព្យាយាមយល់ ហើយពិចារណាពីរបៀបដែលអ្នកអាចជួយ ។ ប្រសិនបើពួកគេត្រូវការមធ្យោបាយធ្វើដំណើរ អ្នកអាចផ្ដល់មធ្យោបាយធ្វើដំណើរដល់ពួកគេ ។ ប្រសិនបើពួកគេពុំទទួលការគាំទ្រពីគ្រួសារ អ្នកអាចអញ្ជើញពួកគេឲ្យអង្គុយជាមួយអ្នក ។ អ្នកអាចធ្វើការអញ្ជើញពិសេសនានា ដើម្បីជួយពួកគេឲ្យមានអារម្មណ៍ស្វាគមន៍ និងសំខាន់នៅក្នុងការប្រជុំសាក្រាម៉ង់ ។

## សូមចង់ចាំ កាយវិការដ៏សាមញ្ញនាំឲ្យមានផលយូរអង្វែង

និយាយដល់ការងារបម្រើ ស៊ីស្ទើរ ជេន ប៊ី ប៊ីងហាំ ប្រធានសមាគមសង្គ្រោះទូទៅបានបង្រៀន ៖ « ជួនកាល យើងគិតថា យើងត្រូវធ្វើអ្វីមួយធំដុំ និងដូចជាវីរជន ‹ ដើម្បីរាប់ថា › ជាការបម្រើដល់អ្នកជិតខាងរបស់យើង ។ ប៉ុន្ដែទង្វើសាមញ្ញៗនៃការបម្រើអាចមានឥទ្ធិពលដ៏ខ្លាំងទៅលើអ្នកដទៃ—ក៏ដូចជាខ្លួនយើងផងដែរ » ។[2]

នៅក្នុងវួដដ៏តូចមួយនៅក្នុងប្រទេសបែលហ្ស៊ិក អ៊ីវីតាតែងសូមជួយបកប្រែសម្រាប់ភ្ញៀវ និងសមាជិកដែលនិយាយភាសាអេស្ប៉ាញ អំឡុងការប្រជុំនៅព្រះវិហារ ។ មានម្ដង អ៊ីវីតាត្រូវបានណែនាំឲ្យស្គាល់មនុស្សម្នាក់ពីសាធារណរដ្ឋដូមីនីហ្គែន ដែលកំពុងរៀនអំពីសាសនាចក្រ ។ គាត់ចេះភាសាអង់គ្លេសខ្លះៗ ប៉ុន្ដែភាសាអេស្ប៉ាញគឺជាភាសាកំណើតរបស់គាត់ ។ ដូច្នេះ អ៊ីវីតាបានសូមជួយបកប្រែដោយស្ងាត់ស្ងៀមសម្រាប់គាត់នៅក្នុងការប្រជុំសាក្រាម៉ង់ ដើម្បីជួយឲ្យគាត់មានអារម្មណ៍កាន់តែកក់ក្ដៅ ។

អ៊ីវីតានិយាយថា « ជួនកាល ការបកប្រែអាចធ្វើឲ្យថ្ងៃបរិសុទ្ធរបស់ខ្ញុំមានភាពមមាញឹកបន្ដិច » ។ « ប៉ុន្ដែការធ្វើតាមការបំផុសគំនិតឲ្យសួរអ្នកដទៃទៀតថាតើពួកគេត្រូវការអ្នកបកប្រែដែរឬទេ ពិតជាផ្ដល់នូវអារម្មណ៍នៃអំណរ និងភាពកក់ក្ដៅដល់ខ្ញុំ ដោយដឹងថាខ្ញុំអាចជួយពួកគេឲ្យមានអារម្មណ៍ពីព្រះវិញ្ញាណ ហើយរីករាយនឹងការប្រជុំរបស់ពួកគេ » ។





### គំនិតដើម្បីជួយតាមរយៈទង្វើដ៏សាមញ្ញៗ

- សូមនិយាយទៅកាន់ថ្នាក់ដឹកនាំរបស់អ្នក ដើម្បីមើលថាតើនរណាអាចនឹងត្រូវការការបម្រើបន្ថែមអំឡុងការប្រជុំសាក្រាម៉ង់ ។ ឬប្រសិនបើអ្នកស្គាល់នរណាម្នាក់ដែលត្រូវការ សូមធ្វើឲ្យប្រាកដថាថ្នាក់ដឹកនាំរបស់អ្នកដឹងពីពួកគេ ។
- អង្គុយដោយស្ងៀមស្ងាត់ពេលអ្នករង់ចាំការប្រជុំចាប់ផ្ដើម ។ ការណ៍នេះនឹងជួយដល់ « មនុស្សដទៃដែលខូចចិត្ត និងមានទុក្ខដែលនៅជុំវិញយើង »[៣] ដែលត្រូវការភាពសុខសាន្តដែលអាចបានមកតាមរយៈគារវភាពនៅក្នុងកន្លែងបរិសុទ្ធ ។
- នៅថ្ងៃអាទិត្យតមអាហារ សូមពិចារណាពីការឧទ្ទិសការតមអាហារ និងការអធិស្ឋានរបស់អ្នកទៅកាន់នរណាម្នាក់ដែលអ្នកផ្ដល់ការងារបម្រើដល់ ដែលអាចនឹងត្រូវការការលួងលោមបន្ថែមទៀត ។
- សូមអធិស្ឋានដើម្បីដឹងថាបើមាននរណាម្នាក់ ដែលអាចទទួលផលពីអ្នកអង្គុយក្បែរ ឬជិតពួកគេអំឡុងការប្រជុំសាក្រាម៉ង់ ឬបើមានរបៀបផ្សេងទៀតដែលអ្នកអាចជួយបាន ។

*វាសំខាន់ដើម្បីធ្វើឲ្យប្រាកដថា អ្នកទាំងអស់ដែលចូលរួមក្នុងការប្រជុំសាក្រាម៉ង់ មានអារម្មណ៍ស្វាគមន៍ និងបីបាច់ខាងវិញ្ញាណ ។*

### ការប្រជុំសាក្រាម៉ង់អាចជាកន្លែងស្វាគមន៍មួយសម្រាប់មនុស្សទាំងអស់គ្នា

ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ( ១៨៧៦–១៩៧២ ) បានបង្រៀនថា « ការប្រជុំសាក្រាម៉ង់គឺជាការប្រជុំដ៏ពិសិដ្ឋ និងបរិសុទ្ធបំផុតលើសអស់ការប្រជុំទាំងអស់របស់សាសនាចក្រ » ។[៤] ដូច្នេះហើយ វាសំខាន់ដើម្បីធ្វើឲ្យប្រាកដថា អ្នកទាំងអស់ដែលចូលរួមក្នុងការប្រជុំសាក្រាម៉ង់មានអារម្មណ៍ស្វាគមន៍ និងបីបាច់ខាងវិញ្ញាណ—ជាពិសេសសមាជិកថ្មី ឬសមាជិកដែលពុំបានចូលរួមព្រះវិហារអស់មួយរយៈ ។

ម៉ោនៀ មកពីញូវសៅវេលស៍ ប្រទេសអូស្ត្រាលី បានធ្វើជាមិត្តនឹងស្ត្រីម្នាក់ដែលកំពុងរៀនអំពីសាសនាចក្រនៅក្នុងវួដរបស់គាត់ ។ ម៉ោនៀនិយាយថា « គាត់បានក្លាយជាមិត្តជាទីស្រឡាញ់ម្នាក់របស់ខ្ញុំឥឡូវនេះ » ។ « ខ្ញុំចូលចិត្តអង្គុយជាមួយគាត់នៅក្នុងការប្រជុំសាក្រាម៉ង់ជារៀងរាល់សប្ដាហ៍ ហើយខ្ញុំតែងតែសួរថាតើគាត់សុខសប្បាយទេ ហើយថាបើមានអ្វីដែលខ្ញុំអាចធ្វើសម្រាប់គាត់បាន » ។ មួយរយៈក្រោយមក មិត្តរបស់ម៉ោនៀបានទទួលបុណ្យជ្រមុជទឹក ។ កិច្ចប្រឹងប្រែងរបស់សមាជិកវួដ ក៏ដូចជាបរិយាកាសស្វាគមន៍នៅក្នុងការប្រជុំសាក្រាម៉ង់ ជាផ្នែកដ៏ធំមួយក្នុងការសម្រេចចិត្តរបស់គាត់ ។

### គំនិតដើម្បីផ្ដល់ការងារបម្រើដល់សមាជិកដែលត្រឡប់មកវិញ ឬសមាជិកថ្មី



- ពេលអ្នកត្រូវឡើងនិយាយក្នុងការប្រជុំសាក្រាម៉ង់ អ្នកអាចអញ្ជើញមិត្តភក្តិ គ្រួសារ និងអ្នកដទៃទៀតមកស្ដាប់សាររបស់អ្នក ។
- អ្នកអាចរកមើល ហើយស្វាគមន៍ពួកអ្នកដែលនៅម្នាក់ឯង ឬអ្នកដែលអាចនឹងត្រូវការជំនួយ ។ សួរថាបើអ្នកអាចអង្គុយក្បែរពួកគេ ឬអញ្ជើញពួកគេឲ្យអង្គុយជាមួយអ្នក ។
- ពេលការប្រជុំចប់ អ្នកអាចអញ្ជើញពួកអ្នកដែលអ្នកផ្ដល់ការងារបម្រើដល់ និងអ្នកដទៃទៀតឲ្យមកកាន់សកម្មភាពសាសនាចក្រខាងមុខទៀត មកកាន់ព្រះវិហារបរិសុទ្ធ ឬកម្មវិធីសង្គមមួយ ។
- ប្រសិនបើនរណាម្នាក់ដែលអ្នកផ្ដល់ការងារបម្រើដល់ ចូលរួមការប្រជុំសាក្រាម៉ង់ ប៉ុន្តែពុំបានមកមួយរយៈ អ្នកអាចសួរពួកគេថាតើពួកគេមានសំណួរអ្វីដែរឬទេអំពីអ្វីដែលបានបង្រៀន ។ សូមប្រាប់ពួកគេថា អ្នកស្វាគមន៍ពួកគេជានិច្ច ប្រសិនបើមានពាក្យពេចន៍ ឬផ្នែកណានៃគោលលទ្ធិដែលពួកគេមិនយល់ ។ អ្នកអាចរកមើលចម្លើយជាមួយគ្នាប្រសិនបើចាំបាច់ ។ ■

**កំណត់ចំណាំ**

១. សូមពិចារណាក្នុងការអាន « របៀប ៤ យ៉ាងដើម្បីបម្រើក្រុមគ្រួសារដែលពិការ » ( អត្ថបទមានតែជាឌីជីថល ) *លីអាហូណា* ខែ មិថុនា ឆ្នាំ ២០១៨ ឬ « ការគ្រប់គ្រងការប្រតិកម្មចំណីអាហារនៅព្រះវិហារ » នៅក្នុងច្បាប់នេះនៅទំព័រ ២២ ។

២. ជីន ប៊ី ប៊ីងហាំ « ការងារបម្រើដូចដែលព្រះអង្គសង្គ្រោះបានធ្វើ » *Liahona* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ១០៤ ។

៣. ជែហ្វ្រី អ័រ ហូឡិន « នុំះន៍ កូនចៀមនៃព្រះ » *Liahona* ខែ ឧសភា ឆ្នាំ ២០១៩ ទំព័រ ៤៦ ។

៤. យ៉ូសែប ហ្វីលឌីង ស្ម៊ីធ នៅក្នុង Conference Report ខែ តុលា ឆ្នាំ ១៩២៩ ទំព័រ ៦០–៦១ ។





**ដោយអែលឌើរ**
**ហ្គែរី អ៊ី ស្ទីវើនសុន**
ក្នុងកូរ៉ុមនៃពួកសាវក
ដប់ពីរនាក់

# តួនាទីដ៏ចាំបាច់របស់បព្វជិតភាព ក្នុងការស្ដារឡើងវិញ

បើគ្មានការត្រឡប់មកវិញនៃបព្វជិតភាពដល់ផែនដីនេះទេ នោះការស្ដារឡើងវិញនឹងពុំអាចមានលទ្ធភាពដំណើរការបានទេ ។

គិតមកដល់ខែ មេសា ឆ្នាំ ១៨២៩ យ៉ូសែប ស្ម៊ីធ បានទទួលការយាងមកជួបដ៏ទេវភាពអស់រយៈពេលជិតមួយទសវត្សរ៍ហើយ ។ ព្រះវរបិតា និងព្រះរាជបុត្រាបានយាងមកឲ្យលោកឃើញនៅក្នុងឆ្នាំ ១៨២០ នៅក្នុងព្រៃក្បែរផ្ទះលោក ពេលលោកមានអាយុ ១៤ ឆ្នាំ ( សូមមើល យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:៥–១៧ ) ។[១] ការមកជួបជាលើកដំបូងរបស់ទេវតាមរ៉ូណៃបានកើតឡើងនៅក្នុងឆ្នាំ ១៨២៣ ដោយមានការមកជួបជាប្រចាំឆ្នាំកើតឡើងតាមក្រោយនោះ ដែលអំឡុងពេលនោះយ៉ូសែបត្រូវបានបង្រៀន និងណែនាំរហូតដល់ឆ្នាំ ១៨២៧ ពេលដែលលោកបានទទួលបញ្ជីពីបុរាណដែលបានសរសេរនៅលើផ្ទាំងទាំងឡាយ ដែលបានក្លាយជាព្រះគម្ពីរមរមន ( សូមមើល យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:៣០–៥៤ ) ។

ទោះជាយ៉ាងណា អស់រយៈពេល ១៨ ខែ បន្ទាប់ពីទទួលបានផ្ទាំងទាំងឡាយ យ៉ូសែបបានមានការលំបាកក្នុងការបកប្រែបញ្ជីនោះ ដោយសារតែការយាយីពីមនុស្សក្នុងតំបន់ ការផ្លាស់ប្ដូរអ្នកសរសេរ និងការបាត់បង់ផ្នែកមួយនៃសំណេរដោយដៃ ។ វាជាពេលវេលាដ៏តានតឹង និងឈឺចាប់មួយសម្រាប់យ៉ូសែប ។ ( សូមមើល យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:៥៨–៦២; គោលលទ្ធិ និង សេចក្ដីសញ្ញា ៣ ) ។

ប៉ុន្តែអ្វីៗបានផ្លាស់ប្ដូរនៅក្នុងខែ មេសា ឆ្នាំ ១៨២៩ ជាមួយនឹងការមកដល់របស់គ្រូបង្រៀនឈ្មោះ អូលីវើរ ខៅឌើរី ដែលបានក្លាយជាអ្នកសរសេរពេញម៉ោងរបស់យ៉ូសែប ។ ពេលនោះ ការបកប្រែព្រះគម្ពីរមរមនបានប្រព្រឹត្តទៅក្នុងល្បឿនមួយយ៉ាងលឿន ។

បន្ទាប់ពីចំណាយពេលភាគច្រើនរបស់លោកអំឡុងសរទរដូវឆ្នាំ ១៨២៨ ធ្វើការនៅក្នុងចម្ការក្នុងភូមិហាម៉ូនី រដ្ឋផែនសីលវេញ៉ា ដើម្បីផ្គត់ផ្គង់ដល់គ្រួសារលោក យ៉ូសែបបានបង្វែរការយកចិត្តទុកដាក់ទាំងស្រុងរបស់លោកទៅកាន់ការបកប្រែព្រះគម្ពីរមរមននៅក្នុងឆ្នាំ ១៨២៩ ។ អិមម៉ា ភរិយារបស់យ៉ូសែប និងសាំយូអែល បងប្រុសរបស់លោកបានធ្វើជាអ្នកសរសេរអស់មួយរយៈខ្លី ។ នៅពេលជាមួយគ្នានោះដែរ អូលីវើរ ខៅឌើរី កំពុងរស់នៅជាមួយនឹងឪពុកម្ដាយយ៉ូសែបនៅទីក្រុងញូវយ៉ក ។

ដោយបានឮអំពីផ្ទាំងទាំងឡាយ និងការបកប្រែ អូលីវើរ បានចាប់អារម្មណ៍យ៉ាងខ្លាំង ហើយមានបំណងចង់ដឹងថាបើការណ៍ទាំងនេះមកពីព្រះ ។ យ៉ូសែបបានកត់ត្រាថា « យប់មួយ បន្ទាប់ពីគាត់បានចូលសម្រាន្ត គាត់បានអំពាវនាវ

រូបភាពផ្ទៃខាងក្រោយមកពី GETTY IMAGES

ទៅព្រះអម្ចាស់ ដើម្បីដឹងថាបើការណ៍ទាំងនេះពិតដូច្នោះទេ ហើយព្រះអម្ចាស់បានបើកសម្ដែងដល់គាត់ថាវាពិតមែន » ។[២]

រំពេចនោះ អូលីវើរបានធ្វើដំណើរ ២២៥ គីឡូម៉ែត្រទៅភូមិហាម៉ូនីដើម្បីទៅជួបយ៉ូសែប ។ អូលីវើរគឺជាចម្លើយចំពោះការអធិស្ឋានរបស់យ៉ូសែប ។ ពីរថ្ងៃបន្ទាប់ពីពួកលោកបានជួបគ្នានៅក្នុងខែមេសា ការបកប្រែព្រះគម្ពីរមរមនបានចាប់បន្តដោយល្បឿនដ៏លឿនអស្ចារ្យ ជិតដល់ការបញ្ចប់នៅក្នុងចន្លោះប្រមាណពី ៦០ ទៅ ៦៥ ថ្ងៃ ។ ការបកប្រែទាំងមូលត្រូវបានបញ្ចប់នៅថ្ងៃទី ៣០ ខែ មិថុនា ។

ព្យាការីយ៉ូសែបអាចសន្មត់ថា ការងារទាំងស្រុងរបស់លោកជិតនឹងបញ្ចប់ហើយ ដោយបានបំពេញអាណត្តិដ៏ទេវភាពរបស់លោក ដែលបានបង្គាប់ដោយទូតទេវតាឲ្យបកប្រែ និងបោះពុម្ពបញ្ជីពីបុរាណ ។ ព្យាការីបានដឹងតិចតួចណាស់នៅពេលនោះថា លោកមិនបានបញ្ចប់ទេ ប៉ុន្តែទើបតែចាប់ផ្ដើមតួនាទីដ៏សំខាន់របស់លោកនៅក្នុងការស្ដារឡើងវិញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ ។

*ក្រៅពីអព្ភូតហេតុនៃការបកប្រែព្រះគម្ពីរមរមន ពួកទេវតាបានមកជួប និងប្រគល់សិទ្ធិអំណាចបព្វជិតភាពដល់យ៉ូសែប និងអូលីវើរភ្លាមៗ ។*

ប្រៀបធៀបពីសារសំខាន់ព្រឹត្តិការណ៍មួយចំនួននៅក្នុងប្រវត្តិសាស្ត្រទៅនឹងអ្វីដែលបានកើតឡើងនៅក្នុងនិទាឃរដូវឆ្នាំ ១៨២៩ ។ អូលីវើរបានពិពណ៌នាពីជំពូកដ៏អស្ចារ្យនៃការស្ដារឡើងវិញនេះថាជា « ថ្ងៃដែលពុំអាចបំភ្លេចបានឡើយ » ( យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៧១ កំណត់ចំណាំ ) ។ ក្រៅពីអព្ភូតហេតុនៃការបកប្រែព្រះគម្ពីរមរមន ពួកទេវតាបានយាងមកជួប និងប្រគល់សិទ្ធិអំណាចបព្វជិតភាពដល់យ៉ូសែប និងអូលីវើរភ្លាមៗ ។ រយៈពេលវិវរណៈនៃការបកប្រែ និងការស្ដារឡើងវិញនេះ បានប្ដូរទិស និងពង្រីកទស្សនវិស័យរបស់យ៉ូសែប ហើយបានត្រួសត្រាយផ្លូវសម្រាប់ការរៀបចំសាសនាចក្រជាផ្លូវការមួយឆ្នាំក្រោយមក ។

## ការស្ដារឡើងវិញនៃបព្វជិតភាពអើរ៉ុន

ខណៈកំពុងបកប្រែព្រះគម្ពីរមរមន យ៉ូសែប និង អូលីវើរ បានរកឃើញវគ្គបទគម្ពីរជាច្រើនទាក់ទងនឹងបុណ្យជ្រមុជទឹក និងសិទ្ធិអំណាច ។ យ៉ូសែបត្រូវបានប្រាប់ពីមុនមកថា « ព្រះអម្ចាស់ [ នឹង ] ប្រទានបព្វជិតភាពដ៏បរិសុទ្ធទៅកាន់មនុស្សមួយចំនួន » ។[៣] នៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៨២៩ យ៉ូសែប និង អូលីវើរ បានទៅកាន់ទីកន្លែងស្ងាត់នៅក្នុងព្រៃដើមម៉េបផល « ដើម្បីទូលសួរដល់ព្រះអម្ចាស់ដោយការអធិស្ឋាន ពីព្រះរាជបំណងរបស់ទ្រង់ទាក់ទងនឹងខ្ញុំ » ។[៤]

ពេលដែលពួកលោកអធិស្ឋាន ព្រះសូរសៀងរបស់ព្រះអង្គសង្គ្រោះបានមានព្រះបន្ទូលនូវសេចក្ដីសុខសាន្តដល់ពួកលោក « កាលវាំងននបើកចេញទៅ ហើយមានទេវតាពីព្រះបានចុះមកពាក់ដោយសិរីល្អ ហើយបានប្រាប់នូវសារដែលបានទន្ទឹងចាំ និងកូនសោទាំងឡាយនៃដំណឹងល្អខាងការប្រែចិត្ត » ( យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៧១ កំណត់ចំណាំ ) ។ ទេវតានោះបានណែនាំខ្លួនទ្រង់ថាជាយ៉ូហាន « ជាបុគ្គលដដែល ដែលហៅថា យ៉ូហានបាទីស្ទ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ហើយថាលោកបានធ្វើការនៅក្រោមការដឹកនាំពីពេត្រុស យ៉ាកុប និងយ៉ូហាន » ( យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៧២ ) ។

យ៉ូសែប និង អូលីវើរ បានលុតជង្គង់ចុះ ពេលដែលយ៉ូហានជាបុគ្គលដែលបានរស់ឡើងវិញបានដាក់ដៃរបស់លោកលើក្បាលរបស់ពួកលោក ហើយបានប្រគល់បព្វជិតភាពអើរ៉ុនដល់ពួកលោក « ដែលកាន់កូនសោទាំងឡាយ អំពីការបម្រើនៃពួកទេវតា និងអំពីដំណឹងល្អនៃការប្រែចិត្ត និងអំពីបុណ្យជ្រមុជទឹកដោយការពន្លិចសម្រាប់ការផ្ដាច់បាប » ( យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៩; សូមមើលផងដែរ គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣:១ ) ។ ពួកលោកត្រូវបានសន្យាថា សិទ្ធិអំណាចបព្វជិតភាពបន្ថែមទៀតនឹងត្រូវបានប្រគល់ដល់ពួកលោក « នៅពេលកំណត់ទុក » ។ យ៉ូសែបត្រូវបានហៅថាជា « អែលឌើរទីមួយក្នុងសាសនាចក្រ ហើយគាត់ (អូលីវើរ ខៅឌើរ) ជាទីពីរ » ( យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៧២ ) ។ ពួកលោកត្រូវបានណែនាំឲ្យជ្រមុជទឹកគ្នាទៅវិញទៅមក—យ៉ូសែបជ្រមុជទឹកឲ្យអូលីវើរមុន ហើយបន្ទាប់មកអូលីវើរជ្រមុជទឹកឲ្យយ៉ូសែប ។

នៅពេលមួយនៅថ្ងៃនោះ ពួកលោកទាំងពីរនាក់ « បានចុះទៅក្នុងទឹក » តាមមាត់ទន្លេសុសគ្វីហាណាដើម្បីធ្វើបុណ្យជ្រមុជទឹក ។ ពួកលោក « ត្រូវបានហាមប្រាមឲ្យទុកដោយសម្ងាត់ អំពីការដែលបានទទួលបព្វជិតភាព និងបុណ្យជ្រមុជទឹកដែលយើងបានទទួលមកនោះ ដោយព្រោះវិញ្ញាណខាងការបៀតបៀន ដែលកើតឡើងពាសពេញភូមិទៅហើយនោះ » ( យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៧៤ ) ។ ទន្លេនោះគឺជាផ្លូវសំខាន់សម្រាប់ពាណិជ្ជកម្ម និងគមនាគមន៍ អំឡុងទឹកជំនន់នានិទាឃរដូវ ដោយមានលំហូរយ៉ាងថេរនៃទូក នាវាទាំងឡាយ ។ វាអាចថា យ៉ូសែប និង អូលីវើរ



បានរង់ចាំរហូតទាល់តែព្រលប់ ឬបានទាញយកប្រយោជន៍ពីទឹកជន់ ហើយរកកន្លែងស្ងាត់នៅតំបន់លិចទឹក ។[5]

បន្ទាប់ពីជ្រមុជទឹកឲ្យគ្នាទៅវិញទៅមកហើយ យ៉ូសែបបានតែងតាំងអូលីវើរដល់បព្វជិតភាពអើរ៉ុន ។ បន្ទាប់មក អូលីវើរបានតែងតាំងយ៉ូសែប ដូចដែលទេវតាបានបញ្ជាដល់ពួកលោក ។ ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានបង្រៀនថា វាចាំបាច់ដើម្បីបញ្ជាក់ឡើងវិញនូវការតែងតាំងដំបូងនោះដែលបានទទួលនៅក្រោមដៃនៃយ៉ូហាន បាទីស្ទ បន្ទាប់ពីការជ្រមុជទឹករបស់ពួកលោកដើម្បី « *ផ្សារភ្ជាប់ឡើងវិញ* នូវពរជ័យទាំងនោះតាមរបៀបដែលត្រឹមត្រូវ » ។[6]

## ការស្ដារឡើងវិញនៃបព្វជិតភាពមិលគីស្សាដែក

យើងមានព័ត៌មានស្ដួចស្ដើងទាក់ទងនឹងការមកជួបរបស់ពេត្រុស យ៉ាកុប និងយ៉ូហាន ជាមួយនឹងយ៉ូសែប និងអូលីវើរ ដើម្បីស្ដារបព្វជិតភាពមិលគីស្សាដែកឡើងវិញ ។ ការបកស្រាយផ្សេងៗដែលផ្អែកលើបញ្ជីនៃការនឹកចាំនានា កំណត់ព្រឹត្តិការណ៍ចេញពីនិទាឃរដូវឆ្នាំ ១៨២៩ ប្រហែលចុងខែឧសភា ឬខែមិថុនា ទៅដល់រាប់ខែក្រោយមកទៀត ។[7] យ៉ូសែប និងអូលីវើរ ពុំដែលបានចុះកាលបរិច្ឆេទនៃការលេចមករបស់ពេត្រុស យ៉ាកុប និងយ៉ូហាន ដូចជាពួកលោកបានចុះកាលបរិច្ឆេទសម្រាប់យ៉ូហាន បាទីស្ទ និងការស្ដារឡើងវិញនៃបព្វជិតភាពអើរ៉ុននោះឡើយ ។ ពួកលោកប្រហែលជាបានយល់ពេញលេញពីធម្មជាតិនៃបព្វជិតភាព ឬការបែងចែករបស់វាពីខាងដើម ។ ការយល់របស់យ៉ូសែបអំពីបព្វជិតភាពបានមកដោយសន្សឹមៗ ។

ចាប់ពីឆ្នាំ ១៨៣០ ទៅដល់ឆ្នាំ ១៨៣៥ មុខដំណែងបព្វជិតភាពត្រូវបានបញ្ជាក់ ហើយកូរ៉ុម ក្រុមប្រឹក្សា គណៈប្រធាន និងគណៈប៊ីស្សពត្រូវបានបង្កើតឡើង ។ សូម្បីតែពាក្យ *បព្វជិតភាពមិលគីស្សាដែក* ពុំត្រូវបានប្រើជាឈ្មោះសម្រាប់ « បព្វជិតភាពជាន់ខ្ពស់ » ឬ « បព្វជិតភាពដ៏ធំជាង » ( គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៩; ៨៤:១៩ ) រហូតទាល់តែដល់ឆ្នាំ ១៨៣៥ ( សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២–៤ ) ។

យ៉ូសែបពិតជាបានផ្ដល់នូវព័ត៌មានជាគោលអំពីទីតាំង ។ នៅក្នុងឆ្នាំ ១៨៤២ លោកបានរំឭកពីការឮ « សំឡេងនៃពេត្រុស យ៉ាកុប និងយ៉ូហាននៅក្នុងទីរហោស្ថាន រវាងភូមិហាម៉ូនី . . . និងភូមិខូលស្វិល . . . នៅលើទន្លេសុសគ្វីហាណា ដែលប្រកាសប្រាប់ថាខ្លួនជាអ្នកមានកូនសោទាំងឡាយនៃនគរ » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ១២៨:២០ ) ។

ការណ៍នេះប្រាប់ថា ការស្ដារឡើងវិញនៃបព្វជិតភាពមិលគីស្សាដែក បានកើតឡើងនៅតាមផ្លូវដែលមានរយៈចម្ងាយ ៤៥ គីឡូម៉ែត្រ រវាងផ្ទះគ្រួសារស្ម៊ីធនៅក្នុងភូមិហាម៉ូនី រដ្ឋផែនសីលវេញ៉ា និងភូមិខូលស្វិល រដ្ឋញូវយ៉ក ជាកន្លែងដែលគ្រួសារយ៉ូសែប ណៃត៍ បានរស់នៅ ។ គ្រួសារណៃត៍គឺជាសមាជិកសាសនាចក្រដំបូង ហើយជាមិត្តដ៏ស្មោះត្រង់របស់យ៉ូសែប ស្ម៊ីធ ។ ពួកគេបានផ្ដល់ជាក្រដាស និងស្បៀងអាហារអំឡុងពេលបកប្រែព្រះគម្ពីរមរមន ហើយក្រោយមកបានបង្កើតស្នូលនៃសាខាខូលស្វិលរបស់សាសនាចក្រ ។

ក្រៅពីការទទួលបព្វជិតភាពមិលគីស្សាដែកពីពេត្រុស យ៉ាកុប និងយ៉ូហាន យ៉ូសែប និងអូលីវើរត្រូវបានតែងតាំងជា « ពួកសាវក និងជាពួកសាក្សីពិសេស » របស់ព្រះអម្ចាស់ ( គោលលទ្ធិ និងសេចក្ដីសញ្ញា ២៧:១២ ) ហើយបានទទួលកូនសោទាំងឡាយដែលចាំបាច់ដល់ការបម្រើនៅក្នុងគ្រាកាន់កាប់ត្រួតត្រាដ៏ពេញកំណត់នេះ ។ ឥឡូវនេះពួកលោកបានមានសិទ្ធិអំណាចដើម្បីចាត់ចែងបព្វជិតភាពទាំងអស់ រួមបញ្ចូលទាំងការប្រគល់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។



*ការស្ដារឡើងវិញនៃបព្វជិតភាព ផ្ដោតសំខាន់ទៅលើការហៅមកពីព្រះដល់យ៉ូសែប ស្ម៊ីធ ធ្វើជាព្យាការីដំបូងនៃគ្រាកាន់កាប់ត្រួតត្រានេះ ។*

ពួកលោកក៏បានទទួលនូវ « កូនសោទាំងឡាយនៃអស់ទាំងព្រះពរខាងវិញ្ញាណនៅក្នុងសាសនាចក្រ » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ១០៧:១៨ ) ដែលចាំបាច់ដល់ការរៀបចំសាសនាចក្រឡើងនៅក្នុងខែ មេសា ឆ្នាំ ១៨៣០ និងបានទទួលវិវរណៈដើម្បីស្ដារឡើងវិញនូវកិច្ចការទាំងអស់តាមលំដាប់លំដោយត្រឹមត្រូវរបស់វា ។ ពរជ័យខាងវិញ្ញាណត្រូវបានបើកសម្ដែងតាមរយៈអព្ភូតហេតុ ការព្យាបាល និងពិធីបរិសុទ្ធទាំងឡាយ ដែលត្រូវបានធ្វើឡើងដោយសិទ្ធិអំណាចនៃបព្វជិតភាព ។ នៅក្នុងឆ្នាំ ១៨៣៦ មានសារទូតទេវតាបន្ថែមទៀតបានប្រគល់កូនសោបព្វជិតភាពទាក់ទងនឹងការប្រមូលផ្ដុំវង្សអ៊ីស្រាអែល និងកិច្ចការព្រះវិហារបរិសុទ្ធ ( សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០ ) ។

## ការជាប់ទាក់ទងនៃការស្ដារបព្វជិតភាពឡើងវិញ

ប្រធាន ដេវីឌ អូ មិកឃេ ( ១៨៧៣–១៩៧០ ) បានបង្រៀនថា ចំណុចសំខាន់ដ៏គួរឲ្យកត់សម្គាល់បំផុតនៃសាសនាចក្រដែលបានស្ដារឡើងវិញរបស់ព្រះអង្គសង្គ្រោះគឺ « សិទ្ធិអំណាចមកពីព្រះដោយវិវរណៈដោយផ្ទាល់ » ។[8] បើគ្មានការត្រឡប់មកវិញរបស់បព្វជិតភាពដល់ផែនដីនេះទេ នោះការស្ដារឡើងវិញនឹងពុំអាចមានលទ្ធភាពដំណើរការបានទេ ។ បព្វជិតភាពផ្ដល់សិទ្ធិ

ការស្ដារបព្វជិតភាពមិលគីស្សាដែកឡើងវិញ ដោយ វ៉លធើរ រ៉េន

យ៉ូសែប ស្ម៊ីធ បានធ្វើបុណ្យជ្រមុជទឹកឲ្យ អូលីវើរ ខៅឌើរ ដោយដៀល ក៏ស៊ុន

> *សូមឲ្យយើងម្នាក់ៗមានឆន្ទៈដើម្បីចូលរួមនៅក្នុងការស្ដារឡើងវិញដែលកំពុងកើតឡើងនៃដំណឹងល្អ ដោយការឱបក្រសោប និងអនុវត្តដោយរំភើបរីករាយនូវអ្វីដែលបើកសម្ដែងដល់ពួកព្យាការីសម័យទំនើប ។*

អំណាចដល់ការធ្វើពិធីបរិសុទ្ធ និងផ្ដល់ជាគម្រោងសម្រាប់ការគ្រប់គ្រងសាសនាចក្ររបស់ព្រះអម្ចាស់នៅលើផែនដី ។

យ៉ូសែបបានរៀបចំសាសនាចក្រជាផ្លូវការនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៨៣០ ។ រយៈពេលពីរបីឆ្នាំក្រោយមក គណៈប្រធានទីមួយ និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ត្រូវបានរៀបចំឡើង ។ នៅក្រោមការដឹកនាំរបស់ប្រធានសាសនាចក្រ កូនសោបព្វជិតភាពត្រូវបានផ្ទេរទៅកាន់ថ្នាក់ដឹកនាំតាមមូលដ្ឋាននៅទូទាំងពិភពលោក អនុញ្ញាតឲ្យដំណឹងល្អ « រមៀលចេញទៅដល់ទីបំផុតផែនដី » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ៦៥:២ ) ។

ការស្ដារឡើងវិញនៃបព្វជិតភាព ផ្ដោតសំខាន់ទៅលើការហៅមកពីព្រះដល់យ៉ូសែប ស៊្មីធ ធ្វើជាព្យាការីដំបូងនៃគ្រាកាន់កាប់ត្រួតត្រានេះ ។ នៅក្នុងអារម្ភកថានៃគោលលទ្ធិ និងសេចក្ដីសញ្ញា ព្រះអម្ចាស់បានពន្យល់ថា « ហេតុដូច្នេះហើយ យើងជាព្រះអម្ចាស់ ដោយជ្រាបនូវគ្រោះដែលនឹងមានមកលើបណ្ដាជនទាំងឡាយនៅលើផែនដី នោះបានហៅយ៉ូសែបស៊្មីធ ជុញ្ញ័រ ជាអ្នកបម្រើរបស់យើង ហើយបាននិយាយមកកាន់លោកពីលើស្ថានសួគ៌ ហើយបានប្រទានព្រះបញ្ញត្តិទាំងឡាយដល់លោក » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ១:១៧ ) ។

មុនការជួបរបស់យ៉ូហាន បាទីស្ទ នៅក្នុងខែឧសភា ឆ្នាំ ១៨២៩ យ៉ូសែបបានផ្ដោតលើការបកប្រែព្រះគម្ពីរមរមន ។ ជាមួយនឹងការស្ដារឡើងវិញនៃបព្វជិតភាពអើរ៉ុន និងមិលគីស្សាដែក លោកបានដឹងថា ការហៅរបស់លោករួមមានកិច្ចការជាច្រើនទៀត ។ ការទទួលបានសិទ្ធិអំណាចពីស្ថានសួគ៌បានរៀបចំយ៉ូសែបបន្ថែមទៀតដើម្បីអនុវត្តការទទួលខុសត្រូវទាំងឡាយរបស់លោកក្នុងនាមជា « អ្នកមើលឆុត ជាអ្នកបកប្រែ ជាព្យាការី [ និង ] ជាសាវកនៃព្រះយេស៊ូវគ្រីស្ទ » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ២១:១ ) ។

អែលឌើរ រ៉ូប៊ើត ឌី ហែល ( ១៩៣២–២០១៧ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានពិពណ៌នាថាតើជីវិតរបស់យើងនឹងក្លាយជាយ៉ាងណាបើពុំមានបព្វជិតភាពទេនោះ ៖ « ប្រសិនបើអំណាចនៃបព្វជិតភាពពុំមាននៅលើផែនដីទេ នោះពួកមារសត្រូវនឹងមានសេរីភាពដើម្បីទៅគ្រប់ទិសទី ហើយគ្រងរាជ្យដោយគ្មានដែនកំណត់ ។ វានឹងគ្មានអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធដើម្បីដឹកនាំ ហើយបំភ្លឺយើង គ្មានពួកព្យាការីដើម្បីថ្លែងនៅក្នុងព្រះនាមនៃព្រះអម្ចាស់ គ្មានព្រះវិហារបរិសុទ្ធដែលយើងអាចធ្វើសេចក្ដីសញ្ញាអស់កល្បជានិច្ចដ៏ពិសិដ្ឋ គ្មានសិទ្ធិអំណាចដើម្បីប្រសិទ្ធពរ ឬជ្រមុជទឹក ព្យាបាល ឬ លួងលោមឡើយ ។ ប្រសិនបើគ្មានអំណាចបព្វជិតភាពទេនោះ ‹ ផែនដីទាំងមូលនឹងត្រូវកម្ទេចចោលសូន្យឈឹង › ( សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ២:១–៣ ) ។ វានឹងគ្មានពន្លឺ គ្មានសេចក្ដីសង្ឃឹម—គឺមានតែភាពអន្ធការប៉ុណ្ណោះ » ។[៩]

ការទទួលពិធីបរិសុទ្ធបព្វជិតភាព គឺសំខាន់ដល់កិច្ចការរបស់ព្រះអម្ចាស់នៅក្នុង « [ ការ ] នាំឲ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស » ( ម៉ូសេ ១:៣៩ ) ។ ពិធីបុណ្យជ្រមុជទឹក និងការបញ្ជាក់ អំណោយទានពិសិដ្ឋ និងការផ្សារភ្ជាប់សម្រាប់ពេលនេះ និងអស់កល្បជានិច្ច គឺចាំបាច់ដល់សេចក្ដីសង្គ្រោះរបស់យើង ។ សមត្ថភាពក្នុងការចង និងផ្សារភ្ជាប់ក្រុមគ្រួសារនៅក្នុងព្រះវិហារបរិសុទ្ធសម្រាប់ពួកអ្នកដែលនៅសងខាងនៃវាំងនន អាចធ្វើទៅបានតែតាមរយៈសិទ្ធិអំណាច និងកូនសោបព្វជិតភាពប៉ុណ្ណោះ ដូចដែលបានណែនាំដោយប្រធាននៃសាសានចក្រ ។

## ការស្ដារឡើងវិញដែលកំពុងកើតឡើង

តើសិទ្ធិអំណាចបព្វជិតភាពអាចបំផុសឲ្យអ្នកចូលរួមនៅក្នុងការស្ដារឡើងវិញដែលកំពុងកើតឡើងនៃសាសនាចក្រដោយរបៀបណា ? យើងអាចនឹងមិនដឹងពីអ្វីដែលកើតឡើងនៅពេលអនាគត ប៉ុន្តែវាច្បាស់ថា ការស្ដារឡើងវិញគឺកំពុងកើតឡើង ។ ព្រះអម្ចាស់ពុំបានបើកសម្ដែងគ្រប់គោលលទ្ធិ ឬគោលការណ៍ ឬប្រទានការណែនាំទាំងអស់ដល់យ៉ូសែបនៅក្នុងព្រៃពិសិដ្ឋ តាមរយៈម៉ូរ៉ូណៃនៅយូម៉ូរ៉ា ឬនៅឯការប្រជុំដែលបានរៀបចំរបស់សាសនាចក្រនោះទេ ។ ការស្ដារឡើងវិញពុំបានកើតឡើងជាព្រឹត្តិការណ៍តែមួយនោះទេ ។ ផ្ទុយទៅវិញ ព្រះអម្ចាស់បានបើកបង្ហាញការណ៍ទាំងឡាយ « មួយបន្ទាត់ម្ដងៗ » ( នីហ្វៃទី២ ២៨:៣០ ) ដល់យ៉ូសែប គឺដូចជាទ្រង់បន្តបើកសម្ដែងការណ៍ទាំងឡាយដល់ពួកព្យាការីរបស់ទ្រង់នៅសព្វថ្ងៃនេះ យោងទៅតាមគោលបំណង និងពេលវេលារបស់ទ្រង់ ។

ខ្សែស្រឡាយជាប់មិនដាច់នៃពួកព្យាការីតាំងពីជំនាន់យ៉ូសែប ស៊្មីធ បាននិយាយជំនួសព្រះអម្ចាស់ ហើយបន្តប្រាប់ឲ្យដឹងពីព្រះរាជបំណងរបស់ទ្រង់ ។ ពួកព្យាការីមើលឃើញទស្សនវិស័យទូលំទូលាយ ហើយទទួលការណែនាំជាក់លាក់សម្រាប់ឧបសគ្គនានានៃជំនាន់របស់ពួកលោក ។ ប្រធាន រ័សុល អិម ណិលសុន ប្រកាសថា យើងទាំងអស់គ្នាជា « សាក្សីដល់ដំណើរការនៃការស្ដារឡើងវិញ ។ ប្រសិនបើបងប្អូនគិតថា សាសនាចក្រត្រូវបានស្ដារឡើងវិញពេញលេញហើយនោះ នោះបងប្អូនទើបតែឃើញការចាប់ផ្ដើមប៉ុណ្ណោះ ។ មានអ្វីៗជាច្រើនដែលនឹងកើតឡើង » ។[១០]

## ការស្ដារឡើងវិញ និងអ្នក

សូមឲ្យយើងម្នាក់ៗមានឆន្ទៈដើម្បីចូលរួមនៅក្នុងការស្ដារឡើងវិញដែលកំពុងកើតឡើងនៃដំណឹងល្អ ដោយការឱបក្រសោប និងអនុវត្តដោយរំភើបរីករាយនូវអ្វីដែលបើកសម្ដែងដល់ពួកព្យាការីសម័យទំនើប ។ ឧទាហរណ៍រួមមាន ការរស់នៅតាមច្បាប់ដែលកាន់តែខ្ពង់ខ្ពស់ និងកាន់តែបរិសុទ្ធនៃការងារបម្រើទៅដល់បងប្អូនប្រុសស្រីយើង ។[១១] ហើយសូមឲ្យយើងម្នាក់ៗរកឃើញនូវអំណរនៃដំណឹងល្អដ៏បិតថេរ តាមរយៈផែនការដែលផ្ដោតលើគេហដ្ឋាន ដោយមានការគាំទ្រពីសាសនាចក្រ ដើម្បីរៀនគោលលទ្ធិ ពង្រឹងសេចក្ដីជំនឿ រក្សាបទបញ្ញត្តិទាំងឡាយ ហើយយកចិត្តទុកដាក់បន្ថែមបីបាច់នូវការថ្វាយបង្គំផ្ទាល់ខ្លួនដែលកាន់តែរឹងប៉ឹងជាង រួមមាននូវរាត្រីជួបជុំគ្រួសារដែលបំពេញតម្រូវការបុគ្គល និងក្រុមគ្រួសារ ។[១២]

យើងអាចរៀបចំសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ដោយការពន្លឿនការប្រមូលផ្ដុំនៃអ៊ីស្រាអែលនៅផ្នែកទាំងសងខាងនៃវាំងនន ។[១៣] យើងអាចធ្វើបានប្រសើរជាងនេះ ក្នុងការធ្វើឲ្យថ្ងៃបរិសុទ្ធជាថ្ងៃដ៏រីករាយ ទាំងការថ្វាយបង្គំនៅថ្ងៃអាទិត្យរបស់យើង និងនៅគេហដ្ឋានរបស់យើង ។[១៤] យើងអាចនៅឲ្យកាន់តែមានភាពសមស្របទៅនឹងព្រះវិញ្ញាណបរិសុទ្ធ ដោយការធ្វើកិច្ចការខាងវិញ្ញាណដែលចាំបាច់ ដើម្បីទទួលបាននូវវិវរណៈផ្ទាល់ខ្លួនប្រចាំថ្ងៃ ។[១៥]

ខ្ញុំសូមថ្លែងទីបន្ទាល់ថា ស្ថានសួគ៌បើកចំហរ ហើយថាមានអ្វីជាច្រើនទៀតនឹងកើតឡើងកាលដែលព្រះអម្ចាស់រៀបចំយើងសម្រាប់ថ្ងៃដ៏រំភើបទាំងឡាយដែលនឹងមកដល់ ។ ការស្ដារបព្វជិតភាពឡើងវិញអនុញ្ញាតឲ្យបុត្រាបុត្រីព្រះ ផ្ដល់ការងារបម្រើ និងទទួលពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះ ហើយវាផ្ដល់សិទ្ធិអំណាចដល់ពួកព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈសម័យទំនើប ឲ្យដឹកនាំគេរបស់ព្រះអម្ចាស់ ។

ពរជ័យរាប់មិនអស់កើតឡើងជារៀងរាល់ថ្ងៃដល់សាសនាចក្រ និងសមាជិកដោយសារតែមានបព្វជិតភាពរបស់ព្រះអម្ចាស់ ។ សូមឲ្យយើងបង្ហាញការដឹងគុណរបស់យើងសម្រាប់ការលេចមករបស់យ៉ូហានបាទីស្ទ និងរបស់ពេត្រុស យ៉ាកុប និងយ៉ូហាន និងសម្រាប់ការត្រឡប់មកវិញនៃបព្វជិតភាពអើរ៉ុន និងមិលគីស្សាដែកនៅក្នុងថ្ងៃចុងក្រោយនេះ និងគ្រាកាន់កាប់ត្រួតត្រាចុងក្រោយបង្អស់នេះ ជាការត្រៀមរៀបចំសម្រាប់ការយាងត្រឡប់របស់ព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះរបស់យើង គឺព្រះយេស៊ូវគ្រីស្ទ ។ ■

**កំណត់ចំណាំ**

១. Joseph Smith, History, 1838–1856, vol. A-1, បានបង្កើតឡើងនៅថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៨៣៩–ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ១៨៤៣ ទំព័រ ១៥ បណ្ណាល័យប្រវត្តិសាស្ត្ររបស់សាសនាចក្រ ។
២. យ៉ូសែប ស្ម៊ីធ នៅក្នុង *History of the Church* ១:៣៥ ។
៣. អូលីវើរ ខៅឌើរី សំបុត្រទៅកាន់ ដបុលយូ ដបុលយូ ហ្វែល្ប នៅក្នុង *Latter Day Saints' Messenger and Advocate* ខែ តុលា ឆ្នាំ ១៨៣៥ ទំព័រ ១៩៩ ។
៤. *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* ( ឆ្នាំ ២០០៧ ) ទំព័រ ៨៥ ។ ខណៈដែលប្រពៃណីដែលបានកាន់យូរមកហើយ បានដាក់ពួកលោកនៅតាមដងទន្លេសុសគ្វីហាណា បញ្ជីទាំងឡាយដែលបានកើតឡើងក្នុងពេលជាមួយគ្នាបញ្ជាក់ថា ពួកលោកបានទៅកាន់ព្រៃនៃដើមម៉េបផលនៅចុងខាងជើងនៃដីនោះ ( សូមមើល Mark Lyman Staker, "Where Was the Aaronic Priesthood Restored? Identifying the Location of John the Baptist's Appearance, May 15, 1829," *Mormon Historical Studies* 12, no. 2 [Fall 2011]: ១៤២–៥៩ ) ។
៥. សូមមើល Mark L. Staker, "Where Was the Aaronic Priesthood Restored?" ទំព័រ ១៥៣ ។
៦. យ៉ូសែប ហ្វិលឌីង ស្ម៊ីធ *Doctrines of Salvation* និពន្ធដោយ ព្រូស អ័រ ម៉ាក់ខខុនឃី ( ឆ្នាំ ១៩៥៥ ) ១:១៩៧ ។
៧. សូមមើល Larry C. Porter « Dating the Restoration of the Melchizedek Priesthood » *Ensign* ខែ មិថុនា ឆ្នាំ ១៩៧៩ ទំព័រ ៥–៩; Larry C. Porter « The Restoration of the Aaronic and Melchizedek Priesthoods » *Ensign* ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ៤២–៤៤ ) ។
៨. David O. McKay «The Mission of the Church and Its Members » *Improvement Era* ខែ វិច្ឆិកា ឆ្នាំ ១៩៥៦ ទំព័រ ៧៨១ ។
៩. រ៉ូបឺត ឌី ហែល « Blessings of the Priesthood » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ទំព័រ ៣២ ។
១០. « Latter-day Saint Prophet, Wife and Apostle Share Insights of Global Ministry » newsroom.ChurchofJesusChrist.org ។
១១. សូមមើល រ័សុល អិម ណិលសុន « ការបម្រើដោយព្រះចេស្ដា និងសិទ្ធិអំណាចពីព្រះ » *Liahona* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ៦៨–៧០, ៧៥ ។ រ័សុល អិម ណិលសុន « ការងារបម្រើ » *Liahona* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ១០០ ។ ហិនរី ប៊ី អាវិរីង « ការងារបម្រើដ៏បំផុសគំនិត » *Liahona* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ៦១–៦៤ ។ ជីន ប៊ី ប៊ីងហាំ « ការងារបម្រើដូចដែលព្រះអង្គសង្គ្រោះបានធ្វើ » *Liahona* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ១០៤–១០៦ ។
១២. សូមមើល រ័សុល អិម ណិលសុន « សន្ទរកថាចាប់ផ្ដើម » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៨ ទំព័រ ៦–៨ ។ ឃ្វីនថិន អិល ឃុក "Deep and Lasting Conversion to Heavenly Father and the Lord Jesus Christ," *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៨ ទំព័រ ៨–១២ ។
១៣. សូមមើល រ័សុល អិម ណិលសុន « ក្ដីសង្ឃឹមរបស់អ៊ីស្រាអែល » ( ការប្រជុំធម្មនិដ្ឋានទូទាំងពិភពលោកសម្រាប់យុវវ័យ ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១៨ ) HopeofIsrael ។ ChurchofJesusChrist.org ។ រ័សុល អិម ណិលសុន « ការចូលរួមរបស់បងប្អូនស្រីនៅក្នុងការប្រមូលផ្ដុំសាសន៍អ៊ីស្រាអែល» *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៨ ទំព័រ ៦៩–៧០ ។
១៤. សូមមើល រ័សុល អិម ណិលសុន « ថ្ងៃឈប់សម្រាកជាថ្ងៃមួយដ៏សប្បាយ » *Liahona* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១២៩–១៣២ ។
១៥. សូមមើល រ័សុល អិម ណិលសុន « វិវរណៈសម្រាប់សាសនាចក្រ វិវរណៈសម្រាប់ជីវិតរបស់យើង » *Liahona* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ៩៣–៩៦ ។








# តើកូនរបស់ខ្ញុំដែលពិការបានត្រៀមខ្លួនដើម្បីទទួលបុណ្យជ្រមុជទឹកហើយឬនៅ ?

ខួបប្រាំបីឆ្នាំរបស់កូនប្រុសយើងជិតចូលមកដល់ហើយ ។ ប៉ុន្តែតើយើងអាចមានចិត្តប្រាកដថា គាត់បានត្រៀមខ្លួនដើម្បីទទួលបុណ្យជ្រមុជទឹកហើយឬនៅនោះ ។

ដោយ ខាធី អែឌណា ស្ទីង

មិនដល់មួយឆ្នាំទៀតទេ ដេវីឌ កូនប្រុសយើងនឹងឈានចូលអាយុប្រាំបីឆ្នាំ ។ ស្វាមីខ្ញុំ និងខ្ញុំចង់ឲ្យគាត់រៀបចំធ្វើសេចក្តីសញ្ញាដ៏ពិសិដ្ឋនៃបុណ្យជ្រមុជទឹក ។ នោះមានន័យថា ធ្វើរឿងទាំងឡាយដូចជាអានព្រះគម្ពីរមរមន សិក្សាសេចក្តីសញ្ញាបុណ្យជ្រមុជទឹ និងរំឭកសំណួរសម្ភាសបុណ្យជ្រមុជទឹក ។ យើងបានធ្វើការណ៍ទាំងអស់នេះពីមុនមកជាមួយនឹងបងស្រីរបស់ដេវីឌ ប៉ុន្តែដេវីឌមានអធីហ្សឹម ដូច្នេះការសម្រេចចិត្តថាបើគាត់គួរទទួលបុណ្យជ្រមុជទឹកឬទេគឺមិនច្បាស់លាស់ទេសម្រាប់យើង ។

មែនហើយ យើងបានដឹងថាត្រូវធ្វើអ្វីខ្លះដើម្បីជួយរៀបចំគាត់ ប៉ុន្តែសំណួរដែលយើងនៅតែគិតក្នុងចិត្តនោះគឺ ៖ តើដេវីឌ*គួរតែ*ទទួលបុណ្យជ្រមុជទឹកដែរឬទេ ? តើគាត់ត្រៀមខ្លួនហើយឬនៅ ? តើគាត់ត្រូវការទទួលបុណ្យជ្រមុជទឹកទេ ? តើគាត់បានយល់ពីអ្វីដែលគាត់នឹងប្តេជ្ញាចិត្តធ្វើដែរឬទេ ? តើយើងអាចដឹងយ៉ាងប្រាកដដោយរបៀបណាថា អ្វីដែលយើងកំពុងធ្វើជារឿងត្រឹមត្រូវនោះ ?

ដូចជាឪពុកម្តាយជាច្រើនដែលមានកូនជាមួយនឹងពិការភាពដែរ សំណួរទាំងនេះបានដឹកនាំយើងនៅលើដំណើរមួយនៃការស្វែងរកការយល់ដឹងខាងគោលលទ្ធិ និងវិវរណៈផ្ទាល់ខ្លួន ។

## អាយុនៃការទទួលខុសត្រូវ និងការទទួលខុសត្រូវ

គោលលទ្ធិ និងសេចក្តីសញ្ញា ៦៨:២៧ ចែងថា « ហើយកូនចៅរបស់ពួកគេត្រូវទទួលបុណ្យជ្រមុជទឹកសម្រាប់ការផ្តាច់បាបទាំងឡាយរបស់ខ្លួនកាលមានអាយុប្រាំបីឆ្នាំ និងទទួលការដាក់ដៃលើ » ។

ប្រសិនបើយើងផ្អែកទាំងស្រុងទៅលើខគម្ពីរនេះ យើងនឹងសន្មត់ថាក្មេងអាយុប្រាំបីឆ្នាំ ទាំងអស់គឺបានត្រៀមខ្លួនដើម្បីទទួលបុណ្យជ្រមុជទឹក ។ ទោះជាយ៉ាងណា ព្រះគម្ពីរក៏បង្រៀនផងដែរ ៖

« កូនក្មេងតូចត្រូវបានប្រោសលោះ . . . តាមរយៈព្រះរាជបុត្រាបង្កើតតែមួយរបស់យើង

« ដូច្នោះហើយ ពួកគេពុំអាចធ្វើបាបបានទេ . . . លុះត្រាពួកគេចាប់ផ្តើមទទួលការខុសត្រូវនៅចំពោះយើងសិន » ( គោលលទ្ធិ និងសេចក្តីសញ្ញា ២៩:៤៦–៤៧; សូមមើលផងដែរ ម៉ូរ៉ូណៃ ៨:៧–២២ ) ។

តើស្វាមីខ្ញុំ និងខ្ញុំអាចយល់បានដោយរបៀបណាថាបើដេវីឌមានការទទួលខុសត្រូវហើយឬនៅនោះ ? យើងបានបន្តស្រាវជ្រាវទៀត ។

យើងបានរៀនពីគោលនយោបាយសាសនាចក្រថា ការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ គឺផ្អែកទៅលើបំណងប្រាថ្នារបស់គាត់ និងកម្រិតនៃការយល់ដឹងរបស់គាត់ ៖ ប្រសិនបើដេវីឌមានភាពសក្តិសម ហើយមានបំណងប្រាថ្នាដើម្បីទទួលបុណ្យជ្រមុជទឹក ហើយបង្ហាញថាគាត់អាចទទួលខុសត្រូវ នោះយើងមិនគួររារាំងគាត់ពីការទទួលបុណ្យជ្រមុជទឹកនោះទេ ។

យើងក៏បានរៀនផងដែរថា ប្រសិនបើពិការភាពរបស់ដេវីឌកំណត់សមត្ថភាពខាងប្រាជ្ញារបស់គាត់ដូចកូនក្មេងតូចនោះ នោះគាត់មិនអាចទទួលខុសត្រូវបានទេ ហើយនឹងមិនត្រូវការពិធីបរិសុទ្ធនៃសេចក្តីសង្គ្រោះនោះទេ ( សូមមើល *ក្បួនខ្នាត ភាគ១ ៖ ប្រធានស្តេក និងប៊ីស្សព* [ ឆ្នាំ ២០១០ ] ចំណុច ១៦.១.៨ សមាជិកដែលមានសំណួរអំពីគោលលទ្ធិសាសនាចក្រ អាចធ្វើការប្រឹក្សាជាមួយប៊ីស្សពរបស់ពួកគេបាន ) ។

សមត្ថភាពខាងប្រាជ្ញារបស់ដេវីឌតាមពិតទៅធម្មតា ។ ទោះជាយ៉ាងណា ខ្ញុំនៅតែឃើញថាខ្លួនខ្ញុំមានការសង្ស័យថាតើ ដេវីឌបានឈានដល់កម្រិតនៃការទទួលខុសត្រូវសមរម្យដែរឬទេ ។ ខ្ញុំបានបន្តស្រាវជ្រាវប្រកបដោយការអធិស្ឋាន ហើយសង្ឃឹមថាបានការណែនាំដែលនឹងនាំភាពសុខសាន្តដល់ខ្ញុំ ។

## ពិការភាព និងភាពគ្មានកំហុស

ខ្ញុំស្គាល់ឪពុកម្តាយខ្លះដែលមានកូនមានពិការភាព ដែលបានទទួលនូវការលួងលោមយ៉ាងខ្លាំងពីការអានថា ពួកអ្នកដែលបានឆ្លងកាត់ជីវិតរមែងស្លាប់ដោយពុំបានមានការទទួលខុសត្រូវ នោះបន្តស្ថិតនៅក្នុងស្ថានភាពគ្មានកំហុស ៖ « អស់ទាំងកូនក្មេងតូចរស់នៅក្នុងព្រះគ្រីស្ទ ។ . . . ត្បិត

ថតរូបដោយ ឆេរី ឌូលីយ៉ា

ព្រះចេស្ដានៃសេចក្ដីប្រោសលោះ មានមកដល់អស់អ្នកណាដែលគ្មានច្បាប់ . . . ហើយចំពោះមនុស្សបែបនោះ នោះបុណ្យជ្រមុជទឹកនឹងពុំនាំមកនូវផលប្រយោជន៍អ្វីឡើយ » ( ម្ររ៉ូណៃ ៨:២២ ) ។

ព្យាការី យ៉ូសែប ស្ម៊ីធ ក៏បានពិពណ៌នាផងដែរពី លក្ខខណ្ឌរបស់កុមារដែលស្លាប់ ហើយដោយពុំទាន់ចូលដល់ការទទួលខុសត្រូវ ៖ « ហើយខ្ញុំក៏បានឃើញកូនក្មេងទាំងអស់ដែលបានស្លាប់មុនគ្រប់អាយុទទួលខុសត្រូវ នោះត្រូវបានសង្គ្រោះនៅក្នុងនគរសេឡេស្ទាលនៅស្ថានសួគ៌ដែរ » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣៧:១០ ) ។

ខ្ញុំដឹងថា សម្រាប់បុគ្គលទាំងនេះ បុណ្យជ្រមុជទឹកពុំចាំបាច់នៅក្នុងជីវិតនេះទេ ។ ខ្ញុំក៏ដឹងដែរថា ព្រះនឹងជួយយើងឲ្យដឹងនូវអ្វីដែលល្អបំផុតសម្រាប់ដេវីឌ ។

## ស្វែងរកការណែនាំពីព្រះ

មានលទ្ធភាពជាច្រើន សម្រាប់ពួកអ្នកដែលមានពិការភាព ។ បុគ្គលជាច្រើនដែលមានពិការភាព មានកម្រិតសតិខ្ពស់ជាងក្មេងអាយុប្រាំបីឆ្នាំ ហើយអាចទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ប្រសិនបើពួកគេមានការទទួលខុសត្រូវ ( សូមមើល *ក្បួនខ្នាត ភាគ១* ចំណុច ១៦.៣.៥ ) ។ បុគ្គលដទៃទៀតនឹងមិនទទួលខុសត្រូវទេ ។ ខ្ញុំបានដឹងថា ស្វាមីខ្ញុំ និងខ្ញុំអាចប្រឹក្សាជាមួយនឹងកូនប្រុសយើង ជាមួយព្រះ និងជាមួយប៊ីស្សពយើង ដែលឈរតំណាងជា « ចៅក្រមក្នុងអ៊ីស្រាអែល » ដើម្បីជួយធ្វើការសម្រេចចិត្តដ៏បំផុសគំនិត ទាក់ទងនឹងភាពរួចរាល់របស់ដេវីឌដើម្បីទទួលបុណ្យជ្រមុជទឹកឬនៅ ( សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា ១០៧:៧៦ ) ។

ពាក្យសម្ដីទាំងនេះមកពីអាលម៉ា បាននាំមកនូវក្ដីសុខសាន្តយ៉ាងខ្លាំងដល់ខ្ញុំ ៖ « ហើយឥឡូវនេះ ដោយអ្នករាល់គ្នាមានបំណងចង់ចូលរួមក្នុងក្រោលនៃព្រះ ហើយដើម្បីឲ្យបានហៅថាជារាស្ត្ររបស់ទ្រង់ . . . តើមានអ្វីទៅដែលរារាំងអ្នកមិនឲ្យទទួលបុណ្យជ្រមុជទឹកដោយនូវព្រះនាមនៃព្រះអម្ចាស់ ដើម្បីធ្វើជាសាក្សីដល់ទ្រង់ថា អ្នករាល់គ្នាបានចូលក្នុងសេចក្ដីសញ្ញាជាមួយនឹងទ្រង់ថា អ្នករាល់គ្នានឹងបម្រើព្រះអង្គ ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ដើម្បីឲ្យទ្រង់ស្រោចព្រះវិញ្ញាណទ្រង់មកលើអ្នករាល់គ្នាយ៉ាងបរិបូរណ៍ ? » ( ម៉ូសាយ ១៨:៨, ១០ ) ។

បន្ទាប់ពីការរៀបចំទាំងអស់របស់យើង គឺមេរៀនទាំងអស់របស់យើងទាំងនៅផ្ទះ និងនៅថ្នាក់បឋមសិក្សា នោះខ្ញុំបានចាប់ផ្ដើមសួរដេវីឌនូវសំណួរទាំងឡាយដែលខ្ញុំដឹងថា គាត់នឹងត្រូវសួរនៅក្នុងការសម្ភាសសម្រាប់បុណ្យជ្រមុជទឹករបស់គាត់ ។

ជួនកាលការឆ្លើយតបរបស់គាត់បង្ហាញពីការយល់ដឹង ប៉ុន្តែពេលខ្លះទៀតគាត់មិនដឹងពីរបៀបឆ្លើយតបទេ ។ ខ្ញុំឆ្ងល់ថាបើយើងកំពុងធ្វើរឿងត្រឹមត្រូវដែរឬទេ ។

នៅទីបំផុត ព្រះវិញ្ញាណបានខ្សឹបដល់ដួងចិត្តខ្ញុំថា « ហេតុអ្វីអ្នកមិនសួរដល់ដេវីឌថា គាត់គិតយ៉ាងណា ? »

ខ្ញុំបានបែរទៅដេវីឌ ហើយបានសួរថា « ដេវីឌ តើកូនចង់ទទួលបុណ្យជ្រមុជទឹកទេ ? »

គាត់បានមើលមកចំខ្ញុំ ហើយនិយាយថា « បាទ ! »

ពេលខ្ញុំសួរគាត់ថា ហេតុអ្វីបានជាគាត់ចង់ទទួលបុណ្យជ្រមុជទឹក គាត់បាននិយាយថា « ដើម្បីក្លាយដូចជាព្រះយេស៊ូវ » ។

ខ្ញុំបានពោរពេញដោយភាពសុខសាន្ត និងការណែនាំ ។ ខ្ញុំបានដឹងភ្លាមថា ទោះបីជាដេវីឌពុំយល់គ្រប់សំណួរបានឥតខ្ចោះ ក៏គាត់មានភាពរួចរាល់ដើម្បីទទួលបុណ្យជ្រមុជទឹក និងការបញ្ជាក់រួចហើយ ។ គាត់បានដឹងពីអ្វីដែលគាត់ត្រូវការដឹង ហើយសំខាន់បំផុត គាត់បានដឹង ហើយមានបំណងប្រាថ្នាដើម្បីចូលក្នុងនគរនៃព្រះតាមរយៈពិធីបុណ្យជ្រមុជទឹក ។

ថ្ងៃដែលដេវីឌទទួលបុណ្យជ្រមុជទឹក និងបញ្ជាក់ជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ជាថ្ងៃដែលពោរពេញដោយក្ដីស្រឡាញ់ មិត្តភាព និងភាពសុខសាន្ត ។ មានគ្រួសារ សមាជិកវួដ មិត្តភក្តិនៅសាលា និងសូម្បីតែគ្រូៗមកពីសាលារបស់ដេវីឌផងដែរមកពេញក្នុងបន្ទប់ ។ គំរូដែលដេវីឌបានធ្វើនៅថ្ងៃនោះ ក្នុងការជ្រើសរើសដើម្បីធ្វើតាមព្រះយេស៊ូវ ហើយទទួលបុណ្យជ្រមុជទឹកគឺជាគំរូមួយដែលជះឥទ្ធិពលល្អដល់មនុស្សជាច្រើន ។ គ្រួសាររបស់យើងកាន់តែរឹងមាំឡើង ដោយសារយើងមានឱកាសរៀនពីរបៀបដែលកិច្ចការរបស់ព្រះត្រូវបានធ្វើឲ្យឃើញតាមរយៈកូនប្រុសរបស់យើង គឺដេវីឌ ( សូមមើល យ៉ូហាន ៩:៣ ) ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា. ។*

## តើយើងអាចជួយសមាជិកដែលមានពិការភាពដោយរបៀបណា ?

កាលដែលថ្នាក់ដឹកនាំធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះដោយក្ដីស្រឡាញ់ក្នុងការជួយអ្នកដទៃទៀតឲ្យមានអារម្មណ៍ស្វាគមន៍ នោះសមាជិកដែលមានពិការភាព និងគ្រួសាររបស់ពួកគេនឹងទទួលអារម្មណ៍នៃក្ដីស្រឡាញ់របស់ទ្រង់ និងយល់ពីតួនាទីដ៏សំខាន់របស់ពួកគេនៅក្នុងព្រះកាយរបស់ព្រះគ្រីស្ទ ( សូមមើល កូរិនថូស ទី១ ១២:១២, ១៨ ) ។ នៅពេលដែលអ្នកដឹកនាំ និងបម្រើ សូមពិចារណាចំណុចខាងក្រោមនេះ ៖

១. **សូមកុំខ្លាចក្នុងការសួរសំណួរ ។** ជួនកាលយើងខ្លាចនឹងនិយាយពីភាពខុសគ្នាទាំងឡាយ ប៉ុន្តែពេលអ្នកសួរសំណួរដោយការគោរព នោះបុគ្គលទាំងឡាយនឹងពេញចិត្តចំពោះបំណងដ៏ស្មោះត្រង់របស់អ្នកដើម្បីបានយល់ពីស្ថានភាពរបស់ពួកគេ ។ សួរសំណួរក្នុងរបៀបដ៏ជាទីស្រឡាញ់មួយ ដូចជា ៖ « តើខ្ញុំអាចជួយធ្វើឲ្យបទពិសោធន៍នៅព្រះវិហាររបស់អ្នកកាន់តែមានអត្ថន័យដោយរបៀបណា ? » ជាញឹកញាប់ សមាជិកដែលមានពិការភាព និងគ្រួសារពួកគេគឺជាប្រភពដ៏ល្អបំផុតទាក់ទងនឹងពិការភាព ហើយអាចប្រាប់អ្នកបានថាអ្នកអាចជួយអ្វីខ្លះបាន ។

២. **បីបាច់ការយល់ ។** បន្ទាប់ពីការប្រឹក្សាជាមួយសមាជិកអំពីពិការភាពរបស់ពួកគេហើយ សូមពិភាក្សាជាមួយពួកគេថាអ្វីខ្លះដែលពួកគេមិនមានបញ្ហាក្នុងការដែលអ្នកចែកចាយជាមួយអ្នកដទៃទៀត ។ **បន្ទាប់មក តាមការសមរម្យ សូមជួយថ្នាក់ដឹកនាំវួដ និងសមាជិកដទៃទៀតឲ្យយល់ពីពិការភាព និងតម្រូវការរបស់បុគ្គលនោះ ។ ការណ៍នេះអាចបីបាច់ឲ្យមានមេត្តាធម៌ និងការយល់កាន់តែជ្រាលជ្រៅ ក៏ដូចជាការបំផុសគំនិតអំពីរបៀបដើម្បីផ្ដល់ការគាំទ្រផងដែរ ។**

៣. **ផ្ដល់ដំណោះស្រាយ ។** មានការកែសម្រួលសាមញ្ញជាច្រើនដែលអ្នកអាចធ្វើ ដើម្បីជំរុញដល់ការរៀនសូត្រ និងការចូលរួមសម្រាប់មនុស្សគ្រប់គ្នា រួមទាំងការអនុញ្ញាតឲ្យមានពេលវេលាបន្ថែមដើម្បីឆ្លើយតបទៅនឹងសំណួរ ការប្រើអក្សរលោតលើវីដេអូ ការឲ្យអ្នកដែលមានបញ្ហាក្នុងការស្ដាប់ឮ ឬមើលមិនសូវឃើញអង្គុយនៅកន្លែងដែលពួកគេអាចស្ដាប់ឮ ឬមើលឃើញច្បាស់ជាង និងការប្រើប្រព័ន្ធផ្សព្វផ្សាយផ្សេងៗដើម្បីបង្ហាញមេរៀន ។ **អ្នកក៏អាចប្រឹក្សាជាមួយអ្នកជំនាញខាងពិការភាពប្រចាំវួដ ឬស្ដេកផងដែរ អំពីដំណោះស្រាយជាក់លាក់ដែលអ្នកអាចធ្វើបាន ។**

៤. **បង្កើតឱកាសក្នុងការបម្រើ ។** ជួបជាមួយនឹងបុគ្គលទាំងឡាយ និងអ្នកថែទាំរបស់ពួកគេ ដើម្បីដឹងពីជំនាញ និងទេពកោសល្យរបស់ពួកគេ ។ **បន្ទាប់មក ដោយការអធិស្ឋានសូមកំណត់ពីរបៀបដ៏មានអត្ថន័យសម្រាប់ឲ្យពួកគេបម្រើ ។ មនុស្សគ្រប់គ្នាមានអ្វីមួយដែលពួកគេអាចចូលរួមចំណែកដល់កិច្ចការនោះ ។**

៥. **ឈោងទៅជួយដោយសេចក្ដីស្រឡាញ់ ។** សូមព្យាយាមធ្វើតាមការទទួលយកដោយចំហរនៅក្នុងប្រសាសន៍របស់អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ៖ « ក្នុងនាមជាសមាជិកនៃសាសនាចក្រ យើងទាំងអស់គ្នាគឺស្ថិតនៅលើការធ្វើដំណើរនេះ ។ . . . មិនថាអ្នកនៅក្នុងកាលៈទេសៈបែបណាទេ យើងស្វាគមន៍អ្នក » ( « អ្វីដែលខ្ញុំប្រាថ្នាចង់ឲ្យសមាជិកថ្មីគ្រប់រូបបានដឹង—ហើយរាល់សមាជិកដែលចូលជាយូរឆ្នាំបានចងចាំ » លីអាហូណា ខែ តុលា ឆ្នាំ ២០០៦ ទំព័រ ១០ ។ ក្នុងចំណោមធនធានសាសនាចក្រទាំងអស់ អ្វីដែលអស្ចារ្យបំផុតនោះគឺតែងតែជា បុគ្គលទាំងឡាយដែលផ្ដល់ការងារបម្រើដល់គ្នាទៅវិញទៅមកក្នុងសេចក្ដីស្រឡាញ់ និងមិត្តភាព ។



រូបថតរាងលលាដ៍ក្បាល ដោយ រាយអិន ហិនឌ័រ

# ការគ្រប់គ្រង ការប្រតិកម្ម ចំណីអាហារ នៅព្រះវិហារ

**ដោយ លីហ្សា អែន ថមសុន**

សកម្មភាពយុវវ័យនៅរាត្រីដ៏រងាមួយនៅក្នុងខែ មករា ឆ្នាំ ២០១៧ បានផ្លាស់ប្តូរគ្រួសារស្ទូវិនសុនជារៀងរហូត ។ កូនប្រុសរបស់ផៃរី និងជេនីលីន ថេននីរមានអាយុ ១៤ ឆ្នាំ ។ សកម្មភាពរួមគ្នាបានដល់ទីបញ្ចប់ ។ ថ្នាក់ដឹកនាំម្នាក់បានផ្តល់ចំណីអាហារចុងក្រោយ ។ ថេននីរ ដែលមានប្រតិកម្មនឹងសណ្តែកដី បានយកនំយុកឃីមួយ ហើយញ៉ាំវា ។ គាត់មិនគួរធ្វើដូច្នោះទេ ។ វាជានំយុកឃីសណ្តែកដី ។

ផៃរីនិយាយថា « ជាធម្មតាគាត់ប្រុងប្រយ័ត្នណាស់ » ។

ថេននីរបានត្រឡប់មកដល់ផ្ទះវិញ—ផ្ទះរបស់គាត់នៅមិនឆ្ងាយពីព្រះវិហារទេ ។ ប៉ុន្តែគាត់បានបាត់បង់ស្មារតីយ៉ាងឆាប់បន្ទាប់ពីមកដល់ផ្ទះ ។ គាត់ឈប់ដកដង្ហើម ។ គ្រូពេទ្យ និងបុគ្គលិកនៅបន្ទប់សង្គ្រោះបន្ទាន់បានពុះពារជួយគាត់យ៉ាងស្វាហាប់ ។ ប៉ុន្តែជាអកុសលកិច្ចប្រឹងប្រែងរបស់ពួកគេពុំបានជោគជ័យទេ ។

ថេននីរបានស្លាប់នៅយប់នោះ ដោយសារតែការប្រតិកម្មចំណីអាហាររបស់គាត់ ។

## បញ្ហាទូទាំងពិភពលោក

ប្រហែលប្រាំភាគរយនៃកុមារមានប្រតិកម្មចំណីអាហារនៅទូទាំងពិភពលោក ។[១] នៅក្នុងសហរដ្ឋ ប្រហែលបួនភាគរយនៃមជ្ឈិមវ័យ និងរហូតដល់ប្រាំបីភាគរយនៃកុមារមានប្រតិកម្ម[២] ដោយមានចំនួនតួលេខប្រហាក់ប្រហែលគ្នាត្រូវបានរាយការណ៍នៅក្នុងប្រទេសទាំងឡាយក្នុងទ្វីបអឺរ៉ុប និងអាស៊ី ។[៣] នៅក្នុងវួដដែលមានមជ្ឈិមវ័យ ២០០ នាក់ ចំនួននោះគឺប្រហែល ៨ នាក់ ហើយនៅក្នុងថ្នាក់បឋមសិក្សាដែលមានកុមារ ៥០ នាក់ គឺមានប្រហែលជា ៤ នាក់ ។

ចំណីអាហារច្រើនជាង ១៧០ ប្រភេទត្រូវបានកំណត់ថាអាចជាសារធាតុប្រតិកម្ម ប៉ុន្តែនៅក្នុងសហរដ្ឋកំណត់ត្រាម្ហូប « ចំនួន៨ធំៗ » ដែលមនុស្សភាគច្រើនមានប្រតិកម្មជាមួយនោះគឺ ៖ ទឹកដោះគោ ស៊ុត សណ្តែកដី គ្រាប់ផ្លែឈើ ស្រូវសាលី សណ្តែកសៀង ត្រី និងសត្វក្នុងទឹកដែលមានសំបករឹង ។[៤] នៅតាមតំបន់នានា ចំណីអាហារផ្សេងៗទៀតដែលស្ថិតនៅក្នុងបញ្ជីដែលមានសារធាតុប្រិតកម្មមាន ដូចជា សណ្តែកឈីកភី នៅក្នុងប្រទេសឥណ្ឌា គ្រាប់បាក់វីតនៅក្នុងប្រទេសកូរ៉េខាង





ត្បូង និងជប៉ុន និងពងអង្រ្កងនៅក្នុងប្រទេសថៃភាគខាងជើង ។ ទឹកដោះគោ និងស៊ុត ជានិច្ចកាលគឺស្ថិតនៅក្នុងចំណោមចំណីអាហារដែលមានសារធាតុប្រតិកម្មដ៏ទូទៅបំផុតនៅទូទាំងពិភពលោក ។[៥]

ប្រតិកម្មកើតឡើងនៅពេលដែលប្រព័ន្ធភាពស៊ាំរបស់រាងកាយបញ្ចេញប្រតិកម្មជ្រុលហួសទៅនឹងសារធាតុមួយ ដែលវាដឹងថាជាគ្រោះថ្នាក់មួយ ។ ប្រតិកម្មធ្ងន់ធ្ងរបំផុតគឺអាណាហ្វីឡាក់ទិច ដែលជាការឆ្លើយតបជាប្រព័ន្ធយ៉ាងឆាប់រហ័ស ដែលអាចបណ្ដាលឲ្យស្លាប់បាន ។[៦] រោគសញ្ញាទាំងឡាយអាចរួមមានរមួលក្រពើ ឬរមាស់នៅក្នុងមាត់ ហើមបបូរមាត់ មុខ អណ្ដាត ឬផ្នែកផ្សេងទៀតនៃរាងកាយ ចង្អោរ ឬក្អួត ពិបាកដកដង្ហើម ជីបចរដើរលឿន ហើយវិលមុខ និងស្លុត ។[៧]

វេជ្ជ. ចនណាថាន អូលសុន ជាវេជ្ជបណ្ឌិតផ្នែកប្រតិកម្ម ហើយជាសមាជិកសាសនាចក្រ បានចង្អុលបង្ហាញថា « បើវាមិនធ្ងន់ធ្ងរជាង ក៏វាធ្ងន់ធ្ងរដូចជាមនុស្សម្នាក់ដាច់សរសៃឈាម ឬគាំងបេះដូងនៅក្នុងព្រះវិហារអញ្ចឹង » ។ « មនុស្សម្នាក់ដែលមានប្រតិកម្មអាចស្លាប់លឿនជាងមនុស្សម្នាក់ដែលគាំងបេះដូង » ។

ថ្វីបើការព្យាបាលដែលអាចមានបង្ហាញពីសក្ដានុពល ក៏ឥឡូវនេះពុំមានការព្យាបាលឲ្យជាដាច់សម្រាប់ការប្រតិកម្មចំណីអាហារឡើយ ។ វេជ្ជ. អូលសុន មានប្រសាសន៍ថា បទដ្ឋាននៃការថែទាំបន្តជា « ការចៀសវាងសារធាតុដែលប្រតិកម្ម និងការស្គាល់ ព្រមទាំងការព្យាបាលអាណាហ្វីឡាក់ទិច » ។

## ចំណីអាហារជាក្ដីស្រឡាញ់

ជាញឹកញាប់ចំណីអាហារជារឿងសំខាន់សម្រាប់ការជួបជុំ ។ វាតំណាងឲ្យវប្បធម៌ ប្រពៃណី និងថ្ងៃបុណ្យ ។ ចំណីអាហារត្រូវបានប្រើប្រាស់ដើម្បីផ្ដល់ថាមពលដល់រាងកាយយើង ប៉ុន្តែវាក៏ត្រូវបានប្រើប្រាស់ដើម្បីបីបាច់ព្រលឹងយើងផងដែរ គឺបង្ហាញសេចក្ដីស្រឡាញ់ និងក្ដីកង្វល់ ហើយទាក់ទាញឲ្យមនុស្សជួបជុំគ្នា និងភ្ជាប់ទំនាក់ទំនងគ្នា ។

គ្មានកន្លែងណាដែលរឿងនេះពិតជាងនៅក្នុងព្រះវិហារនោះទេ ។ ចំណីត្រូវបានចែកចាយនៅក្នុងថ្នាក់ដើម្បីជំរុញឲ្យមានការចូលរួម ឬដើម្បីពង្រឹងដល់មេរៀនមួយ ។ ការញ៉ាំអាហាររួមគ្នា ការប្រកួតស៊ុបឈីលលី និងសកម្មភាពផ្សេងៗរបស់វួដ ផ្ដល់មូលហេតុដល់ពួកបរិសុទ្ធឲ្យជួបជុំ និងទំនាក់ទំនងគ្នាខាងសង្គម ។ យើងធ្វើម្ហូបសម្រាប់ម្ដាយដែលទើបសម្រាលកូនហើយ និងសម្រាប់បុណ្យសពទុកជាការបម្រើដែលចេញពីចិត្ត ។ យើងទុកចំណីនៅនឹងមាត់ទ្វារដើម្បីប្រាប់ថាយើងគិតពីអ្នក ។

> « មនុស្សម្នាក់ដែលមានប្រតិកម្មអាចស្លាប់លឿនជាងមនុស្សម្នាក់ដែលគាំងបេះដូង » ។

សូម្បីព្រះអង្គសង្គ្រោះបានផ្ដល់ចំណីដល់មនុស្ស ៥000 នាក់ ដែលបានប្រមូលផ្ដុំដើម្បីស្ដាប់ទ្រង់ ។[៨]

ឧទាហរណ៍ទាំងនេះជួយ បង្ហាញពីមូលហេតុដែលការប្រតិកម្មចំណីអាហារអាចពិបាកនឹងគ្រប់គ្រងណាស់ ហើយពិបាកខ្លាំងណាស់សម្រាប់មនុស្សខ្លះដើម្បីយល់—



ហើយជាពិសេស—សូម្បីតែ—នៅព្រះវិហារ ។ ជាញឹកញាប់ ចំណីអាហារជាក្ដីស្រឡាញ់ ។ ប៉ុន្តែបើសមាជិករួដមើលទៅការប្រតិកម្មម្ហូបអាហារជាឱកាសដើម្បីផ្ដល់ការងារបម្រើ នោះ សូមធ្វើចម្រុះសម្រាប់អ្នកដែលមានបញ្ហាប្រតិកម្មចំណីអាហារ ហើយសូម្បីតែ *កង្វះ*ម្ហូបអាហារក៏អាចជាការបង្ហាញនូវសេចក្ដីស្រឡាញ់ផងដែរ ។

## ធ្វើឲ្យសាក្រាម៉ង់ពិសិដ្ឋ—ហើយមានសុវត្ថិភាព

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៅក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ថា ៖ « សាក្រាម៉ង់នៃយប់ចុងក្រោយរបស់ព្រះអម្ចាស់ [ គឺ ] ពិសិដ្ឋ ទទួលស្គាល់ចំណុចប្រសព្វនៃបទពិសោធន៍ថ្វាយបង្គំប្រចាំសប្ដាហ៍របស់យើង ។ . . .

« . . . ម៉ោងដែលព្រះអម្ចាស់បានតែងតាំងឡើងនោះគឺជាម៉ោងដ៏ពិសិដ្ឋបំផុតនៅក្នុងសប្ដាហ៍របស់យើង » ។[៩]

ទោះជាយ៉ាងណា ដូចដែលបានកត់ចំណាំនៅក្នុងគោលការណ៍ណែនាំដែលបានបោះពុម្ពថ្មីៗរបស់សាសនាចក្រស្ដីអំពីការហ្វឹកហ្វឺនពីប្រតិកម្មចំណីអាហារ និងការចម្លងមេរោគ « ការប្រតិកម្មចំណីអាហារ អាចមានឥទ្ធិពលយ៉ាងខ្លាំងទៅលើសុខភាពផ្លូវចិត្តរបស់បុគ្គលម្នាក់ . . . និងលទ្ធភាពក្នុងការចូលរួមក្នុងការប្រជុំ និងសកម្មភាពរបស់សាសនាចក្រ » ។[១០]

គោលការណ៍ណែនាំរបស់សាសនាចក្រស្ដីអំពីប្រតិកម្មចំណីអាហារ រួមមាននូវការណែនាំលើការផ្ដល់នំប៉័ងសាក្រាម៉ង់ដោយសុវត្ថិភាព ក៏ដូចជារបៀបដើម្បីចៀសវាងកុំឲ្យនំប៉័ងទាំងនោះប៉ះគ្នានៅលើតុសាក្រាម៉ង់ ។ ( ព័ត៌មានលម្អិតអាចរកបាននៅ disability.ChurchofJesusChrist.org ) ។ ការធ្វើតាមគោលការណ៍ណែនាំនេះ អាចធានាបាននូវបទពិសោធន៍សាក្រាម៉ង់ដ៏មានសុវត្ថិភាព

***សមាជិកដែលមានប្រតិកម្មអាចពិភាក្សាជាមួយថ្នាក់ដឹកនាំអំពីជម្រើសដែលមានសុវត្ថិភាពសម្រាប់នំប៉័ងសាក្រាម៉ង់របស់ពួកគេ ។***



មួយសម្រាប់សមាជិកភាគច្រើន ។

សមាជិកដែលមានប្រតិកម្មចំណីអាហារអាចពិភាក្សាជាមួយប៊ីស្សពរបស់ពួកគេអំពីការសម្របសម្រួលនានាដែលអាចសមរម្យសម្រាប់ពិធីសាក្រាម៉ង់ ។ សមាជិកអាចផ្ដល់នំប៉័ងដែលមិនមានសារធាតុប្រតិកម្មរបស់គេផ្ទាល់ដោយដាក់នៅក្នុងថង់ផ្លាស្ទិកបិទជិតមួយ ។

ជាងនោះទៀត គ្រួសារដែលមានប្រតិកម្មចំណីអាហារ ប្រឈមនឹងឧបសគ្គនានា ពេលដែលអ្នកដទៃទៀតយកម្ហូប ឬចំណីមកក្នុងការប្រជុំសាក្រាម៉ង់ ។ ដោយសារប្រតិកម្មខ្លះអាចកើតឡើងបានដោយគ្រាន់តែការដកដង្ហើមចូល ឬការប៉ះសារធាតុប្រតិកម្មនោះ គ្រួសារដែលមានប្រតិកម្មចំណីអាហារសម្របសម្រួលការប្រជុំសាក្រាម៉ង់ដោយការប្ដូរកន្លែងអង្គុយ ឬប្ដូរទៅកាន់ច្រកដើរចូលវិញពេលមានចំណីអាហារដែលមានសារធាតុប្រតិកម្មលើកមក ។

នៅក្នុងការប្រជុំហ្វឹកហ្វឺន ខែ មេសា ឆ្នាំ ២០១៥ ប្រធាន អិម រ័សុល បាឡឺដ ប្រធានស្ដីទីក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានផ្ដល់យោបល់ថា « គោលដៅចម្បងរបស់យើងគឺដើម្បីឲ្យមនុស្សគ្រប់គ្នាមានបទពិសោធន៍ខាងវិញ្ញាណ និងពង្រឹងសេចក្ដីជំនឿលើព្រះវរបិតាសួគ៌របស់យើង និងព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ តាមរយៈការគោរពប្រតិបត្តិថ្ងៃបរិសុទ្ធ » ។ លោកបានបន្ថែមថា « ប្រាកដណាស់ យើងអាចរំពឹងថា ទូរសព្ទ និងអាយភែត ល្បែង និងចំណីអាហារអាចត្រូវបានទុកមួយឡែក

សម្រាប់រយៈពេលមួយម៉ោងដ៏មានតម្លៃចេញពី ១៦៨ ម៉ោងនៅក្នុងមួយសប្ដាហ៍សម្រាប់ការប្រជុំសាក្រាម៉ង់ ដែលត្រូវបានឧទ្ទិសដល់ព្រះវរបិតាសួគ៌ និងព្រះរាជបុត្រាជាទីស្រឡាញ់របស់ទ្រង់ គឺព្រះអម្ចាស់យេស៊ូវគ្រីស្ទ » ។[១១]

សម្រាប់មូលហេតុផ្សេងៗ មិនមែនមនុស្សគ្រប់គ្នាអាចទុកចំណីអាហារមួយឡែកអំឡុងពេលនៅព្រះវិហារនោះទេ ។ ប៉ុន្តែជាមួយនឹងកាលវិភាគដែលកាន់តែខ្លីជាងមុន ប្រហែលជាពួកយើងអាចពិចារណាពីយោបល់របស់ប្រធានបាឡឹដ ហើយវាយតម្លៃ ប្រសិនបើអ្នកត្រូវយកចំណីអាហារមកក្នុងការប្រជុំសាក្រាម៉ង់ ។

## ទទួលបន្ទុកគ្នាទៅវិញទៅមក

ខណៈដែលផលប៉ះពាល់ខាងរាងកាយនៃការប្រតិកម្មចំណីអាហារអាចមានភាពធ្ងន់ធ្ងរ នោះផលប៉ះពាល់ខាងវិញ្ញាណអាចមានឥទ្ធិពលដូចគ្នាផងដែរ—ទាំងល្អ និងអាក្រក់ ។

កូនស្រីរបស់ហ្វ្រេនសេសខាមានប្រតិកម្មជាមួយទឹកដោះគោយ៉ាងធ្ងន់ធ្ងរ ។ ពេលកូនស្រីនាងនៅក្នុងថ្នាក់បឋមសិក្សា គ្រូបង្រៀនម្នាក់របស់នាងចូលចិត្តយកនំខាប់ខេកធ្វើនៅផ្ទះមកកាន់ថ្នាក់សម្រាប់ខួបកំណើត ។ ហ្វ្រេនសេសខាបានសុំយកនំខាប់ខេកដែលមានសុវត្ថិភាពមកពេលណាដែលមានខួបកំណើត ។ គ្រូបង្រៀននោះបានបដិសេធ ហើយបានឲ្យក្មេងស្រីអាយុប្រាំមួយឆ្នាំនោះទៅអង្គុយនៅផ្លូវដើរក្នុងព្រះវិហារវិញ ពេលចែកចាយនំខួបកំណើត ។

ហ្វ្រេនសេសខាបានរំឭកថា « វាគួរឲ្យឈឺចាប់ណាស់ » ។ « ជំនួសឲ្យការបង្រៀនកុមារដទៃទៀតឲ្យ ‹ ធ្វើដូចព្រះយេស៊ូវ › ហើយខ្វល់ខ្វាយគ្រប់គ្រាន់ដើម្បីរាប់បញ្ចូលមនុស្សគ្រប់គ្នា នាងបានបង្រៀនពួកគេឲ្យដកមនុស្សចេញវិញ » ។

ការបញ្ចូល និងការដកចេញជាប្រធានបទទូទៅពេលអ្នកនិយាយជាមួយនឹងគ្រួសារដែលមានប្រតិកម្មចំណីអាហារ ។ កូនប្រុសអាយុប្រាំបួនឆ្នាំរបស់ស៊ីនធៀ ដែលមានប្រតិកម្មជាមួយសណ្ដែកដី និងគ្រាប់ផ្លែឈើ បានគិតថានឹងចូលរួមការបោះជំរុំពេលថ្ងៃមួយ ។ ទោះជាយ៉ាងណា នៅព្រឹកនៃការបោះជំរុំនោះ ថ្នាក់ដឹកនាំម្នាក់បានទូរសព្ទមកស្នើសុំមិនឲ្យគាត់ចូលរួម ។ ពួកគេមិនអាចផ្ដល់ការសម្របសម្រួលសម្រាប់ប្រតិកម្មចំណីអាហាររបស់គាត់បានទេ ។

ស៊ីនធៀបានរំឭកថា « ខ្ញុំបានដាក់ទូរសព្ទចុះ ហើយយំ ជាមួយទឹកភ្នែកដែលពេញដោយភាពសោកសៅ ចេញអស់ពីចិត្តខ្ញុំ ចំពោះកូនប្រុសខ្ញុំដែលត្រូវបានគេមិនរាប់បញ្ចូលម្ដងទៀត » ។

ខាធី អែឌណា ស្ទីដ ជាអ្នកគ្រប់គ្រងជំនាញខាងពិការភាពសម្រាប់សាសនាចក្រ កត់សម្គាល់ ៖ « ព្រះអង្គសង្គ្រោះទុកចោលចៀម ៩៩ ហើយទៅរកចៀមមួយដែលបាត់ ។ យើងត្រូវតែចាំពីគំរូនោះ—ដើម្បីមើលឃើញពីចៀមមួយ ហើយយល់ពីចៀមមួយនោះ » ។

## យើងអាចជួយបាន

មានអ្វីៗជាច្រើនដែលសមាជិកដែលមានប្រតិកម្មចំណីអាហារ និងគ្រួសាររួមរបស់ពួកគេអាចធ្វើ ដើម្បី

### *សំណួរសួរនៅពេលរៀបចំផែនការសម្រាប់សកម្មភាព ឬមេរៀនមួយ*

១. តើការបញ្ចូលចំណីអាហារនៅក្នុងមេរៀន ឬសកម្មភាពរបស់ខ្ញុំគាំទ្រសារលិខិតរបស់ខ្ញុំ ឬតើវាអាចរំខានដល់សារលិខិតរបស់ខ្ញុំ តើខ្ញុំអាចដកចំណីអាហារចេញពីមេរៀន ឬសកម្មភាពរបស់ខ្ញុំដែរឬទេ ?

២. ប្រសិនបើចំណីអាហារជាផ្នែកដ៏សំខាន់នៃសកម្មភាពរបស់ខ្ញុំ តើខ្ញុំអាចផ្ដល់ការបម្រើដល់អ្នកដែលមានប្រតិកម្មចំណីអាហារយ៉ាងដូចម្ដេច ? តើមានជម្រើសចំណីអាហារដែលនឹងជួយដល់គោលបំណងរបស់ខ្ញុំខណៈដែលមានសុវត្ថិភាពដល់អ្នកគ្រប់គ្នាដែលចូលរួមដែរឬទេ ? តើខ្ញុំអាចសួមដល់បុគ្គលទាំងឡាយ ឬឪពុកម្ដាយដើម្បីផ្ដល់ចំណីដែលមានសុវត្ថិភាព ឬជួយខ្ញុំឲ្យកំណត់ពីជម្រើសដែលមានសុវត្ថិភាពដែរឬទេ ?

៣. ប្រសិនបើគ្មានមធ្យោបាយដើម្បីផ្ដល់អ្វីដែលគ្រប់គ្នាអាចទទួលបានទេ តើខ្ញុំអាចផ្ដល់នូវអ្វីផ្សេងដល់អ្នកដែលមានប្រតិកម្មបានដែរឬទេ ? តើខ្ញុំអាចសម្របសម្រួលដោយផ្ទាល់ជាមួយនឹងពួកអ្នកដែលមានប្រតិកម្ម ដើម្បីរៀបចំផែនការជាមួយនឹងអ្វីដែលពួកគេអាចទទួលទានបានដែរឬទេ ?





បង្ហាញសេចក្ដីស្រឡាញ់ និងធ្វើឲ្យការចូលរួមនៅព្រះវិហារមានសុវត្ថិភាព និង រាប់បញ្ចូល ។

*តើក្រុមគ្រួសារដែលមានប្រតិកម្មចំណីអាហារអាចធ្វើអ្វីខ្លះ ?*

ក្រុមគ្រួសារដែលមានប្រតិកម្មចំណីអាហារអាចពន្យល់ពីសេចក្ដីត្រូវការរបស់ពួកគេទៅកាន់ថ្នាក់ដឹកនាំ និងគ្រូ—ហើយធ្វើការទាក់ទងម្ដងទៀតពេលមានការផ្លាស់ប្ដូរថ្នាក់ដឹកនាំ និងគ្រូ ។ ពួកគេអាចផ្ដល់ចំណីអាហារដែលមានសុវត្ថិភាព ហើយជួយដាក់ផែនការបញ្ជីមុខម្ហូប និងសកម្មភាពនានា ។ ពួកគេអាចផ្ដល់ការហ្វឹកហ្វឺនអំពីរបៀបងាយៗជួយសង្គ្រោះជីវិត និងផែនការសង្គ្រោះបន្ទាន់ ។ ពួកគេនឹងយល់ពេលសមាជិកបង្ហាញពីការភ័យខ្លាច ឬភាពស្ទាក់ស្ទើរ ប៉ុន្តែពួកគេនឹងប្រាប់ដល់សមាជិកដោយអត់ធ្មត់ ហើយធ្វើការរួមគ្នាដើម្បីស្វែងរកជម្រើសដែលមានសុវត្ថិភាព និងរាប់បញ្ចូល ។ ពួកគេគួរស្នើសុំដំណោះស្រាយសមហេតុផលដែលវួដអាចផ្ដល់ និងគាំទ្របាន ។

*តើសមាជិកវួដអាចធ្វើអ្វីបានខ្លះ ?*

សមាជិកវួដអាចព្យាយាមយល់ពីស្ថានភាពរបស់បុគ្គលម្នាក់ៗ ។ សមាជិកវួដគួរតែធ្វើតាមការណែនាំពីឪពុកម្ដាយអំពីការផ្ដល់ចំណីអាហារដល់កុមារម្នាក់ ។ ប្រសិនបើចំណីអហារជាការចាំបាច់សម្រាប់សកម្មភាព ឬមេរៀនមួយ គ្រូបង្រៀន និងថ្នាក់ដឹកនាំអាចសួរបុគ្គលទាំងឡាយ និងឪពុកម្ដាយថាបើចំណីអាហារនោះមានសុវត្ថិភាពឬទេ ។ សមាជិកវួដអាចអញ្ជើញបុគ្គលទាំងឡាយ និងឪពុកម្ដាយឲ្យចូលរួម និងដោះស្រាយបញ្ហាតាមកាលៈទេសៈចាំបាច់ ។

ស៊ូសានមានប្រតិកម្មចំណីអាហារមួយចំនួន ។ នាងមានការរំជួលចិត្តជាពិសេសដោយការគិតគូររបស់ពួកសង្ឃនៅក្នុងវួដរបស់នាង ពេលពួកគេរៀបចំសាក្រាម៉ង់ ។ នាងនិយាយថា « ខ្ញុំមានចិត្តរាបទាបជាខ្លាំងដោយសារពួកយុវជនដែលបានធ្វើឲ្យការទទួលសាក្រាម៉ង់របស់ខ្ញុំមានសុវត្ថិភាព » ។

**« *ព្រះអង្គសង្គ្រោះទុកចោលចៀម ៩៩ ហើយទៅរកចៀមមួយដែលបាត់ ។ សូមចងចាំដើម្បីមើលឃើញពីចៀមមួយ ហើយយល់ពីចៀមមួយនោះ* » ។**

នៅថ្ងៃអាទិត្យមួយ សាក្រាម៉ង់ពុំត្រូវបានចែកដល់នាងទេ ។ ពួកសង្ឃដែលរៀបចំវាបានកត់សម្គាល់ឃើញថា នំប៉័ងរបស់នាងប៉ះនឹងនំប៉័ងផ្សេងទៀតនៅលើតុ ។

ស៊ូសាននិយាយថា « ពួកគេបានមករកខ្ញុំបន្ទាប់ពីការប្រជុំសាក្រាម៉ង់ បានពន្យល់ពីអ្វីដែលបានកើតឡើង ហើយបានប្រាប់ខ្ញុំថា ពួកគេបានទទួលការអនុញ្ញាតពិសេសពីប៊ីស្សពដើម្បីផ្ដល់សាក្រាម៉ង់ដល់ខ្ញុំនៅក្នុងថ្នាក់រៀន » ។ « ខ្ញុំបានយំនៅពេល ដែលពួកគេបានប្រសិទ្ធិពរ និងចែកសាក្រាម៉ង់ នៅក្នុងបន្ទប់ដ៏តូចនោះ ។ ខ្ញុំអាចទទួលអារម្មណ៍ពី ក្ដីស្រឡាញ់របស់ព្រះអង្គសង្គ្រោះយ៉ាងខ្លាំង និងព្រះរាជ គំរិះរបស់ទ្រង់ថាតើខ្ញុំមានការលំបាកយ៉ាងណាជាមួយនឹងបញ្ហានេះ » ។



ស៊ូសាននិយាយថា « ការបង្ហាញពីឆន្ទៈដើម្បីធ្វើឲ្យមានបរិយាកាសដែលមានសុវត្ថិភាពនៅព្រះវិហារសម្រាប់មនុស្សដែលមានប្រតិកម្មធ្ងន់ធ្ងរ ក៏ជាការបង្ហាញពីឆន្ទៈដើម្បីទទួលបន្ទុកគ្នាទៅវិញទៅមកផងដែរ » ។

កូនស្រីរបស់ហ្វ្រេនសេសខាជាយុវនារីឥឡូវនេះ ។ ប្រធានយុវនារីរបស់នាងបានទទួលការបំផុសគំនិតឲ្យជួយសម្រាលបន្ទុករបស់គ្រួសារនេះ ។ នាងនិយាយថា « ខ្ញុំមានអារម្មណ៍ថា យើងត្រូវតែធ្វើអ្វីដែលត្រូវធ្វើ ដើម្បីប្រាកដថានាងមិនត្រូវបានបង្ខំឲ្យជ្រើសរើសរវាងសុវត្ថិភាព និងការថ្វាយបង្គំរបស់នាង » ។ « ខ្ញុំបានអធិស្ឋានអំពីរបៀបដែលយើងត្រូវប្រឈមនឹងស្ថានភាពនេះ ហើយបានទទួលអារម្មណ៍យ៉ាងកក់ក្ដៅថា យើងត្រូវតែ



*គ្រួសារ គ្រូបង្រៀន និងថ្នាក់ដឹកនាំអាចធ្វើការរួមគ្នាដើម្បីធ្វើឲ្យព្រះវិហារជាកន្លែងដែលមានសុវត្ថិភាពដើម្បីមនុស្សគ្រប់គ្នារៀន និងលូតលាស់ ។*

ឱបក្រសោបគ្រួសារនេះ ហើយធ្វើឲ្យប្រាកដថា ពួកគេត្រូវបានរាប់បញ្ចូលទាំងស្រុង » ។

ថ្នាក់ដឹកនាំយុវវ័យបានទទួលយកការអញ្ជើញឲ្យដាក់ផែនការសម្រាប់សន្និសីទយុវវ័យឆ្លងយប់មួយ ដែលកូនស្រីរបស់ហ្វ្រេនសេសខាអាចចូលរួមដោយសុវត្ថិភាព ។ ហ្វ្រេនសេសខាបានជួយរៀបផែនការបញ្ជីមុខម្ហូប និងទៅទិញម្ហូប ។ កម្លាំងរបស់យុវជនបានជួយលាងសម្អាតចង្ក្រានអាំងសាច់មុនពេលពួកគេចម្អិនលើវា ។

ហ្វ្រេនសេសខានិយាយថា « វាគឺជារឿងដ៏អស្ចារ្យ ! » « ខ្ញុំបានយំ ហើយ ទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ព្រះតាមរយៈសកម្មភាពដ៏សប្បុរស និងរាប់បញ្ចូលរបស់ពួកគេ ។ កូនស្រីខ្ញុំក៏មានអារម្មណ៍បែបនោះដែរ » ។

## កិច្ចការរបស់ព្រះបានបើកសម្ដែងឡើង

គ្រួសាររបស់ថេនន័របានឃើញអព្ភូតហេតុជាច្រើនទាំងធំ ទាំងតូច តាំងពីបានបាត់បង់កូនប្រុសរបស់ពួកគេមក ។ ពួកគេសង្ឃឹមឲ្យមាននូវការយល់ដឹងកើនឡើងអំពីប្រតិកម្មចំណីអាហារ គឺជាអព្ភូតហេតុមួយក្នុងចំណោមនោះ ។

ផែរី ឪពុករបស់ថេនន័រនិយាយថា « មិនមែនថាក្មេងទាំងនេះដែលមានប្រតិកម្មចំណីអាហារពុំមានការទទួលខុសត្រូវនោះទេ ។ មិនមែនថាពួកគេមិនយកចិត្តទុកដាក់នោះទេ ។ ប៉ុន្តែពួកគេជាក្មេងៗ » ។ « វាគ្រាន់តែអ្នកមិនបានប្រុងប្រយ័ត្នតែមួយវិនាទីប៉ុណ្ណោះ » ។

ប៉ុន្តែការផ្ដល់ការងារបម្រើអាចជួយការពារពួកគេបាន ។ វេជ្ជ. អូលសុន និយាយថា « និយមន័យនៃការងារបម្រើ មានន័យថា ការឆ្លើយតបដល់តម្រូវការរបស់អ្នកដទៃទៀត » ។ « អ្វីគ្រប់យ៉ាងអំពីព្រះវិហារគឺផ្អែកលើតម្រូវការរបស់បុគ្គលម្នាក់ៗ ហើយធ្វើឲ្យប្រាកដថា តម្រូវការខាងវិញ្ញាណ និងខាងរាងកាយរបស់ពួកគេត្រូវបានបំពេញតាម » ។

សារ៉ុន អូប៊ែង ទីប្រឹក្សាទីមួយក្នុងគណៈប្រធានសមាគមសង្គ្រោះទូទៅ បានបង្រៀនថា « ព្រះគ្រីស្ទបានប្រាប់ដល់ពួកនីហ្វៃដោយទន់ភ្លន់ថា ‹ យើងមិនបានបញ្ជា*នរណាមួយក្នុងពួកអ្នក*ឲ្យចេញទៅឡើយ › ។ . . . វាគឺជាតម្រូវការដ៏ខ្ជាប់ខ្ជួនមួយរបស់ពួកសិស្សគ្រីស្ទាន និងពួកបរិសុទ្ធថ្ងៃចុងក្រោយដើម្បីបង្ហាញសេចក្ដីស្រឡាញ់ពិតដល់គ្នាទៅវិញទៅមក » ។[១២]

សម្រាប់ហ្វ្រេនសេសខា បន្ទាប់ពីការលំបាកផ្ទាល់ខ្លួនដើម្បីយល់ពីមូលហេតុដែលកូននាងប្រឈមនឹងឧបសគ្គនៃការប្រតិកម្មចំណីអាហារ នាងបានយល់ដឹងថា « ជួនកាលព្រះព្យាបាលមនុស្សម្នាក់ដែលមានពិការភាព ដើម្បីបង្ហាញនូវកិច្ចការដ៏រុងរឿងរបស់ទ្រង់ ហើយពេលខ្លះទៀតទ្រង់អនុញ្ញាតឲ្យមនុស្សម្នាក់បន្តមានពិការភាព ដោយសារទ្រង់ចង់បង្ហាញកិច្ចការរបស់ទ្រង់នៅក្នុងរបៀបដែលអ្នកដទៃទៀតប្រព្រឹត្តិចំពោះបុគ្គលនោះ ។ ព្រះប្រទានដល់យើងទាំងអស់គ្នានូវឱកាសដើម្បីរៀនមានសណ្ដានចិត្តល្អ និងរៀនក្លាយដូចជាទ្រង់ ដោយការអនុញ្ញាតឲ្យយើងក្លាយជាអព្ភូតហេតុមួយ សម្រាប់នរណាម្នាក់នៅក្នុងការរងទុក្ខរបស់ពួកគេ » ។ ■


**កំណត់ចំណាំ**

១. សូមមើល « Food Allergies: Global Burden, Causes, Treatment, Prevention and Public Policy » ( ការសិក្សាមតិទូទៅដោយ U.S. Institute of Medicine ឆ្នាំ ២០១៧ ) National Academies of Science ។
២. សូមមើល Wenyin Loh and Mimi L. K. Tang, “The Epidemiology of Food Allergy in the Global Context,” *International Journal of Environmental Research and Public Health,* វ៉ុល ១៥ លេខ ៩ ( ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៨ ) ទំព័រ ២០៤៣ ncbi.nlm.nih.gov/pmc/articles/PMC6163515 ។
៣. សូមមើល Alison Joanne Lee, Meera Thalayasingam, and Bee Wah Lee, “Food Allergy in Asia: How Does It Compare?” *Asia Pacific Allergy,* វ៉ុល ៣ លេខ ១ ( ខែ មករា ឆ្នាំ ២០១៣ ) ទំព័រ ៣–១៤ ncbi.nlm.nih.gov/pmc/articles/PMC3563019/; FARE: Food Allergy Research & Education ។ “Food Allergy Facts and Statistics for the U.S.,” foodallergy.org/sites/default/files/migrated-files/file/Final-FARE-Food-Allergy-Facts-Statistics.pdf. ការប្រតិកម្មចំណីអាហារខ្លះបាត់ទៅវិញ ឬខ្សោយជាងពេលធំឡើង ដែលមានភាគរយនៃការប្រតិកម្មនៅក្នុងវ័យកុមារមានច្រើនជាងមជ្ឈិមវ័យ ។
៤. សូមមើល FARE, “Food Allergy Facts and Statistics for the U.S” ។
៥. សូមមើល Loh and Tang, “The Epidemiology of Food Allergy in the Global Context” ។
៦. សូមមើល “Signs and Symptoms,” anaphylaxis.org.uk/hcp/what-is-anaphylaxis/signs-and-symptoms ។
៧. សូមមើល Mayo Clinic, “Food allergy,” mayoclinic.org ។
៨. សូមមើល ម៉ាកុស ៦:៣៧–៤៤; លូកា ៩:១០–១៧ ។
៩. ជែហ្វ្រី អ័រ ហូឡិន « នំុះន៍ កូនចៀមនៃព្រះ » *Liahona* ខែ ឧសភា ឆ្នាំ ២០១៩ ទំព័រ ៤៥, ៤៦ ។
១០. “Food Allergies,” នៅក្នុងផ្នែក Policies and Guidelines នៃ disability.ChurchofJesusChrist.org ។
១១. អិម. រ័សុល បាឡឺត នៅក្នុង « April 2015: Sabbath Day Observance » ( វីដេអូ ) ChurchofJesusChrist.org/media-library ។
១២. សារ៉ុន អូប៊ែង « ព្រះគ្រីស្ទ ៖ ជាពន្លឺដែលបំភ្លឺនៅក្នុងភាពងងឹត » *Liahona* ខែ ឧសភា ឆ្នាំ ២០១៩ ទំព័រ ៧៤ ការសង្កត់ន័យត្រូវបានបន្ថែម ។



យើងសូមចែកចាយបទពិសោធន៍មួយចំនួន ដែលយើងបានរៀនពីបទពិសោធន៍របស់យើងជាមួយដូរ៉ា កូនស្រីយើងដែលមានតម្រូវការពិសេស ដោយសង្ឃឹម និងអធិស្ឋានថា គំនិត និងពាក្យសម្ដីរបស់យើងអាចផ្ដល់ពរដល់នរណាម្នាក់ផ្សេងទៀត ដែលស្ថិតនៅលើដំណើរស្រដៀងគ្នានេះ ។



**ដោយ អែលឌើរ ផល ប៊ី ដែបភើរ**
ក្នុងពួកចិតសិបនាក់
**និងដោយ ម៉ែលីស្សា ធី ដែបភើរ**

# មនុស្សដែលមានតម្រូវការពិសេស មេរៀនពិសេស

នៅប៉ុន្មានថ្ងៃបន្ទាប់ពីការសម្រាលរបស់ដូរ៉ាដោយការវះកាត់ដែលបានកំណត់ទុក នោះយើងបានដឹងថាមានអ្វីមួយខុសធម្មតាអំពីនាង ។ ប៉ុន្តែទាល់តែពេលដែលយើងប្រញាប់យកនាងទៅមន្ទីរពេទ្យពីការពិនិត្យសុខភាពជាមួយវេជ្ជបណ្ឌិតនៅបីសប្ដាហ៍ក្រោយមក ទើបយើងបានចាប់ផ្ដើមយល់ថា កំណើតរបស់នាងជាព្រឹត្តិការណ៍ដែលផ្លាស់ប្ដូរជីវិតគ្រួសារយើង ។

ជាច្រើនសប្ដាហ៍ និងខែបន្ទាប់ពីនោះ យើងមានក្ដីសង្ឃឹមដ៏ច្រើនផង ហើយភ័យខ្លាចខ្លាំងផងដែរ កាលដែលអ្នកជំនាញខិតខំជាខ្លាំងដើម្បីធ្វើរោគវិនិច្ឆ័យលើស្ថានភាពរបស់ដូរ៉ា ។ របាយការណ៍វិភាគនីមួយៗនាំមកនូវភាពថប់បារម្ភរបស់វាផ្ទាល់ ។

យើងបានឆ្លើយតបទៅនឹងរោគវិនិច្ឆ័យដែលអាចកើតមានមួយថា « ឱសូមកុំឲ្យ *ដូច្នោះ*ឡើយ ។ យើងមិនអាចទ្រាំបានទេ បើយើងបាត់បង់នាងនោះ » ។ យើងបានឆ្លើយតបទៅនឹងការវិនិច្ឆ័យរោគមួយទៀតថា « បើសិនជាវា*ដូច្នេះ* យើងមិនប្រាកដថាយើងអាចដោះស្រាយជាមួយវាយ៉ាងដូចម្ដេចនោះទេ » ។

ការធ្វើរោគវិនិច្ឆ័យគឺជាដាវមុខពីរ ។ វាអាចធ្វើឲ្យយើងបានធូរចិត្ត ហើយជួយមនុស្សម្នាក់ឲ្យយល់ថាអនាគតនឹងទៅជាយ៉ាងណា ប៉ុន្តែវាក៏បង្កើតនូវការរំពឹងទុក ឬកំណត់ពីព្រំដែនដែលអាចមិនមែនជាការពិតផងដែរ ។ ក្នុងករណីរបស់យើង យើងមានអំណរគុណដែលបន្ទាប់ពីរបាយការណ៍វិភាគ និងការធ្វើតេស្ដ៍ទាំងអស់ ក្រុមវេជ្ជបណ្ឌិតមិនអាចផ្ដល់លទ្ធផលនៃរោគវិនិច្ឆ័យជាក់លាក់មួយសម្រាប់ដូរ៉ាឡើយ ។



ពួកគេប្រាប់យើងថា « សរីរាង្គរបស់នាងធ្វើការធម្មតាទាំងអស់ ប៉ុន្តែនាងមានសាច់ដុំខ្សោយ ហើយប្រកាច់ ។

យើងបានរស់នៅជាមួយនឹងប្រយោគនេះអស់ ២៨ ឆ្នាំហើយ—ភាពមិន

*យើងចូលចិត្តកំណត់ដូរ៉ាដោយសមត្ថភាពរបស់នាង ជាជាងដោយការមានដែនកំណត់របស់នាង ។*

រូបថតដូរ៉ា ផ្ដល់ឲ្យដោយគ្រួសារដែបភើរ

ច្បាស់លាស់របស់វា ភាពបត់បែនរបស់វា ឧបសគ្គរបស់វា ព្រមទាំងអំណោយ និងលទ្ធភាពរបស់វា ។ យើងមិនបានដឹងថាវិថីនេះនឹងទៅជាយ៉ាងណានោះទេ ប៉ុន្តែយើងមិនដែលមានអារម្មណ៍ថាត្រូវបានកំណត់ព្រំដែនដោយរោគវិនិច្ឆ័យវេជ្ជសាស្ត្រជាក់លាក់មួយឡើយ ។

## ការកំណត់ថាមនុស្សម្នាក់មានតម្រូវការពិសេស

សំណួរមួយចំនួនដែលយើងបានទទួលអស់ជាច្រើនឆ្នាំនេះអំពីដូរ៉ាគឺ « តើនាងមានជម្ងឺអ្វី ? » និង « តើអ្វីជាពិការភាពរបស់នាង ? » ជាទូទៅយើងឆ្លើយដោយនិយាយដូចនេះថា « មែនហើយ នាងមិននិយាយ ដើរដោយគ្មានជំនួយ ឬញ៉ាំ ឬស្លៀកពាក់ដោយខ្លួនឯងបានឡើយ ប៉ុន្តែនាងមានអ្វីៗច្រើនជាងនោះទៀត » ។

យើងបានរៀនដើម្បីមិនកំណត់នាងដោយអសមត្ថភាព ឬភាពមានកំណត់របស់នាងឡើយ ។ ប៉ុន្តែ យើងចូលចិត្តកំណត់នាងដោយសមត្ថភាពរបស់នាងវិញ ។

ឧទាហរណ៍ ដូរ៉ាអាចញញឹម ។ ស្នាមញញឹមរបស់នាងធ្វើឲ្យមនុស្សនៅជុំវិញនាងញញឹមដែរ ។ មនុស្សដែលមិនស្គាល់យើងសោះបានបញ្ឈប់យើងនៅព្រលានយន្តហោះដើម្បីសួរថាបើពួកគេអាចថតរូបជាមួយដូរ៉ាបានឬទេ ដោយគ្រាន់តែព្រោះពួកគេរំជួលចិត្តដោយពន្លឺនៃស្នាមញញឹមដ៏ចែងចាំងរបស់នាង ។

នាងអាចឱប ។ បើអ្នកមានសំណាងគ្រប់គ្រាន់ដើម្បីបានដូរ៉ាឱប នោះវានឹងផ្លាស់ប្ដូរជីវិតអ្នក ។ មានពេលមួយនោះ ពេលយើងកំពុងដើរចេញពីកម្មវិធីកីឡាមួយដោយឆ្លងកាត់បុរសអនាថាម្នាក់នៅចញ្ចើមផ្លូវ ដូរ៉ាបានចូលទៅជិត និងឱបគាត់ដោយឯកឯង ។ ទឹកមុខរបស់គាត់បង្ហាញយ៉ាងជាក់ស្ដែងថា ការឱបរបស់នាងគឺជាអ្វីមួយដែលអស្ចារ្យបំផុតដែលគាត់បានទទួលនៅថ្ងៃនោះ ។



### រាងកាយទន់ខ្សោយ ជោគវាសនាដ៏ទេវភាព



« មិនតម្រូវឲ្យមានរូបកាយល្អឥតខ្ចោះមួយ ដើម្បីសម្រេចបានជោគវាសនាដ៏ទេវភាពនោះទេ ។ ការពិត វិញ្ញាណដ៏ផ្អែមល្ហែមមួយចំនួនត្រូវបានដាក់ក្នុងរូបកាយទន់ខ្សោយ ។ ជាញឹកញាប់ កម្លាំងខាងវិញ្ញាណដ៏អស្ចារ្យត្រូវបានអភិវឌ្ឍ ដោយអ្នកដែលមានឧបសគ្គខាងរាងកាយ—ពិតណាស់គឺមកពីពួកគេមានការពិបាកខ្លាំង ។ បុគ្គលបែបនោះស័ក្តិសមនឹងទទួលនូវពរជ័យទាំងអស់ដែលព្រះបានរៀបចំសម្រាប់បុត្រាបុត្រីដ៏ស្មោះត្រង់ និងគោរពប្រតិបត្តិរបស់ទ្រង់ » ។

ប្រធាន រ័សុល អិម ណិលសុន « Your Body: A Magnificent Gift to Cherish » *Liahona* ខែសីហា ឆ្នាំ ២០១៩ ទំព័រ ៥៣ ។

ដូរ៉ាជួយអ្នកឲ្យទទួលអារម្មណ៍នៃក្ដីស្រឡាញ់ ។ ប្រសិនបើដូរ៉ាសម្លឹងប៉ះភ្នែកអ្នកសូម្បីតែមួយវិនាទី នោះអ្នកនឹងទទួលអារម្មណ៍នៃក្ដីស្រឡាញ់ និងភាពផ្អែមល្ហែមដែលអាចបណ្ដាលឲ្យអ្នកមានទឹកភ្នែករលីងរលោង ។ ជាមួយនឹងអំណោយទានដ៏អស្ចារ្យទាំងនោះ ហេតុអ្វីយើងចង់កំណត់នាងថា « អសមត្ថភាព » ឬ « ពិការ » ទៅវិញ ? នាងបានជះឥទ្ធិពលល្អដល់ជីវិតមនុស្សរាប់រយអ្នក ដោយគ្រាន់តែបង្ហាញគុណសម្បត្តិធម្មជាតិរបស់នាង ហើយធ្វើនូវអ្វីដែលនាងធ្វើ ។

## មួយថ្ងៃម្ដងៗ

វាងាយស្រួលនឹងមានការសន្ទប់ចិត្តដល់ឪពុកម្ដាយ ពេលដឹងថាកូនរបស់ពួកគេនឹងត្រូវពឹងផ្អែកលើពួកគេអស់មួយជីវិតនោះ ។ អារម្មណ៍សន្ទប់ចិត្តនោះកាន់តែជ្រាលជ្រៅថែមទៀត ពេលដែលកូននោះតម្រូវនូវការគាំទ្រឥតឈប់ឈរខាងរាងកាយ ផ្លូវចិត្ត ហើយប្រហែលជាខាងវេជ្ជសាស្ត្រផង ។ ការគិតឃើញពីការបញ្ចុក ការស្លៀកពាក់ ការងូតទឹក ការថែទាំ និងការគាំទ្រដល់កូនម្នាក់ជារៀងរាល់ថ្ងៃ អាចឃើញថាជាភ្នំមួយដ៏ខ្ពស់ និងចោតហួសដើម្បីឡើងទៅ ។

នៅក្នុងគ្រាទាំងនោះ វាសំខាន់ដើម្បីឈានត្រឡប់ក្រោយ ហើយនិយាយថា « ខ្ញុំគ្រាន់តែត្រូវធ្វើវាថ្ងៃនេះប៉ុណ្ណោះ » ។ យើងបានឃើញថា ដោយការផ្ដោតតែទៅលើតម្រូវការ និងឱកាសនៃថ្ងៃនីមួយៗ នោះកិច្ចការហាក់ដូចជាអាចគ្រប់គ្រងបានជាង ។ យើងអាច

រស់នៅគ្រាន់តែមួយថ្ងៃម្ដងៗ ហើយយើងអាចរកមើលអំណរ និងភាពលូតលាស់ដែលបានមកនៅថ្ងៃនោះ ។

## សមត្ថភាពនៃការពង្រីក

វិញ្ញាណនីមួយៗដែលត្រូវបានបញ្ជូនមកផែនដី គឺមានសមត្ថភាពនៃ « ការពង្រីក » ។[1] យើងទាំងអស់គ្នាត្រូវបានរំពឹងឲ្យអនុវត្តសិទ្ធិជ្រើសរើសរបស់យើងឲ្យដល់កម្រិតដែលយើងអាចធ្វើបាន ។ យើងដែលជាអ្នកថែទាំមានទំនួលខុសត្រូវដើម្បីជួយដល់ពួកអ្នកដែលនៅក្រោមការថែទាំរបស់យើងឲ្យលូតលាស់ និងរីកចម្រើនឡើងខាងរាងកាយ ខាងផ្លូវអារម្មណ៍ និងខាងវិញ្ញាណឲ្យដល់កម្រិតមួយដែលពួកគេអាចធ្វើទៅបាន ។ នោះអាចមានន័យថា ជួយពួកគេឲ្យមានឱកាសដើម្បីបម្រើ—ដូចជាដូរ៉ាបានផ្ដល់ការឱប ឬស្នាមញញឹម ។ វាក៏អាចមានន័យថា ជួយពួកគេឲ្យប្រើប្រាស់ ហើយបើអាចធ្វើទៅបាន ពង្រីកសមត្ថភាពខាងរាងកាយ និងខាងផ្លូវចិត្តរបស់ពួកគេតាមរយៈការព្យាបាល និងសកម្មភាព ។

នៅក្នុងការធ្វើដូច្នោះ យើងត្រូវនៅក្នុងភាពជាក់ស្ដែង ។ បើយើងតែងតែតានតឹងក្នុងចិត្ត នោះយើងប្រហែលជាប្រឹងជំរុញហួសកម្លាំងពេកហើយ ។ ព្រះអម្ចាស់អាចជួយយើង ហើយដឹកនាំយើងតាមរយៈព្រះវិញ្ញាណរបស់ទ្រង់ ឲ្យធ្វើកិច្ចការទាំងឡាយនោះដែលអាចធ្វើទៅបាន និងដែលសមរម្យ ។ នៅក្នុងករណីខ្លះ ទ្រង់នឹងប្រទានអព្ភូតហេតុដល់យើង ទោះជាវាហាក់ដូចជាតូចក្ដី ។

យើងនឹងតែងតែចងចាំពីអ្វីដែលអ្នកជំនាញផ្នែកឆ្អឹងឈានមុខម្នាក់ប្រាប់យើងថា ដូរ៉ានឹងពុំដែលអាចដើរបានទេ ។ ប៉ុន្តែបន្ទាប់ពីការអធិស្ឋានជាច្រើន និងការខិតខំអស់ជាច្រើនឆ្នាំមក ឥឡូវនេះ ដូរ៉ាអាចដើរបានដោយមានជំនួយ ។ ស្ថានភាពទូទៅរបស់នាងពុំបានផ្លាស់ប្ដូរទេ ប៉ុន្តែព្រះអម្ចាស់បានប្រទានអព្ភូតហេតុតូចមួយដល់យើងដើម្បីជួយនាងឲ្យលូតលាស់ និងស្វែងរកភាពរីករាយបន្ថែមទៀតនៅក្នុងជីវិត ។

## សេចក្ដីជំនឿទោះមិនបានព្យាបាល

វាជារឿងធម្មតាដើម្បីសួរថា *ហេតុអ្វី* ? ពេលដែលបុត្រដ៏មានតម្លៃដែលមានឧបសគ្គរបស់ព្រះម្នាក់ត្រូវបានបញ្ជូនមកផ្ទះរបស់យើង ។ សេចក្ដីជំនឿរបស់យើងដឹកនាំយើងដោយឯកឯងឲ្យសួរដល់ព្រះ ថាតើវាអាចទៅរួចទេដើម្បីព្យាបាល ឬដកចេញនូវស្ថានភាពរបស់កូននោះ ។ យើងមានសេចក្ដីជំនឿយ៉ាងប្រាកដថា ព្រះអាចព្យាបាលកូនស្រីយើងបាន ប៉ុន្តែទ្រង់ក៏បានបង្ហាញយ៉ាងច្បាស់ថា វាមិនមែនជាព្រះទ័យរបស់ទ្រង់ដើម្បីធ្វើដូច្នោះនៅឥឡូវនេះទេ ។

យើងដែលជាអ្នកថែទាំមានទំនួលខុសត្រូវដើម្បីជួយដល់ពួកអ្នកដែលនៅក្រោមការថែទាំរបស់យើងឲ្យលូតលាស់ និងរីកចម្រើនឡើងខាងរាងកាយ ខាងផ្លូវអារម្មណ៍ និងខាងវិញ្ញាណឲ្យដល់កម្រិតមួយដែលពួកគេអាចធ្វើទៅបាន ។

ព្រះវរបិតាសួគ៌មានព្រះរាជបំណងផ្ទាល់របស់ទ្រង់ដែលបានបញ្ជូនដូរ៉ាមកយើង ហើយទ្រង់នឹងព្យាបាលនាង—ប្រសិនបើ ហើយនៅពេលដែលទ្រង់នឹងធ្វើដូច្នោះ ។ ថ្ងៃនោះអាចនឹងមិនកើតរហូតដល់ពេលនៃការព្យាបាលចុងក្រោយបំផុត—ការរស់ឡើងវិញ ។ វាត្រូវការសេចក្ដីជំនឿច្រើនដូចគ្នា ដើម្បីទទួលយកព្រះឆន្ទៈរបស់ព្រះថា កូនៗដ៏មានតម្លៃទាំងនេះពុំទទួលបានការព្យាបាលឥឡូវនេះ ទៅនឹងការជឿថា ទ្រង់អាចព្យាបាលពួកគេឥឡូវនេះ ។ ដូរ៉ាត្រូវបានបញ្ជូនមកយើងជាមួយនឹងគោលបំណងមួយ ហើយយើងបានទទួលការរំឭកមិនឲ្យស្វែងរកថា*ហេតុអ្វី* ប៉ុន្តែឲ្យសួរដល់ព្រះវរបិតាសួគ៌ថា *អ្វី* ដែលទ្រង់មានព្រះទ័យចង់ឲ្យយើងរៀន ។

អែលឌើរ រីឆាដ ជី ស្កុត ( ១៩២៨–២០១៥ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ថា « ដើម្បីសួរថា ហេតុអ្វីរឿងនេះត្រូវកើតឡើងចំពោះខ្ញុំ ? ហេតុអ្វីខ្ញុំត្រូវរងទុក្ខចំពោះបញ្ហានេះ នៅពេលនេះ ? តើខ្ញុំបានធ្វើអ្វីបានជាវាកើតឡើង ? នឹងនាំអ្នកទៅកាន់ជ្រលងដ៏ងងឹត » ។ លោកបាននិយាយថា ផ្ទុយទៅវិញ « សួរថា តើខ្ញុំត្រូវធ្វើអ្វី ? តើខ្ញុំត្រូវរៀនអ្វីខ្លះចេញមកពីបទពិសោធន៍នេះ ? . . . ពេលអ្នកអធិស្ឋានដោយភាពជឿជាក់យ៉ាងប្រាកដថា ‹ សូមឲ្យកូនបានដឹងពីព្រះឆន្ទៈរបស់ទ្រង់ › និង ‹ សូមតាមព្រះហឫទ័យទ្រង់ចុះ › នោះអ្នកស្ថិតនៅក្នុងជំហរដ៏រឹងមាំបំផុតដើម្បីទទួលជំនួយធំធេងបំផុតពីព្រះវរបិតាសួគ៌របស់អ្នកហើយ » ។[2]

ពេលខ្លះ យើងគិតពីឪពុកម្ដាយរបស់កូនៗទាំងនោះ ដែលព្រះអង្គសង្គ្រោះបានព្យាបាលអំឡុងការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ ។ ប្រហែលជាដូចយើងដែរ ឪពុកម្ដាយទាំងនោះឆ្ងល់ថាតើអ្វីជាគោលបំណងដែលកូនៗរបស់ពួកគេត្រូវបានបញ្ជូនមកពួកគេនោះ ។ បន្ទាប់ពីព្រះអង្គសង្គ្រោះបានព្យាបាលពួកគេហើយ ឪពុកម្ដាយទាំងនោះអាចយល់ថា វាពុំអាចទៅរួចទេដែលទ្រង់បង្ហាញពីអំណាច និងទេវភាពនៃការព្យាបាលរបស់ទ្រង់នោះ បើពុំមាននរណាម្នាក់ឈឺ ហើយត្រូវការការព្យាបាលនោះ ។ យើងមានសេចក្ដីជំនឿថា ពេលវេលានៃការព្យាបាលនឹងមកដល់បុត្រាបុត្រីគ្រប់រូបរបស់ព្រះ ។[3]

យើងទន្ទឹងរង់ចាំថ្ងៃនោះ ។ ■

**កំណត់ចំណាំ**

១. ព្យាការី យ៉ូសែប ស្ម៊ីធ បាន បង្រៀន ថា « គ្រប់ទាំងគំនិត និងវិញ្ញាណដែលព្រះធ្លាប់បានបញ្ជូនមកក្នុងពិភពលោកនេះ គឺងាយនឹងពង្រីកបាន » ( *Teachings of Presidents of the Church: Joseph Smith* [ ២០០៧ ] ទំព័រ ២១០ ) ។
២. រីឆាដ ជី ស្កុត « Trust in the Lord » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ទំព័រ ១៧ ។
៣. សម្រាប់ការយល់ដឹងពីការមាន « សេចក្ដីជំនឿទោះមិនបានព្យាបាល » សូមមើល ដេវីឌ អេ បែដណា « Accepting the Lord's Will and Timing » *Liahona* ខែ សីហា ឆ្នាំ ២០១៦ ទំព័រ ១៦–២៣ ។

# ពាក្យសម្ដីរបស់ព្យាការីសម្រាប់មនុស្សគ្រប់រូប

*ខ្ញុំមិនបានរំពឹងថានឹងឃើញការដកស្រង់មួយពីព្យាការីម្នាក់របស់ព្រះនៅលើជញ្ជាំងសាលារៀននោះទេ ។*

ខ្ញុំបានភ្ញាក់ពីព្រលឹមនៅព្រឹកមួយដើម្បីរៀបចំខ្លួនទៅធ្វើការ ។ ទោះជានិច្ចកាលខ្ញុំស្រឡាញ់ការងារខ្ញុំជាគ្រូបង្រៀន ក៏ជួនកាលខ្ញុំមិនសប្បាយចិត្តទេ ហើយចង់តែលូនចូលក្រោមភួយវិញ ហើយធ្វើពុតថាវាដល់ពេលគេងម្ដងទៀតហើយ ។

ពេលខ្ញុំមកដល់វិទ្យាល័យ ខ្ញុំបានព្យាយាមត្រៀមគំនិតជាស្រេចដើម្បីធ្វើការ ។ ខ្ញុំបានដឹងថា ខ្ញុំត្រូវបង្រៀនថ្នាក់គណិតវិទ្យាបន្តិចទៀតនេះ ប៉ុន្តែដួងចិត្ត និងខួរក្បាលខ្ញុំស្ពឹកអស់ ហើយធ្លាក់ទឹកចិត្ត ។ ខ្ញុំមានអារម្មណ៍អវិជ្ជមាន ។

ខ្ញុំបានសម្រេចចិត្តទៅបន្ទប់ទឹកមុនទៅថ្នាក់រៀន ។ យូរៗម្ដង មាននរណាម្នាក់បិតក្រដាសប្រកាសនៅក្នុងបន្ទប់ទឹកដែលមានព័ត៌មានសម្រាប់សិស្ស និងបុគ្គលិក ។ មានបណ្ណប្រកាសមួយទាក់ទាញកន្ទុយភ្នែកខ្ញុំ ។ វាមានការដកស្រង់ដ៏ល្អមួយដែលអានថា « ប្រសិនបើអ្នកចង់ផ្ដល់ពន្លឺទៅអ្នកដទៃទៀត អ្នកត្រូវតែបញ្ចេញពន្លឺខ្លួនឯង » ។[១] ខ្ញុំភ្ញាក់ផ្អើលដែលឃើញថា ការដកស្រង់នេះគឺមកពីប្រធាន ថូម៉ាស អេស ម៉នសុន ( ១៩២៧–២០១៨ ) ។

ខ្ញុំមិនរំពឹងថានឹងឃើញការដកស្រង់មួយពីព្យាការីម្នាក់របស់ព្រះនៅលើជញ្ជាំងសាលារៀននោះទេ ។ ខ្ញុំរស់នៅក្រុងតូចមួយនៅរដ្ឋផែនសីលវេញ៉ា ស.រ.អា. ហើយខ្ញុំប្រាកដណាស់ថា ខ្ញុំជាមនុស្សម្នាក់ក្នុងចំណោមពីរបីនាក់ ឬប្រហែលជាតែម្នាក់ប៉ុណ្ណោះ ដែលជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ នៅក្នុងសាលានេះ ។ ខ្ញុំបានដឹងថា ខ្ញុំជាមនុស្សម្នាក់ក្នុងចំណោមមនុស្សពីរបីនាក់ដែលយល់ពីសារសំខាន់នៃពាក្យសម្ដីរបស់ប្រធាន ម៉នសុន—ជាបុរសម្នាក់ដែលខ្ញុំបានគាំទ្រអស់ជាច្រើនឆ្នាំជាព្យាការីម្នាក់ ។ ខ្ញុំបានមានអារម្មណ៍ថា សារនេះគឺសម្រាប់ខ្ញុំ ។ វាបន្ទន់ចិត្តខ្ញុំ ហើយលើកស្ទួយអារម្មណ៍ខ្ញុំ ។ ការដឹងគុណចំពោះទីបន្ទាល់របស់ខ្ញុំបានបំពេញដួងចិត្តខ្ញុំ ហើយសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌បានហ៊ុំព័ទ្ធខ្ញុំ ។

ខ្ញុំចង់ទាញយកបណ្ណនោះពីជញ្ជាំង ហើយទុកវានៅក្នុងហោប៉ៅខ្ញុំពេញមួយថ្ងៃដើម្បីលើកទឹកចិត្តខ្ញុំ ប៉ុន្តែខ្ញុំបានដឹងអ្វីមួយមួយរំពេច ។ ប្រធាន ម៉នសុន មិនគ្រាន់តែជាព្យាការីសម្រាប់ខ្ញុំ និងសមាជិកផ្សេងទៀតនៃសាសនាចក្រនោះទេ—លោកជាព្យាការីសម្រាប់ពិភពលោកនេះ ។ ពាក្យសម្ដីរបស់លោក ដូចជាពាក្យសម្ដីរបស់ប្រធាន រ័សុល អិម ណិលសុន នៅសព្វថ្ងៃនេះ គឺសម្រាប់មនុស្សគ្រប់គ្នា ។ ពាក្យសម្ដីរបស់ព្យាការីជួយ និងលើកទឹកចិត្តដល់*មនុស្សទាំងអស់*ណាដែលស្ដាប់ ។ ខ្ញុំថតរូបនៃការដកស្រង់នោះជាមួយនឹងទូរសព្ទខ្ញុំ ហើយបានទុកបណ្ណប្រកាសនោះសម្រាប់គ្រប់គ្នាផ្សេងទៀតដែលត្រូវការវា ។

ខ្ញុំមានអំណរគុណចំពោះព្រះវរបិតាសួគ៌ ដែលបានដាក់សារនេះនៅតាមផ្លូវខ្ញុំ ។ ខ្ញុំចង់ផ្ដល់ពន្លឺដល់មនុស្សដទៃទៀត ។ តាមរយៈការគោរពប្រតិបត្តិ និងភាពជិតស្និតនឹងព្រះអង្គសង្គ្រោះយើង ខ្ញុំអាចបញ្ចេញពន្លឺ សូម្បីតែនៅថ្ងៃដែលភាពងងឹតធ្វើឲ្យខ្ញុំវង្វេងផ្លូវ ។ ■

**យេធើរីន ហ្វើជេសុន រដ្ឋផែនសីលវេញ៉ា ស.រ.អា.**



**កំណត់ចំណាំ**
១. ថូម៉ាស អេស ម៉នសុន « For I Was Blind, but Now I See » *Liahona* ខែ ឧសភា ឆ្នាំ ១៩៩៩ ទំព័រ ៦៩ ។

រចនារូបភាពដោយ មើរីលី លីដជៀន

# « ខ្ញុំនឹងពុំបដិសេធសេចក្ដីជំនឿរបស់ខ្ញុំឡើយ »

*ខ្ញុំបានក្លាយជាវត្ថុសម្រាប់ការចំអក និងមើលងាយនៅកន្លែងធ្វើការ ។ ហេតុអ្វីខ្ញុំបន្តធ្វើការងារដែលបានក្លាយជាគ្រោះថ្នាក់មួយដល់សុខុមាលភាពខាងវិញ្ញាណរបស់ខ្ញុំ ?*



មិនយូរបន្ទាប់ពីខ្ញុំត្រូវបានគេទទួលឲ្យធ្វើការជាជំនួយការនាយកនៃបណ្ណាល័យដ៏ធំមួយ ក្រុមរបស់ខ្ញុំ និងខ្ញុំ បានចាប់ផ្ដើមគម្រោងដ៏មានមហិច្ឆតាមួយ ដើម្បីបញ្ចូលសៀវភៅ ៣៧០០០ ក្បាលទៅជាឌីជីថល ។ ថ្ងៃមួយអ្នកគ្រប់គ្រងរបស់ខ្ញុំបានហៅខ្ញុំឲ្យចូលទៅក្នុងការិយាល័យគាត់ ។

គាត់បាននិយាយថា « អេឌូដ ខ្ញុំត្រូវបានគេអញ្ជើញឲ្យធ្វើបទបង្ហាញពីគម្រោងធ្វើសៀវភៅឌីជីថលរបស់យើងនៅសហរដ្ឋ និងដើម្បីរៃអង្គាសធនធានជាសៀវភៅថ្មីៗខ្លះទៀត ។ ខ្ញុំត្រូវបានស្នើឲ្យនាំមិត្តរួមការងារដ៏ទុកចិត្តម្នាក់ទៅជាមួយ ។ ខ្ញុំមានទំនុកចិត្តលើអ្នក ប៉ុន្តែមិនទុកចិត្តលើព្រះវិហាររបស់អ្នកទេ ។ ប្រសិនបើអ្នកបោះបង់ចោលជំនឿរបស់អ្នក នោះអ្នកអាចមកជាមួយខ្ញុំបាន » ។

ខ្ញុំមិនទាន់បាននិយាយអ្វីផង គាត់ក៏ប្រាប់ខ្ញុំឲ្យគិតមើលពីវា ហើយក៏បានឲ្យខ្ញុំចេញទៅ ។

នៅល្ងាចនោះ ខ្ញុំបានចែកចាយវាជាមួយភរិយាខ្ញុំពីអ្វីដែលបានកើតឡើង ។ គាត់បានលើកទឹកចិត្តខ្ញុំឲ្យមានសេចក្ដីជំនឿ ។ ស្អែកឡើង ខ្ញុំបានប្រាប់អ្នកគ្រប់គ្រងរបស់ខ្ញុំថា ខ្ញុំនឹងរក្សាសេចក្ដីជំនឿរបស់ខ្ញុំ ។ គាត់ខឹង ហើយបាននិយាយថា គាត់នឹងធ្វើដំណើរតែម្នាក់ឯង ។

មួយឆ្នាំក្រោយមក ខ្ញុំបានមានឱកាសដើម្បីធ្វើដំណើរទៅប្រទេសបារាំងដើម្បីទទួលការហ្វឹកហ្វឺនស្ដីអំពីការផ្ដល់មូលនិធិ ការទទួល និងការគ្រប់គ្រងបណ្ណាល័យ ។ ខ្ញុំគ្រាន់តែត្រូវការការអនុញ្ញាតរបស់អ្នកគ្រប់គ្រងរបស់ខ្ញុំប៉ុណ្ណោះ ។ គាត់បាននិយាយថាគាត់នឹងអនុញ្ញាតបើខ្ញុំព្រមដកខ្លួនពីជំនឿរបស់ខ្ញុំ ។ ខ្ញុំបានបដិសេធម្ដងទៀត ។ បន្ទាប់មកគាត់បានហែកឯកសារនោះ ហើយបោះវាលើមុខខ្ញុំ ។ មួយរយៈក្រោយមកទៀត អ្នកគ្រប់គ្រងរបស់ខ្ញុំបានមករកខ្ញុំម្ដងទៀត ។

គាត់បាននិយាយថា « ខ្ញុំរៀបនឹងធ្វើដំណើរមួយផ្សេងទៀត » ។ « អ្នកអាចមកជាមួយខ្ញុំ តែលក្ខខណ្ឌគឺនៅដដែល ។ ខ្ញុំនឹងមិនធ្វើដំណើរជាមួយសមាជិកម្នាក់នៃព្រះវិហាររបស់អ្នកឡើយ » ។

ខ្ញុំបាននិយាយថា « ខ្ញុំនឹងពុំបដិសេធសេចក្ដីជំនឿរបស់ខ្ញុំឡើយ » ។ គាត់បានចាកចេញដោយមិននិយាយអ្វីមួយមាត់ ។ មិនយូរប៉ុន្មាន គាត់បាននិយាយពីខ្ញុំទៅកាន់មិត្តរួមការងាររបស់ខ្ញុំ ។

គាត់បាននិយាយថា « ខ្ញុំបានផ្ដល់ឱកាសដល់គាត់ » ។ « ប៉ុន្តែគាត់បានបោះបង់ឱកាសទាំងអស់នោះ ដោយសារសេចក្ដីជំនឿដ៏ងងឹងងងុលរបស់គាត់ ។ គាត់គឺជាមនុស្សល្ងង់ » ។

ចាប់តាំងពីនោះមក ខ្ញុំបានក្លាយជាវត្ថុសម្រាប់ការចំអក និងមើលងាយនៅកន្លែងធ្វើការ ។ ខ្ញុំបានមានអារម្មណ៍ថាត្រូវគេវាយបំបាក់ ។ នាល្ងាចមួយ ដោយបានខ្វល់ខ្វាយជាមួយបញ្ហានេះទៅហើយ នោះខ្ញុំបានបើកព្រះគម្ពីរប៊ីប ហើយអានថា « បើភ្នែកស្ដាំអ្នកនាំឲ្យរវាតចិត្ត នោះចូរខ្វេះចេញបោះចោលទៅ ដ្បិតដែលភ្នែកអ្នក១ត្រូវវិនាស នោះមានប្រយោជន៍ជាជាងឲ្យរូបកាយទាំងមូល ត្រូវបោះទៅក្នុងនរក » ( ម៉ាថាយ ៥:២៩ ) ។

បើព្រះអម្ចាស់មានព្រះបន្ទូលថា យើងគួរតែដកចេញនូវអ្វីមួយដើម្បីសង្គ្រោះខ្លួនយើង ចុះហេតុអ្វីខ្ញុំបន្តធ្វើការងារដែលបានក្លាយជាគ្រោះថ្នាក់មួយដល់សុខុមាលភាពខាងវិញ្ញាណរបស់ខ្ញុំ ? ស្អែកឡើង ខ្ញុំបានដាក់ពាក្យសុំឈប់របស់ខ្ញុំ ។

ថ្ងៃនេះ ខ្ញុំរីករាយនឹងជម្រើសនេះ ។ ជាមួយនឹងសេចក្ដីក្លាហាន និងសេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ នោះខ្ញុំបានប្រឈមនឹងភាពអាម៉ាសនៅកន្លែងការងារ ហើយអត់ការងារធ្វើជាបណ្ដោះអាសន្ន ។ ការងារថ្មីរបស់ខ្ញុំឥឡូវនេះផ្ដល់ឱកាសទាំងឡាយដល់ខ្ញុំ ដែលពុំមានពីមុនមក ។ ព្រះអម្ចាស់បានប្រទានពរដល់ខ្ញុំ ហើយខ្ញុំអរព្រះគុណទ្រង់សម្រាប់ព្រះសណ្ដោសរបស់ទ្រង់ និងសេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះខ្ញុំ ។ ■

**អេឌូដ ងិនឌូ ទីក្រុងកាតូកា សាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ**

រចនារូបភាពដោយ ក្រេហ្គ ស្ទីនសុន

# យើងត្រូវការអព្ភូតហេតុទីពីរ

*យើងបានមានអព្ភូតហេតុមួយរួចមកហើយជាមួយនឹងការមានផ្ទៃពោះរបស់ភរិយាខ្ញុំ ។ ឥឡូវនេះយើងត្រូវការអព្ភូតហេតុមួយទៀត ។*

ភរិយាខ្ញុំ សារ៉ាមានផ្ទៃពោះ ២៤ សប្ដាហ៍ពេលនាងបានចាប់ផ្ដើមមានការឈឺចាប់ជាខ្លាំង ។ ខ្ញុំបានផ្ដល់ការប្រសិទ្ធិពរមួយដល់នាង ហើយបានចេញទៅធ្វើការ ។ ខ្ញុំនៅកន្លែងធ្វើការនៅឡើយ ពេលនាងបានទូរសព្ទឲ្យខ្ញុំទៅផ្ទះដើម្បីយកនាងទៅមន្ទីរពេទ្យ ។

យើងត្រូវបានប្រាប់ថា « កូនអ្នកនឹងសម្រាលមកហើយ » នៅពេលយើងមកដល់មន្ទីរពេទ្យ ។ ដោយសារសារ៉ាទើបតែមានទម្ងន់ ២៤ សប្ដាហ៍ នោះឱកាសដ៏ល្អបំផុតដើម្បីឲ្យកូននៅរស់គឺការវះកាត់ជាបន្ទាន់ ។

វេជ្ជបណ្ឌិតបានប្រាប់ខ្ញុំថា « ភរិយារបស់អ្នកមិនត្រូវការឆ្លងកាត់ការប៉ះទង្គិចផ្លូវចិត្តបន្ថែមទៀតទេ » ។ « នាងគង់តែនឹងបាត់បង់កូននេះដដែលហ្នឹង » ។

សារ៉ា និងខ្ញុំបាននិយាយគ្នា ហើយបានអធិស្ឋានអំពីអ្វីដែលវេជ្ជបណ្ឌិតបានប្រាប់ ។ យើងបានទទួលអារម្មណ៍ថា បើមានឱកាសណាមួយដែលកូនយើងអាចបានរស់ នោះយើងត្រូវតែទាញយកឱកាសនោះ ។ យើងមានការលំបាកណាស់ដើម្បីមានកូន ។ កូនប្រុសច្បងរបស់យើង ថេល័រ គឺជាកូនដែលយើងសុំមកចិញ្ចឹម ។ នៅពេលសារ៉ាបានមានផ្ទៃពោះ ពីរឆ្នាំក្រោយពីយើងបានសុំថេល័រមកចិញ្ចឹម យើងបានមានអារម្មណ៍ថាវាជាអព្ភូតហេតុមួយ ។ ឥឡូវនេះ យើងត្រូវការអព្ភូតហេតុទីពីរ ។

មួយសន្ទុះក្រោយមក អ្នកជំនាញម្នាក់បានមកជួបយើង ហើយនិយាយថា « ខ្ញុំគិតថា យើងអាចនឹងមានពេលដើម្បីនាំភរិយាលោកទៅកាន់មន្ទីរពេទ្យកុមារនៅទីក្រុងអិលផាសូ រដ្ឋតិចសាស ដែលមានបំពាក់ដោយបរិក្ខារវេជ្ជសាស្ត្រដើម្បីថែទាំកូនដែលទើបនឹងកើតដែលកើតមុនកំណត់ ហើយឈឺធ្ងន់ធ្ងរ ។ កូននេះនឹងមានឱកាសមួយនៅទីនោះ ! »

រថយន្តសង្គ្រោះបន្ទាន់បានបើកចេញពីមន្ទីរពេទ្យក្នុងតំបន់របស់យើងដោយមានសារ៉ានៅក្នុងនោះ ហើយបើកយ៉ាងលឿនទៅកាន់មន្ទីរពេទ្យកុមារដែលនៅចម្ងាយ ៤៥ នាទីពីនោះ ។ ខ្ញុំបើកតាមប្រកៀកពីក្រោយ ដោយអធិស្ឋានទូលអង្វរដល់ព្រះអម្ចាស់សូមប្រទានអព្ភូតហេតុមួយដល់យើង ។ ខ្ញុំបានសន្យានឹងទ្រង់ថា ខ្ញុំនឹងបន្តដើរនៅលើផ្លូវនៃដំណឹងល្អ ហើយព្យាយាមក្លាយជាមនុស្សល្អប្រសើរជាងនេះ ។

នៅឯមន្ទីរពេទ្យ ខ្ញុំបានប្រាប់វេជ្ជបណ្ឌិតនៅក្នុងផ្នែកថែទាំកម្រិតខ្ពស់ដល់ទារកទើបនឹងកើតថា ៖ « ខ្ញុំដឹងថា យើងមានអព្ភូតហេតុមួយរួចហើយជាមួយនឹងការមានផ្ទៃពោះរបស់ភរិយាខ្ញុំ ។ ឥឡូវនេះយើងរំពឹងថាបានអព្ភូតហេតុមួយទៀត » ។

ការសម្រាលប្រព្រឹត្តិទៅយ៉ាងរលូន ហើយកូនរបស់យើងបានរស់ ។ បន្ទាប់ពីនាងបានស្នាក់នៅក្នុងផ្នែកថែទាំកម្រិតខ្ពស់ដល់ទារកទើបនឹងកើតអស់បួនខែ យើងបាននាំស្ពានណាមកផ្ទះ ។ យើង*បាន*ទទួលអព្ភូតហេតុទីពីរ ។ មិនជាច្រើនឆ្នាំក្រោយមកទៀត យើងបានទទួលអព្ភូតហេតុមួយទៀត—ព្រះអម្ចាស់បានប្រទានពរដល់យើងជាមួយនឹងកូនភ្លោះ ។

ស្ពានណាមាន IQ ទាបបន្តិច ហើយនាងត្រូវនៅក្នុងរទេះរុញ ប៉ុន្តែនាងពោរពេញដោយអំណរ តែងតែវិជ្ជមាន ហើយជាមិត្តដល់មនុស្សគ្នា ។ នាងចូលចិត្តប្រាប់អ្នកពីថ្ងៃរបស់នាង ហើយនាងរំភើបនឹងជីវិត ។ នាងធ្វើឲ្យយើងញញឹម ហើយបង្រៀនយើងឲ្យរីករាយ ។ យើងស្រឡាញ់នាង ហើយមានអំណរគុណចំពោះនាង ។ ស្ពានណាគឺពិតជាពរជ័យមួយ ។ ■

**ដានីយ៉ែល ផេន ទីក្រុងនូវម៉ិកស៊ីកូ ស.រ.អ.**



រចនារូបភាពដោយ ប្រេដលី ខ្លាក



# ពិធីសម្ពោធបើកព្រះវិហារបរិសុទ្ធបានបើកដួងចិត្តខ្ញុំ

*ជាមួយនឹងការប្រកាសពីពិធីសម្ពោធបើកព្រះវិហារបរិសុទ្ធ ខ្ញុំបានមានអារម្មណ៍ថា ព្រះអម្ចាស់បានអញ្ជើញខ្ញុំដោយផ្ទាល់ទៅកាន់ព្រះដំណាក់របស់ទ្រង់ ។*

ខ្ញុំបានជ្រមុជទឹក កាលខ្ញុំមានអាយុ ១៥ ឆ្នាំ ។ មនុស្សជាច្រើនពុំយល់ពីជំនឿថ្មីរបស់ខ្ញុំនោះទេ ។ មនុស្សខ្លះ រួមទាំងមិត្តភក្តិខ្ញុំ ថែមទាំងបានចំអកដល់ខ្ញុំ ដោយសារការសម្រេចចិត្តរបស់ខ្ញុំដើម្បីចូលព្រះវិហារ ។ ឪពុកម្តាយខ្ញុំពុំមែនជាសមាជិកព្រះវិហារទេ ដូច្នេះខ្ញុំពុំមានការគាំទ្ររបស់ពួកគាត់ឡើយ ។

ជាលទ្ធផល វាបានក្លាយជាការលំបាកសម្រាប់ខ្ញុំដើម្បីបន្តទៅព្រះវិហារ និងបន្តរស់នៅក្នុងដំណឹងល្អ ។ ពេលខ្ញុំបានឈានដល់វ័យ ១៩ ឆ្នាំ ខ្ញុំបានឈប់ទៅព្រះវិហារតែម្តង ។

ដប់ឆ្នាំក្រោយមក ខ្ញុំបានឮថា ព្រះវិហារបរិសុទ្ធមួយនឹងត្រូវបានសង់ឡើងនៅក្នុងប្រទេសអែលសាវ៉ាឌ័រ ។ ខ្ញុំមានការភ្ញាក់ផ្អើលដែលឮថា ព្រះដំណាក់នៃព្រះអម្ចាស់នឹងត្រូវសង់ឡើងនៅក្នុងប្រទេសរបស់ខ្ញុំ ! បួនឆ្នាំក្រោយមក ព្រះវិហារបរិសុទ្ធសានសាវ៉ាឌ័រ អែលសាវ៉ាឌ័រ ត្រូវបានបញ្ចប់ ហើយពិធីសម្ពោធបើកព្រះវិហារបរិសុទ្ធត្រូវបានប្រកាស ។ នៅពេលខ្ញុំបានដឹងថា ការសម្ពោធបើកព្រះវិហារបរិសុទ្ធនឹងផ្តល់ឱកាសដល់ខ្ញុំឲ្យបានចូលព្រះវិហារបរិសុទ្ធ ខ្ញុំបានមានអារម្មណ៍ហាក់ដូចជា ព្រះអម្ចាស់បានអញ្ជើញខ្ញុំដោយផ្ទាល់ទៅកាន់ព្រះដំណាក់របស់ទ្រង់ ។

ថ្ងៃដែលខ្ញុំបានដើរកាត់ក្នុងព្រះវិហារបរិសុទ្ធគឺជាថ្ងៃដ៏ល្អបំផុតមួយក្នុងជីវិតរបស់ខ្ញុំ ។ អំឡុងពិធីសម្ពោធបើក ខ្ញុំបានរៀនបន្ថែមទៀតអំពីអ្វីដែលកើតឡើងនៅខាងក្នុងព្រះវិហារបរិសុទ្ធដែលបានឧទ្ទិសឆ្លងហើយ ។ ខ្ញុំក៏បានរៀនផងដែរអំពីសេចក្តីសញ្ញាពិសិដ្ឋនៅក្នុងព្រះវិហារបរិសុទ្ធដែលបុគ្គលទាំងឡាយធ្វើជាមួយនឹងព្រះ ។

ពេលខ្ញុំដើរកាត់ក្នុងបន្ទប់នីមួយៗក្នុងព្រះវិហារបរិសុទ្ធ ខ្ញុំទទួលអារម្មណ៍នៃវត្តមានរបស់ព្រះ ។ ខ្ញុំមានអារម្មណ៍សុខសាន្ត ។ ការទៅទស្សនាព្រះវិហារបរិសុទ្ធផ្តល់ដល់ខ្ញុំនូវបំណងប្រាថ្នាដើម្បីត្រឡប់ទៅព្រះវិហារវិញ ហើយរស់នៅតាមដំណឹងល្អម្តងទៀត ។ ពេលខ្ញុំបានដឹងថា ខ្ញុំអាចរួមចំណែកក្នុងកិច្ចការដ៏អស្ចារ្យរបស់ព្រះ ខ្ញុំចង់ធ្វើកិច្ចការព្រះវិហារបរិសុទ្ធសម្រាប់បុព្វការីជនរបស់ខ្ញុំ ហើយអនុវត្តបព្វជិតភាព ។

បទពិសោធន៍នៅក្នុងព្រះវិហារបរិសុទ្ធរបស់ខ្ញុំនៅថ្ងៃនោះ បានផ្លាស់ប្តូរខ្ញុំ ។ ឥឡូវនេះ ខ្ញុំជួយដល់សមាជិកក្នុងវួដខ្ញុំរៀបចំសម្រាប់ព្រះវិហារបរិសុទ្ធ ហើយជួយពួកគេជាមួយនឹងពង្សប្រវត្តិ ដើម្បីពួកគេអាចធ្វើកិច្ចការព្រះវិហារបរិសុទ្ធសម្រាប់បុព្វការីជនរបស់ពួកគេ ។

វាមិនដែលយឺតពេលទេដើម្បីវិលត្រឡប់មកកាន់ព្រះវិហារវិញនោះ ។ វាមិនដែលយឺតពេលទេដើម្បីធ្វើការល្អនោះ ។ ជាមួយនឹងសេចក្តីស្រឡាញ់ដ៏ឥតព្រំដែនរបស់ទ្រង់ ព្រះអម្ចាស់តែងតែគង់ជាមួយយើង ។ ព្រះវិហារបរិសុទ្ធជាកន្លែងដែលបង្រួបបង្រួមយើងជាមួយទ្រង់ ហើយអនុញ្ញាតឲ្យយើងត្រឡប់ទៅរស់នៅជាមួយទ្រង់វិញនៅថ្ងៃមួយ ។ ■

**រីការដូ ម៉ាថាម៉្រូស ទីក្រុងអាហ៊ូឆាផេន ប្រទេសអែលសាវ៉ាឌ័រ**

# អំណោយនៃសេចក្ដីស្រឡាញ់

ដោយ ហ្វេស អេស វ៉ាត់សុន

*ពេលស្វាមីខ្ញុំបានប្រសិទ្ធពរដល់កូនស្រីតូចរបស់យើង ខ្ញុំបានចាប់ផ្ដើមក្រឡេកមើលពីជម្រៅ និងទំហំនៃអំណោយនៃសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌—គឺបព្វជិតភាព ។*

ខ្ញុំជាសមាជិកថ្មីម្នាក់របស់សាសនាចក្រ ជាភរិយាថ្មី និងជាម្ដាយថ្មីថ្មោង ។ វាជាថ្ងៃអាទិត្យតមអាហារ ហើយកូនស្រីដ៏តូចរបស់យើងត្រៀមនឹងទទួលឈ្មោះ និងពរជ័យមួយ ។ ខ្ញុំមិនដែលបានឃើញការប្រសិទ្ធពរទារកពីមុនមកទេ ដោយសារយើងបានរស់នៅក្នុងវួដមួយដែលមានគ្រួសារវ័យក្មេងតែបន្តិចបន្តួចប៉ុណ្ណោះ ។ ខ្ញុំពុំដឹងថា មានអ្វីត្រូវរំពឹងទុកឡើយ ។ ទោះយ៉ាងណាខ្ញុំបានទទួលអារម្មណ៍ពីព្រះវិញ្ញាណថា នេះជាអ្វីមួយពិសេស និងសំខាន់ខ្លាំងណាស់ ។

ស្វាមីខ្ញុំ ដោយបានចូលរួមពីអ្នកកាន់បព្វជិតភាពដ៏មានគារវភាពផ្សេងទៀត បានទ្រកូនស្រីតូចដ៏មានតម្លៃរបស់យើងដោយប្រុងប្រយ័ត្ន ។ ភាពផ្អែមល្ហែមនៃព្រះវិញ្ញាណបានបំពេញក្នុងចិត្តខ្ញុំ ។ ទឹកភ្នែកបានហូរកាត់ថ្ពាល់ខ្ញុំ ហើយការបំផុសជាច្រើនបានបំពេញក្នុងគំនិតខ្ញុំ ។ ខ្ញុំបានដឹងថា ខ្ញុំគ្រាន់តែបានចាប់ផ្ដើមក្រឡេកមើលឃើញពីជម្រៅ និងទំហំនៃអំណោយដ៏អស្ចារ្យនៃសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ដល់យើង—គឺបព្វជិតភាព ។

ពេលពួកអ្នកផ្សព្វផ្សាយសាសនាបានបង្រៀនខ្ញុំនូវការពិភាក្សាទាំងឡាយ ខ្ញុំបានដឹងថាពួកគេមានអារម្មណ៍ថាមានកិត្តិយសយ៉ាងណាដែលបានកាន់បព្វជិតភាពនោះ ។ ខ្ញុំបានឮវានៅក្នុងពាក្យសម្ដីរបស់ពួកគេ និងនៅក្នុងការអធិស្ឋានរបស់ពួកគេ រួមទាំងពេលដែលពួកគេបានប្រសិទ្ធិពរខ្ញុំឲ្យយកឈ្នះឧបសគ្គជាមួយនឹងច្បាប់ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ។ ខ្ញុំបានដឹងពេលដៃរបស់ពួកគេដែលបានដាក់លើក្បាលខ្ញុំដោយថ្នមៗនោះ ចាប់ផ្ដើមញ័រពេលពួកគេបាននិយាយពាក្យពេចន៍ដែលខ្ញុំដឹងថាមកពីព្រះអម្ចាស់—ជាពាក្យនៃសេចក្ដីស្រឡាញ់ និងនៃការព្យាបាល ។

មិនយូរប៉ុន្មានខ្ញុំបានទទួលបុណ្យជ្រមុជទឹក ហើយដៃរបស់ពួកអ្នកកាន់បព្វជិតភាពបានដាក់លើក្បាលខ្ញុំម្ដងទៀត ។ ខ្ញុំបានទទួលពិធីបញ្ជាក់ជាសមាជិកនៃសាសនាចក្ររបស់ព្រះអម្ចាស់ និងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ត្រូវបានប្រគល់ដល់ខ្ញុំ ។ ខ្ញុំបានស្អាតស្អំ និងបានកើតជាថ្មី ។ ខ្ញុំបានទទួលអារម្មណ៍នៃអំណាចបព្វជិតភាពពេញទាំងរាងកាយខ្ញុំ ហើយជាលើកទីមួយក្នុងជីវិតខ្ញុំ ខ្ញុំបានស្គាល់សេចក្ដីអំណរ ។

មិនយូរបន្ទាប់ពីបុណ្យជ្រមុជទឹករបស់ខ្ញុំ ខ្ញុំ និងស្វាមីខ្ញុំបានរៀបការ ។ ឪពុកម្ដាយគាត់ជាសមាជិកសាសនាចក្រ ហើយផ្ទះគាត់ផ្ដោតទៅលើដំណឹងល្អ ប៉ុន្តែខ្ញុំដឹងថា ទីបន្ទាល់របស់គាត់ពុំបានចាក់ឫសរឹងមាំទេ ។ ទោះយ៉ាងណា ខ្ញុំពុំមានការបារម្ភនោះទេ ។ សេចក្ដីជំនឿក៏ក្មេងខ្ចីរបស់ខ្ញុំធ្វើឲ្យខ្ញុំមានពេញដោយសុទិដ្ឋិនិយម ។ ខ្ញុំនឹងស្រឡាញ់គាត់ ហើយអត់ធ្មត់ និងអធិស្ឋាន ។

អំឡុងពេលដែលខ្ញុំមានផ្ទៃពោះជាមួយនឹងកូនដំបូងរបស់យើង ខ្ញុំមានអារម្មណ៍ដូចជាម្ដាយទាំងឡាយមានដែរ—ជិតដិតយ៉ាងខ្លាំងទៅនឹងកូនក្នុងផ្ទៃ ពោរពេញដោយភាពអស្ចារ្យនឹងជីវិតថ្មីដែលនៅក្នុងពោះខ្ញុំនេះ ។ ពេលកូនស្រីយើងបានកើតមក ចំណងរបស់ខ្ញុំនឹងនាងបានក្លាយជាចំណងនៃសេចក្ដីស្រឡាញ់ រឹងមាំ ហើយផ្អែមល្ហែម ។

ប៉ុន្តែខ្ញុំមានកង្វល់ពីស្វាមីខ្ញុំ ។ គាត់ពុំបានមានពរជ័យនៃភាពជិតស្និតដ៏ខ្លាំងនឹងកូនស្រីយើង ដែលខ្ញុំមាននោះទេ ។ ពិតណាស់គាត់ស្រឡាញ់នាង ប៉ុន្តែខ្ញុំឆ្ងល់ ហើយព្រួយបារម្ភថាបើគាត់ និងនាងនឹងអភិវឌ្ឍនូវចំណងដ៏រឹងមាំមួយដែរឬទេ ។ ខ្ញុំព្រួយចិត្តពេលខ្ញុំចំណាយពេលបំបៅនាង ងូតទឹកឲ្យនាង និងបីនាង ខណៈដែលពេលវេលាច្រើនបំផុតរបស់ស្វាមីខ្ញុំត្រូវបានចំណាយលើការងារដើម្បីផ្គត់ផ្គង់គ្រួសារយើង ។

ឥឡូវនេះ ពីរបីសប្ដាហ៍បន្ទាប់ពីនាងបានកើត យើងនៅក្នុងសាលាជំនុំរបស់យើង ។ អព្ភូតហេតុមួយបានបើកសម្ដែងឡើងនៅពីមុខខ្ញុំ និងនៅក្នុងដួងចិត្តខ្ញុំ ។ ស្វាមីរបស់ខ្ញុំដែលមិនដឹងថាគាត់កំពុងធ្វើអ្វីនោះបានញញឹមដោយការបន្ទាបខ្លួនទៅកាន់បងប្អូនប្រុសរបស់គាត់ដែលនៅក្នុងរង្វង់ ភ្នែកគាត់ពោរពេញដោយពន្លឺ ហើយមានទឹកភ្នែករលីងរលោងផង ។ ជាការតបវិញ បងប្អូនប្រុសទាំងនោះបានផ្ដល់សេចក្ដីស្រឡាញ់ និងការគាំទ្រដល់គាត់ កាលដែលពួកគេបានដាក់ដៃលើស្មា ហើយជួយទ្រកូនរបស់យើង បង្កើតជារង្វង់តូចមួយស្រោចស្រប់នូវសេចក្ដីស្រឡាញ់ដ៏បរិសុទ្ធ និងពិសិដ្ឋ ។ ពេលស្វាមីខ្ញុំបានចាប់ផ្ដើមការប្រសិទ្ធពរ ខ្ញុំបានឮសំឡេងគាត់ញ័រ ហើយខ្ញុំបានដឹងថា គាត់កំពុងទទួលអារម្មណ៍ពីព្រះចេស្ដានៃព្រះ និងកិត្តិយសនៃការកាន់បព្វជិតភាព ។

ខ្ញុំបានដឹងថា គាត់មានអារម្មណ៍នៃសេចក្ដីស្រឡាញ់យ៉ាងអស្ចារ្យចំពោះកូនស្រីតូចរបស់យើង ហើយខ្ញុំបានដឹងថា គាត់បានព្យាយាមយ៉ាងខ្លាំងដើម្បីរៀបចំខ្លួនគាត់ក្នុងការប្រសិទ្ធិពរដល់នឹងនូវពរជ័យដែលព្រះវរបិតាសួគ៌មានព្រះរាជបំណងចង់ប្រទានដល់នាង ។ ខ្ញុំបានពោរពេញដោយអំណរ



រចនារូបភាពដោយ ALE + ALE ម៉ារហ្គេន ហ្គានីន

ពេលខ្ញុំបានដឹងថា ឥឡូវនេះគាត់មានចំណងដ៏រឹងមាំជាមួយកូនស្រីយើង ។ វាជាចំណងមួយដែលមិនដែលទន់ខ្សោយនោះឡើយ ។

ជាច្រើនឆ្នាំបានកន្លងទៅហើយតាំងពីបទពិសោធន៍នោះបានកើតឡើង ។ ខ្ញុំបានធ្វើជាសាក្សី និងទទួលអារម្មណ៍នៃអំណាច និងភាពស្រស់ស្អាតនៃបព្វជិតភាពដែលត្រូវបានអនុវត្តក្នុងរបៀបជាច្រើន ក្នុងទីកន្លែងជាច្រើន និងសម្រាប់បុត្រាបុត្រីជាច្រើនរបស់ព្រះវរបិតាសួគ៌ ។ ខ្ញុំបានមើលឃើញពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះដ៏ស្រស់បំព្រងដែលត្រូវបានប្រគល់ និងបំពេញដួងចិត្ត ។ ខ្ញុំបានសង្កេតឃើញមានការសម្អាត ការព្យាបាល ការលួងលោម និងការបង្រៀន ។ ខ្ញុំបានឃើញ និងទទួលអារម្មណ៍ថា បន្ទុកត្រូវបានធ្វើឲ្យស្រាលឡើង ។

ខ្ញុំដឹងថា ខ្ញុំនៅតែមិនយល់ពីភាពអស្ចារ្យពេញលេញនៃបព្វជិតភាពនោះទេ ប៉ុន្តែគ្រប់ការប្រសិទ្ធិពរទារកដែលខ្ញុំបានឃើញ បានបំពេញដួងចិត្តខ្ញុំជាមួយនឹងភាពស្ងប់ស្ងែងដែលខ្ញុំបានទទួលអារម្មណ៍អំឡុងការប្រសិទ្ធពរកូនដំបូងរបស់ខ្ញុំ ។ ខ្ញុំមានភាពស្ងប់ស្ងែងនឹងសេចក្ដីស្រឡាញ់ដែលព្រះវរបិតាសួគ៌បានបង្ហាញ ដោយការចែកចាយនូវអំណាចរបស់ទ្រង់ជាមួយយើង ហើយខ្ញុំពោរពេញដោយការដឹងគុណរកពាក្យអ្វីមកថ្លែងជាទីបន្ទាល់មិនបានអំពីទ្រង់ ព្រះរាជបុត្រាជាទីស្រឡាញ់របស់ទ្រង់ និងដំណឹងល្អដែលបានស្តារឡើងវិញដ៏ស្រស់បំព្រងរបស់យើង ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា. ។*

# អាលម៉ា ៥–៧

ថ្ងៃទី ១–៧ ខែ មិថុនា

# តើសំណួររបស់អាលម៉ាជួយយើងឲ្យរីកចម្រើនខាងវិញ្ញាណដោយរបៀបណា ?



**តើការបង្រៀនខ្ញុំយ៉ាងណាដែរ ?**

អាលម៉ាបានសួរដល់ប្រជាជននៃសារ៉ាហិមឡា ៣៦ សំណួរ ដើម្បីជួយពួកគេឲ្យធ្វើការវាយតម្លៃលើការរីកចម្រើនខាងវិញ្ញាណរបស់ពួកគេ ។ ប្រធាន អិម រ័សុល បាឡឺដ ប្រធានស្ដីទីក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ថា ការវាយតម្លៃខាងវិញ្ញាណគឺមានប្រយោជន៍ ។ លោកបានមានប្រសាសន៍ថា « ជាការណែនាំដល់ខ្ញុំអំឡុងពេល [ ការវាយតម្លៃ ] នេះ ខ្ញុំចូលចិត្តអាន ហើយពិចារណាអំពីពាក្យពេចន៍ដែលធ្វើឲ្យពិចារណាអំពីខ្លួនឯងដែលមាននៅក្នុងអាលម៉ា ជំពូកទីប្រាំ » ។[1]

**តើខ្ញុំត្រូវផ្លាស់ប្ដូរអ្វីខ្លះ ?**

នៅពេលអ្នកអាន អាលម៉ា ៥:៣–១៣ សូមរកមើលនូវអ្វីដែលអាលម៉ាបានបង្រៀនអំពីរបៀបដែលយើងអាចផ្លាស់ប្ដូរ និងខិតកាន់តែជិតព្រះគ្រីស្ទ ។ សូមពិចារណាថាអ្វីខ្លះដែលអ្នកអាចផ្លាស់ប្ដូរបាន ហើយដាក់ផែនការដើម្បីធ្វើវា ។

**តើព្រះអម្ចាស់បានប្រទានពរដល់ខ្ញុំដោយរបៀបណា ?**

អាលម៉ាក៏បានអញ្ជើញប្រជាជនឲ្យចងចាំពីរបៀបដែលព្រះអម្ចាស់បានដោះលែងបុព្វការីជនរបស់ពួកគេ និងឲ្យពួកគេរំឭកពីការប្រែចិត្តជឿរបស់ពួកគេ ។ សូមពិចារណាពីការសរសេររឿងនៃការប្រែចិត្តជឿរបស់អ្នក ដើម្បីចងចាំពីរបៀបដែលព្រះអម្ចាស់បានប្រទានពរដល់អ្នក ។ អ្នកក៏អាចអានរឿងរ៉ាវនៃការប្រែចិត្តជឿរបស់បុព្វការីជនរបស់អ្នក ឬរបស់សមាជិកសាសនាចក្រពីដើម ។

« វាជាការណ៍ប្រសើរណាស់ បើពួកបរិសុទ្ធគ្រប់គ្នាបានដឹងពីរឿងនៃការប្រែចិត្តជឿរបស់ដូនតាគេ ។ . . . យើងម្នាក់ៗនឹងមានពរជ័យយ៉ាងមហិមា បើយើងដឹងពីរឿងនៃសេចក្ដីជំនឿ និង ការលះបង់ ដែលនាំឲ្យដូនតាយើងចូលរួមក្នុងសាសនាចក្ររបស់ព្រះអម្ចាស់ » ។[2]

**កំណត់ចំណាំ**

១. អិម រ៉ាសុល បាឡឺត « Return and Receive » *Liahona* ខែ ឧសភា ឆ្នាំ ២០១៧ ទំព័រ ៦៤ ។

២. វីល្លាម អរ វ៉កឃើរ « Live True to the Faith » *Liahona* ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ៩៧, ៩៩ ។

រចនារូបភាពដោយ ខារ៉ូលីន វីបប៊ើត

អាលម៉ា ៨–១២
ថ្ងៃទី ៨–១៤ ខែ មិថុនា

# តើការអភិវឌ្ឍឲ្យមានដួងចិត្តទន់ភ្លន់ ជួយយើងទទួលបានការចេះដឹងខាងវិញ្ញាណដោយរបៀបណា ?

ពេលអាលម៉ាប្រកាសដំណឹងល្អនៅទីក្រុងអាំម៉ូណៃហា ប្រជាជនភាគច្រើនបានបដិសេធលោក ប៉ុន្តែអាមូលេកបានស្ដាប់ ហើយបានជឿ ។ ភាពខុសគ្នារវាងអាមូលេក និងប្រជាជនផ្សេងទៀតនៅទីក្រុងអាំម៉ូណៃហា បង្ហាញយើងពីលទ្ធផលនៃការមានដួងចិត្តទន់ភ្លន់ ឬដួងចិត្តរឹងរូស ចំពោះការណ៍ទាំងឡាយរបស់ព្រះ ( សូមមើល អាលម៉ា ១២:១០ ) ។ អ្នកអាចជ្រើសរើសដើម្បីមានដួងចិត្តទន់ភ្លន់ ។

### ការពិភាក្សា

- តើអាមូលេកមានចរិតលក្ខណៈអ្វីខ្លះ ? តើយើងអាចអភិវឌ្ឍចរិតលក្ខណៈល្អតាមលោកដោយរបៀបណា ?
- ប្រសិនបើអ្នកកំពុងស្វែងរកចម្លើយចំពោះសំណួរជាក់លាក់មួយ តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីឲ្យកាន់តែងាយទទួលបានវិវរណៈពីព្រះវរបិតាសួគ៌ ?
- ដោយការជ្រើសរើសមានចិត្តទន់ភ្លន់ និងគោរពប្រតិបត្តិ តើពរជ័យអ្វីខ្លះដែលព្រះអាចនឹងមាននៅក្នុងឃ្លាំងរបស់ទ្រង់សម្រាប់អ្នក និងគ្រួសារអ្នក ?



### អាមូលេក និងប្រជាជនអាំម៉ូណៃហា

អាមូលេកបានជឿថា អាលម៉ាជាព្យាការីរបស់ព្រះ ( សូមមើល អាលម៉ា ៨:២០ ) ។ ពេលទេវតាបានប្រាប់លោកឲ្យអនុញ្ញាតអាលម៉ាចូលក្នុងផ្ទះលោក លោកបានជ្រើសរើសដើម្បីគោរពតាម ( សូមមើល អាលម៉ា ១០:៨ ) ។ លោកក៏បានឆ្លើយតបចំពោះការហៅរបស់ព្រះឲ្យប្រកាសដំណឹងល្អផងដែរ ( សូមមើល អាលម៉ា ៨:២៩–៣០ ) ។ ទោះជាយ៉ាងណា មនុស្សផ្សេងទៀតនៅក្នុងទីក្រុងនោះបានបដិសេធអាលម៉ា និងមិនជឿឡើយ ។



### ពរជ័យនៃដួងចិត្តទន់ភ្លន់

ដោយសារលោកបានទទួលយកព្រះបន្ទូលរបស់ព្រះ នោះអាមូលេកត្រូវបានប្រទានពរឲ្យមានការចេះដឹងខាងឯព្រះវិញ្ញាណ ។ លោកបាន « ពោរពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធ » ( អាំលម៉ា ៨:៣០ ) លោកទទួលបានទីបន្ទាល់មួយអំពីព្រះចេស្ដានៃព្រះ ( សូមមើល អាលម៉ា ១០:៥ ) ហើយលោកថែមទាំងបានដឹងពីគំនិតរបស់ពួកអ្នកដែលព្យាយាមបោកបញ្ឆោតលោកទៀតផង ( សូមមើល អាលម៉ា ១០:១៧ ) ។ អ្នកក៏អាចជ្រើសរើសដើម្បីទទួលយកព្រះបន្ទូលនៃព្រះ ហើយទទួលពរជ័យរបស់ទ្រង់ផងដែរ ។







### លទ្ធផលនៃដួងចិត្តរឹងរូស

ដោយសារប្រជាជនអាំម៉ូណៃហាបានពង្រឹងចិត្តរបស់ពួកគេចំពោះការបង្រៀនរបស់អាលម៉ា នោះពួកគេបានបាត់បង់ពរជ័យដ៏មានតម្លៃទាំងឡាយ ។ ពួកគេពុំមានចំណេះដឹងអំពីអព្ភូតហេតុនៃព្រះ ( សូមមើល អាលម៉ា ៩:៥ ) ហើយពួកគេត្រូវបានព្រមានថា ព្រះនឹងបំផ្លិចបំផ្លាញពួកគេ ហើយពួកគេនឹងមិនបានទទួលមរតកនៃនគររបស់ទ្រង់ឡើយ ( សូមមើល អាលម៉ា ៩:១២ ) ។



រចនារូបភាពដោយ ប៉ែន ស៊ីម៉ុនសិន

# អាលម៉ា ១៣–១៦

ថ្ងៃទី ១៥–២១ ខែ មិថុនា

# តើពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះចង្អុលបង្ហាញខ្ញុំទៅរកព្រះគ្រីស្ទដោយរបៀបណា ?



« ការប្រព្រឹត្តិល្អដោយគ្មានពិធីបរិសុទ្ធនៃដំណឹងល្អ នឹងមិនប្រោសលោះ ឬលើកតម្កើងដល់មនុស្សលោកទេ ) ។[1]

## រៀបចំ

អាលម៉ា និងអាមូលេកត្រូវបានហៅ និងរៀបចំដោយព្រះអម្ចាស់ដើម្បីបង្រៀនបទបញ្ញត្តិរបស់ទ្រង់ ( សូមមើល អាលម៉ា ១៣:៣ ) ។ ពួកលោកក៏ត្រូវបាន « តែងតាំងឡើងដោយពិធីបរិសុទ្ធ » ( អាលម៉ា ១៣:៨ ) ។ ពិធីបរិសុទ្ធនេះ និងដទៃទៀតត្រូវបានផ្ដល់ឲ្យ ដើម្បីយើងអាចដឹងថាត្រូវរកការផ្ដាច់បាបរបស់យើងនៅឯណា ( សូមមើល អាលម៉ា ១៣:១៦ ) ។ ពិធីបរិសុទ្ធទាំងអស់ចង្អុលបង្ហាញយើងទៅរកព្រះយេស៊ូវគ្រីស្ទ ។

តើអ្នកអាចរៀបចំដើម្បីទទួលពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះរបស់ដំណឹងល្អដោយរបៀបណា ?

## ប្រែចិត្ត

ការប្រែចិត្តបង្វែរចិត្តយើងទៅកាន់ព្រះអង្គសង្គ្រោះ ។ ពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះផ្ដោតគំនិតយើងទៅលើព្រះគ្រីស្ទ និងព្រះគុណរបស់ទ្រង់ ដើម្បីយើងអាចត្រឡប់ទៅកាន់ទ្រង់វិញ ( សូមមើល អាលម៉ា ១៣:១៦ ) ។

## ទទួលបាន

ព្រះអម្ចាស់ប្រទានពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះ ដើម្បីយើងអាចដកបទពិសោធន៍នូវ « ព្រះចេស្ដានៃព្រះគ្រីស្ទក្នុងការសង្គ្រោះ » ( អាលម៉ា ១៥:៦ ) ។

តើពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះណាដែលអ្នកបានទទួល ហើយតើពិធីបរិសុទ្ធទាំងនោះបាននាំអ្នកឲ្យខិតជិតព្រះអង្គសង្គ្រោះដោយរបៀបណា ?



រូបគំនូរដោយ ខាធ្លីន ភីធើសុន

**កំណត់ចំណាំ**

១. ប៊ិយដ៍ ឃេ ផាកកឺ « The Only True Church » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៥ ទំព័រ ៨២ ។

អាលម៉ា ១៧–២២
ថ្ងៃទី ២២–២៨ ខែ មិថុនា

# តើខ្ញុំអាចអនុវត្តសេចក្ដីជំនឿភ្លាមៗដោយរបៀបណា ?

សកម្មភាពដ៏ស្មោះត្រង់ និងភ្លាមៗរបស់អ័ប៊ីសនៅក្នុងព្រះគម្ពីរមរមន បង្ហាញពីរបៀបដែលសេចក្ដីជំនឿជួយនាំអ្នកដទៃទៀតឲ្យមកកាន់ព្រះគ្រីស្ទ ។ សូមពិចារណាពីរបៀបដែលនាង « បានប្រែចិត្តជឿដល់ព្រះអម្ចាស់ » ទាំងស្រុង ( អាលម៉ា ១៩:១៦ ) ។

## ការពិភាក្សា

តើអ្នកអាចពង្រឹងសេចក្ដីជំនឿរបស់អ្នកលើព្រះដោយរបៀបណា ដើម្បីឲ្យអ្នក ហើយប្រហែលជាអ្នកដទៃផង នឹងទទួលអារម្មណ៍នៃអំណាចដើម្បីអនុវត្តភ្លាមៗ និងពេញលេញទៅលើព្រះឆន្ទៈរបស់ព្រះ ?

ទេពកោសល្យដោយ អែនឌ្រូ ប៊ុសលី ប្រភពផ្ទៃខាងក្រោយមកពី GETTY IMAGES



## នាងបានដឹងពីវា

សេចក្ដីជំនឿរបស់អ័ប៊ីសគឺខ្លាំងណាស់ រហូតដល់ពេលដែលនាងបានឃើញអ្នកផ្ទះរបស់ឡាម៉ូណៃបានដួលចុះទៅលើដី នាង « ដឹងថា នេះហើយជាព្រះចេស្ដានៃព្រះ » ( អាលម៉ា ១៩:១៧ ) ។ តើអ្នកអាចស្លាបនាសេចក្ដីជំនឿរបស់អ្នកដើម្បីដឹងពីព្រះចេស្ដានៃព្រះ ដូចជាអ័ប៊ីសបានដឹងដោយរបៀបណា ?





## នាងបានរត់ទៅ

ពេលដែលអ័ប៊ីសបានដឹងពីព្រះចេស្ដានៃព្រះ នាង « បានរត់ពីផ្ទះមួយទៅផ្ទះមួយ » ហើយបានប្រាប់ប្រជាជនឲ្យមកមើលអព្ភូតហេតុនោះ ( អាលម៉ា ១៩:១៧ ) ។ សេចក្ដីជំនឿរបស់នាងបានផ្ដល់អំណាចដល់នាងដើម្បីអនុវត្តភ្លាមៗ ។ តើមានចំណុចណាមួយនៃដំណឹងល្អដែលអ្នកបានដើរ ជំនួសឲ្យរត់វិញ ក្នុងការអនុវត្តតាមព្រះឆន្ទៈរបស់ព្រះដោយសេចក្ដីជំនឿនោះ ?

## នាងបានកាន់ដៃនាំអ្នកដទៃទៀតឲ្យមក

អ័ប៊ីស « ចាប់ព្រះហស្តនៃព្រះអគ្គមហេសី » ដោយសេចក្ដីជំនឿថាវានឹងធ្វើឲ្យព្រះអគ្គមហេសីឈរឡើង ( អាលម៉ា ១៩:២៩ ) ។ នាងបានធ្វើនូវអ្វីដែលហាក់ដូចជាពុំអាចទៅរួច ដោយសារសេចក្ដីជំនឿរបស់នាងលើព្រះ ។ តើអ្នកអាចពង្រឹងសេចក្ដីជំនឿរបស់អ្នកលើព្រះ ហើយសម្រេចនូវអ្វីដែលមិនអាចទៅរួចនៅក្នុងជីវិតអ្នកដោយរបៀបណា ?

## នៅក្នុងវគ្គនេះ


៤៤ ការដកយកសម្ពាធចេញពីការស្វែងរកដៃគូអស់កល្ប
ដោយ ដូមីនីកា ស្វូអ៊ីកា

៤៨ រៀនមានភាពរីករាយពេលខ្ញុំនៅលីវ
ដោយ លេនដុន ហារស៍


## មានតែឌីជីថលប៉ុណ្ណោះ


**១០ យ៉ាងដើម្បីសួរអនាគតស្វាមី/ភរិយារបស់អ្នក**

**ការទុកចិត្តលើចំណាប់អារម្មណ៍ទីពីរ និងលើការដឹកនាំពីព្រះវិញ្ញាណ**
ដោយ ម៉ារី ណិតស្ល័រ

**ការនៅលីវរំឭកខ្ញុំឲ្យទុកចិត្តទៅលើផែនការរបស់ព្រះ*ទាំងស្រុង*សម្រាប់ខ្ញុំ**
ដោយ គ្រីស្ទីណា ខុតតេរ៉ល

**គន្លឹះ ៧ យ៉ាងដើម្បីបន្តភ្ជាប់ទំនាក់ទំនងនៅក្នុងចំណងទាក់ទង**


## ចែកចាយរឿងរបស់អ្នក

តើអ្នកមានបទពិសោធន៍មួយដើម្បីចែកចាយឬទេ ? ឬតើអ្នកចង់ឃើញអត្ថបទអ្វីខ្លះអំពីប្រធានបទជាក់លាក់នានា ? បើដូច្នេះ យើងចង់ឮពីអ្នក ! អ្នកអាចផ្ញើអត្ថបទ ឬមតិកែលម្អរបស់អ្នកតាមគេហទំព័រ **liahona.ChurchofJesusChrist.org** ។

# ការស្វែងរកស្វាមី/ភរិយាម្នាក់—និងព្រះគុណរបស់ព្រះអង្គសង្គ្រោះ

ព្រះអម្ចាស់សន្យាថា « គុណ [ របស់យើង ] មានគ្រប់គ្រាន់សម្រាប់អ្នកស្លូតត្រង់ » ( សូមមើល អេធើរ ១២:២៦ ) ។ បន្ទូលទាំងនេះគួរតែផ្ដល់ដល់យើងជាយុវមជ្ឈិមវ័យនូវសេចក្ដីសង្ឃឹម និងការលួងលោម ជាពិសេសពេលវាទាក់ទងនឹងការស្វែងរកដៃគូអស់កល្ប ។ ជាញឹកញាប់ ពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទដែលងាយទុកចិត្តគេស្វែងរកសេចក្ដីស្រឡាញ់ដោយចិត្តបើកចំហរ តែត្រូវបានធ្វើឲ្យខកចិត្តដោយក្ដីសង្ឃឹមដែលមិនបានដូចចិត្ត ឬត្រូវរកាំចិត្តដោយអាកប្បកិរិយាមិនល្អពីអ្នកដែលពួកគេណាត់ដើរលេងជាគូរនោះ ។ ការស្វែងរកនេះអាចបង្កើតជាការភ័យខ្លាច កំហឹង ភាពជូរចត់ និងភាពតានតឹង ជាពិសេសប្រសិនបើវាបន្តអស់ជាច្រើនឆ្នាំហួសពេលរៀបការដែលអ្នករំពឹងទុក !

ប៉ុន្តែ ដូចដែលអ្នកអាចស្រមៃឃើញថា ព្រះពុំមានព្រះរាជបំណងឲ្យយើងមានអារម្មណ៍ទាំងនេះឥតឈប់ឈរនោះទេ ពេលយើងធ្វើតាមការបញ្ជារបស់ទ្រង់ឲ្យរៀបការ ហើយចិញ្ចឹមបីបាច់គ្រួសារដ៏សុចរិត និងរីករាយនោះ ។ តាមពិតទៅ **ព្រះមានព្រះទ័យចង់ឲ្យយើងមានអារម្មណ៍រីករាយ** អំឡុងពេលនៃការស្វែងរកនេះ !

ដោយទុកការណ៍នេះនៅក្នុងគំនិត អត្ថបទនៅក្នុងផ្នែកនេះត្រូវបានរៀបរាងឡើងដើម្បីជួយអ្នក**ដកយកភាពតានតឹងចេញពីការស្វែងរកដៃគូអស់កល្ប** ។ អ្នកនឹងឃើញមានរឿងរ៉ាវអំពី **របៀបដើម្បីរីកចម្រើននៅក្នុងជីវិត** ដោយមិនគិតពីស្ថានភាពរៀបការ ឬនៅលីវ និង**ដំបូន្មានដែលអាចជួយរៀបចំអ្នក**សម្រាប់អាពាហ៍ពិពាហ៍ដ៏ពោរពេញដោយក្ដីស្រឡាញ់បំផុត ពោរពេញដោយការបីបាច់ និងចាក់ឫសយ៉ាងជ្រៅ ។

ពេលអ្នកស្វែងរកមនុស្សម្នាក់ដែលនឹងប្រគល់ដួងចិត្តទាំងមូលរបស់គេដល់អ្នក ដូចដែលអ្នកប្រគល់ដល់គេ នោះសូមយកពេលមួយភ្លែតដើម្បីអានអត្ថបទទាំងនេះ ។ ខ្ញុំសន្យាថា អត្ថបទមួយក្នុងចំណោមនេះនឹងបំភ្លឺដល់ដួងចិត្តអ្នក ហើយជួយអ្នកឲ្យទុកចិត្តថា **ព្រះគុណរបស់ព្រះអង្គសង្គ្រោះពិតជាគ្រប់គ្រាន់សម្រាប់អ្នក ។**

ដោយស្មោះស្ម័គ្រ
លេនដុន ហារស៍

តើអ្វីជារបៀបដ៏ល្អបំផុតសម្រាប់អ្នក ដើម្បីយកឈ្នះលើភាពសង្ស័យនានាដែលទាក់ទងនឹងសាសនាចក្រ សូមផ្ញើចម្លើយរបស់អ្នកតាមរយៈ **liahona.ChurchofJesusChrist.org** ឲ្យបានត្រឹមថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២០ ។



រូបថតមកពី Getty Images



# ការដកយក
# សម្ពាធ
# ចេញពីការស្វែងរក
# ដៃគូអស់កល្ប



ដោយ ដូមីនីកា ស្ទូអ៊ីកា

សាសនាចក្រនៅប្រទេសប៉ូឡូញតូចណាស់ ។ តាមពិតទៅ វាតូចនៅគ្រប់ទីកន្លែងនៅទ្វីបអឺរ៉ុបប៉ែកខាងកើត ។ ជាធម្មតា យើងពុំមានសមាជិកសាសនាចក្រអាយុស្របាលយើងច្រើនទេនៅក្នុងប្រទេសរបស់យើងទាំងមូល ចុះទម្រាំតែនៅក្នុងវួដ ឬស្តេករបស់យើងទៀតនោះ ។ សំណាងល្អមានសន្និសីទសម្រាប់យុវមជ្ឈិមវ័យដែលធ្វើឡើងជារៀងរាល់ឆ្នាំ នៅក្នុងប្រទេសជាច្រើននៅអឺរ៉ុបខាងកើត ។

សន្និសីទទាំងនេះត្រូវបានរៀបចំឡើង មិនមែនចាំបាច់តែជាការជួយអ្នកឲ្យស្វែងរក « ដៃគូឥតខ្ចោះ » នោះទេ ប៉ុន្តែភាគច្រើនបំផុតគឺដើម្បីជួយដល់យុវមជ្ឈិមវ័យឲ្យបង្កើតមិត្តថ្មី ដែលមានគុណតម្លៃដូចគ្នា ហើយពង្រឹងសេចក្តីជំនឿរបស់ពួកគេដោយការនិយាយជាមួយគ្នាអំពីបទពិសោធន៍ខាងវិញ្ញាណរបស់ពួកគេ ។

## ការផ្តោតលើមិត្តភាព

អំឡុងសន្និសីទមួយនៅប្រទេសប៉ូឡូញនៅឆ្នាំ ២០១០ ខ្ញុំបានជួបរ៉ាឌូ ។ គាត់មកពីប្រទេសរូម៉ានី ។ យើងបាននិយាយគ្នាបន្តិច ប៉ុន្តែមិនយូរប៉ុន្មានគាត់បានចេញទៅបេសកកម្មរបស់គាត់ ហើយយើងក៏មិនបានជួបគ្នាទៀតទេទាល់តែដល់សន្និសីទយុវមជ្ឈិមវ័យមួយទៀត នៅបីឆ្នាំក្រោយមក ។ នៅទីនោះយើងបានមានពេលស្គាល់គ្នាទៅវិញទៅមកបន្ថែមបន្តិចទៀត ប៉ុន្តែខ្ញុំនឹងចេញទៅបេសកកម្មរបស់ខ្ញុំផ្ទាល់នៅមួយខែទៀត ។ រ៉ាឌូបានជូនពរខ្ញុំឲ្យជួបតែអ្វីដែលល្អ ហើយបាននិយាយថា « សូមឲ្យយើងបន្តទំនាក់ទំនងនឹងគ្នា » ។ ខ្ញុំមិនជាបានគិតទេថា គាត់នឹងបន្តទាក់ទងនោះ ប៉ុន្តែគាត់បានធ្វើវា ។ គាត់បានសរសេរសំបុត្រដល់ខ្ញុំអស់ពេញមួយបេសកកម្មខ្ញុំ ។ ពុំមានអ្វីទាក់ទងរឿងស្នេហាទេនៅក្នុងសំបុត្ររបស់គាត់ ប៉ុន្តែគាត់បានក្លាយជាមិត្តដ៏ស្និតស្នាលម្នាក់របស់ខ្ញុំ ។ ហើយខ្ញុំចូលចិត្តការគោរពដែលគាត់មានសម្រាប់ខ្ញុំ និងសម្រាប់កិច្ចការផ្សព្វផ្សាយសាសនាជាទូទៅ ។

ពេលខ្ញុំបានត្រឡប់មកផ្ទះវិញ រ៉ាឌូ និងខ្ញុំទាំងពីរនាក់រំភើបណាស់ ដោយបានស្គាល់គ្នាបន្ថែមទៀតកាន់តែច្បាស់—នៅទីបំផុតយើងអាចធ្វើឲ្យវាកើតឡើងបានបន្ទាប់ពីរយៈពេលជាច្រើនឆ្នាំមក ។ យើងបានជ្រើសរើស



# ជីវិតមិនមែនតែពី ការរៀបការនោះទេ ប៉ុន្តែ វាអំពីការក្លាយជាទម្រង់ដ៏ ល្អបំផុតនៃខ្លួនយើង ហើយ អនុញ្ញាតឲ្យព្រះធ្វើកិច្ចការរបស់ ទ្រង់នៅក្នុងជីវិតយើង ។

កន្លែងមួយដែលមិនសូវថ្លៃសម្រាប់យើងទាំងពីរដើម្បីជួបគ្នា ( ដែលជាប្រទេសបែលហ្ស៊ិកនៅពេលនោះ ) ដើម្បីចំណាយពេលខ្លះជាមួយគ្នា ។ យើងបានជជែកគ្នា ហើយជជែកគ្នាទៀត ហើយជជែកគ្នាថែមទៀត ។

យើងពុំបានដាក់សម្ពាធលើចំណងទាក់ទងរបស់យើងនោះទេ ។ យើងបានផ្ដោតទៅលើការស្ថាបនាមិត្តភាពមួយ ហើយគ្រាន់តែរៀនស្គាល់គ្នាបន្ថែមទៀត ។ យើងតែងតែមានភាពសប្បាយរីករាយយ៉ាងខ្លាំងជាមួយគ្នា ប៉ុន្តែយើងក៏មាននូវការពិភាក្សាដ៏មានអត្ថន័យ និងជ្រាលជ្រៅផងដែរអំពីការណ៍ទាំងឡាយដែលមានសារសំខាន់បំផុត ។ ពេលវេលាចេះតែរំកិលទៅមុខ ហើយមិត្តភាពរបស់យើងលូតលាស់កាន់តែរឹងមាំ ។ យើងនិយាយគ្នាតាម Skype ស្ទើរតែរាល់ថ្ងៃ ហើយក្រោយមកយើងបានចាប់ផ្ដើមអធិស្ឋានពេលរាត្រីជាមួយគ្នា ។ នៅទីបំផុតយើងបានចាប់ផ្ដើមទៅលេងប្រទេសរបស់គ្នាទៅវិញទៅមកជារៀងរាល់ពីរបីខែម្ដង ។

## « ចូរយើងអធិស្ឋានអំពីវា »

មួយរយៈក្រោយមកទៀត ខ្ញុំបានចាប់ផ្ដើមមានការថប់បារម្ភដោយសារខ្ញុំបានមានអារម្មណ៍ថាមិត្តភាពរបស់យើងកំពុងអភិវឌ្ឍទៅកាន់អ្វីមួយថែមទៀត ។ ប៉ុន្តែគាត់មកពីប្រទេសរូម៉ានី ! ខ្ញុំមិនចង់មានចំណងទាក់ទងដែលឆ្ងាយពីគ្នានោះទេ ព្រោះចំណងទាក់ទងមួយអាចនាំទៅកាន់អាពាហ៍ពិពាហ៍ដែលមានន័យថាម្នាក់ក្នុងចំណោមទាំងពីរត្រូវតែប្ដូរទៅកាន់ប្រទេសមួយផ្សេងទៀត ។ ខ្ញុំពុំទាន់បានត្រៀមខ្លួនរួចរាល់ចំពោះរឿងនោះទេ ។

ថ្ងៃមួយពេលខ្ញុំមានការថប់បារម្ភខ្លះៗ នោះរ៉ាឌូបានរំឭកខ្ញុំពីគោលការណ៍ដ៏សាមញ្ញតែមានអានុភាពមួយ ។ គាត់បាននិយាយថា « ចូរយើងអធិស្ឋានពីចំណងទាក់ទងរបស់យើង ហើយមើលថាតើយើងមានអារម្មណ៍យ៉ាងណា » ។

ខ្ញុំមិនបានដឹងទេថាហេតុអ្វីខ្ញុំមិនបានគិតអំពីការអធិស្ឋានអំពីចំណងទាក់ទងរបស់យើងពីមុននេះ ។ ប៉ុន្តែនោះគឺជាដំបូន្មានដ៏ល្អបំផុតដែលខ្ញុំបានទទួលនៅពេលនោះ ។ ដូច្នេះ ខ្ញុំបានអធិស្ឋានសូមការដឹកនាំ ។

ខ្ញុំពុំបានរំពឹងថាបានចម្លើយជាក់លាក់ណាមួយឡើយនៅគ្រានោះទេ ប៉ុន្តែខ្ញុំបានសម្រេចចិត្តបន្តឈានទៅមុខជាមួយនឹងការរៀនស្គាល់រ៉ាឌូបន្ថែមទៀត ។ ខ្ញុំបានសង្ឃឹមថា ព្រះវរបិតាសួគ៌នឹងផ្ដល់ការព្រមានដល់ខ្ញុំ ប្រសិនបើចំណងទាក់ទងរបស់យើងមិនមែនជាអ្វីដែលខ្ញុំគួរតែបន្ត ។ ប៉ុន្តែយូរៗទៅ ចម្លើយដែលខ្ញុំបានសូម *ពិត*ជាបានមក ។

ខ្ញុំបាននិយាយអំពីរ៉ាឌូជាមួយគ្រួសារ និងមិត្តភក្តិខ្ញុំ ហើយគ្រប់ការសន្ទនាទាំងអស់ ខ្ញុំត្រូវបានបញ្ជាក់ជាថ្មីថា ខ្ញុំកំពុងដើរទៅកាន់ទិសដៅត្រឹមត្រូវ ។

មិនយូរប៉ុន្មាន ខ្ញុំបានមានការយល់ដឹងដ៏គួរឲ្យអស់សំណើចមួយ ។ បន្ទាប់ពីមានការនិយាយតាម Skype ដ៏អស្ចារ្យមួយទៀតជាមួយរ៉ាឌូនៅយប់មួយ ខ្ញុំបាននិយាយទៅកាន់ខ្លួនឯងថា « គាត់ពិតជាមិត្តដ៏ល្អបំផុតដែលខ្ញុំធ្លាប់មាន ។ ខ្ញុំចង់ធ្វើជាមិត្តរបស់គាត់ជារៀងរហូត ! » ពេលនោះហើយដែលខ្ញុំបានដឹង ។ រំពេចនោះសំឡេងមួយនៅក្នុងចិត្តខ្ញុំបានឆ្លើយទៅនឹងគំនិតរបស់ខ្ញុំផ្ទាល់ថា « មែនហើយ អញ្ចឹងអ្នកត្រូវតែរៀបការនឹងគាត់ ! » ខ្ញុំដឹងថា ព្រះវរបិតាសួគ៌ញញឹមនឹងចំណងទាក់ទងរបស់ខ្ញុំនឹងរ៉ាឌូ ។ ខ្ញុំអាចឃើញថា គាត់ជាមិត្តដ៏ល្អបំផុត ហើយថាយើងអាចមានភាពរីករាយជាមួយគ្នា ។

## ការដកយកសម្ពាធចេញពីការស្វែងរកស្វាមី/ភរិយា

ដូច្នេះខ្ញុំបានប្ដូរទៅនៅប្រទេសរូម៉ានី ហើយបានរៀបការនឹងរ៉ាឌូ ។ ខ្ញុំមិនដែលគិតទេថា ខ្ញុំនឹងរស់នៅប្រទេសរូម៉ានី ។ ប៉ុន្តែយើងបានរៀបការអស់បួនឆ្នាំហើយឥឡូវនេះ ហើយយើងមានកូនស្រីដ៏ល្អម្នាក់ឈ្មោះ អាំមើលៀ ។

ខ្ញុំដឹងពីអ្វីដែលអ្នកកំពុងគិត—ខ្ញុំគ្រាន់តែជាយុវមជ្ឈិមវ័យម្នាក់ទៀតដែលបានជួប « ដៃគូជីវិត » របស់ខ្ញុំនៅសន្និសីទយុវមជ្ឈិមវ័យ ហើយអ្វីៗបានដំណើរការទៅដោយមិនបាច់ប្រឹង ។ ប៉ុន្តែនោះពុំមែនជារឿងពិតទេ ។ មូលហេតុដែលខ្ញុំប្រាប់រឿងនេះដល់អ្នក គឺដើម្បីឲ្យអ្នកឈប់ដាក់សម្ពាធលើខ្លួនឯងក្នុងការស្វែងរកដៃគូអស់កល្ប ហើយសូមឲ្យព្រះដឹកនាំអ្នកវិញ ។

តើខ្ញុំទៅសន្និសីទយុវមជ្ឈិមវ័យទាំងនោះដើម្បីទៅរកស្វាមីឬ ? អត់ទេ ។

តើខ្ញុំបានគិតថា បុរសម្នាក់ដែលខ្ញុំបានជួបនៅទីនោះនឹងក្លាយជាស្វាមីរបស់ខ្ញុំឬ ? ខ្ញុំមិនប្រាកដដែរ ។

ផ្ទុយទៅវិញ ខ្ញុំបានដកយកសម្ពាធចេញពីការស្វែងរកមនុស្សដែលខ្ញុំចង់រៀបការជាមួយ ហើយខ្ញុំគ្រាន់តែទៅសន្និសីទទាំងនេះដើម្បីភ្ជាប់ទំនាក់ទំនងនឹងមនុស្សផ្សេងទៀត ហើយកសាងមិត្តភាព—នោះហើយជាអ្វីដែលរ៉ាឌូ និងខ្ញុំបានធ្វើពីដំបូង ។





សម្ពាធដើម្បីស្វែងរកដៃគូអស់កល្បឲ្យឆាប់បំផុតតាមដែលអាចធ្វើទៅបាន អាចជារឿងពិតជាក់ស្តែងណាស់នៅពេលខ្លះ ។ ប៉ុន្តែពុំមានការកំណត់ពេលវេលាលើចំណងទាក់ទងដ៏អស់កល្បនោះទេ ។ ពុំចាំបាច់តានតឹងពីវាទេ ។ ជីវិតមិនមែនតែពីការរៀបការនោះទេ ប៉ុន្តែវាអំពីការក្លាយជាទម្រង់ដ៏ល្អបំផុតនៃខ្លួនយើង ហើយអនុញ្ញាតឲ្យព្រះធ្វើកិច្ចការរបស់ទ្រង់នៅក្នុងជីវិតយើង ។ មែនហើយ យើងទាំងអស់គ្នាគួរតែចេញទៅ បង្ហាញខ្លួន ជួបមនុស្សម្នា បង្កើតមិត្តថ្មី ហើយធ្វើអ្វីដែលមិនមែនជារឿងងាយស្រួលសម្រាប់យើង ។ ប៉ុន្តែយើងក៏គួរតែធ្វើដូច្នោះដោយមានគំនិតថា « ខ្ញុំនឹងសប្បាយរីករាយ ហើយជួបនឹងមិត្តភក្តិដ៏អស្ចារ្យមួយចំនួន » ជាជាងថា « ខ្ញុំត្រូវតែចាំយាមរកមើល ‹ មនុស្សម្នាក់ដែលល្អបំផុត › ឬមិនដូច្នោះទេខ្ញុំនឹងធ្វើឲ្យខូចផែនការអស់ពេញមួយជីវិតខ្ញុំ ! »

រឿងមួយដែលវ៉ាឌូបានប្រាប់ខ្ញុំពេលយើងភ្ជាប់ពាក្យគឺថា ថ្វីបើគាត់តែងតែមានអារម្មណ៍តានតឹងបន្តិចពេលនៅជិតមនុស្សស្រីដែលគាត់ចូលចិត្ត ក៏គាត់ពុំបានមានអារម្មណ៍បែបនោះជាមួយខ្ញុំឡើយ ។ គាត់បាននិយាយថា ដោយសារតែមិត្តភាពរបស់យើង គាត់តែងតែងមានអារម្មណ៍ស្រាកស្រាន្ត ហើយគាត់តែងតែអាចធ្វើជាខ្លួនឯង ។

ដូច្នេះ សូមរកមើលមនុស្សល្អៗឲ្យនៅជុំវិញខ្លួនឯង ហើយរីករាយជាមួយនឹងស្ថានភាពបច្ចុប្បន្នរបស់អ្នក ។ ដោយសារតាមពិតទៅ ពេលអ្នកឈប់មានភាពតានតឹង ហើយគ្រាន់តែជ្រើសរើសដើម្បីកសាងមិត្តភាព ហើយរៀនស្រឡាញ់ខ្លួនឯង និងស្ថានភាពបច្ចុប្បន្នរបស់ខ្លួនឯង ពេលនោះហើយដែលជីវិតក្លាយកាន់តែរីករាយឡើង ។

## ការទុកចិត្តលើផែនការរបស់ព្រះសម្រាប់អនាគតរបស់យើង

វ៉ាឌូ និងខ្ញុំមិនល្អឥតខ្ចោះទេ ។ យើងមិនបានស្វែងរកមនុស្ស « ល្អឥតខ្ចោះ » ឡើយ—យើងគ្រាន់តែធ្វើជាខ្លួនឯងប៉ុណ្ណោះ ។ អ្វីដែលខ្ញុំបានសង្កេតឃើញនោះគឺថា ភាពពិតនៃខ្លួនអ្នក និងរបៀបដែលអ្នករស់នៅ គឺជាអ្វីដែលទាក់ទាញចិត្តបំផុតដល់មនុស្សផ្សេងទៀត ។ ពេលអ្នកព្យាយាមធ្វើតាមព្រះយេស៊ូវគ្រីស្ទ អ្នកនឹងទាក់ទាញចិត្តអ្នកដទៃទៀតដែលកំពុងធ្វើតាមទ្រង់ឲ្យបានល្អបំផុតផងដែរ ។

ខ្ញុំក៏បានរៀនផងដែរថា ពេលយើងក្លាយកាន់តែប្រសើរឡើង ហើយមានសេចក្តីជំនឿពេញលេញថា ព្រះជាអង្គទទួលខុសត្រូវ នោះយើងនឹងអញ្ជើញព្រះហស្តទ្រង់ចូលក្នុងជីវិតយើង—ហើយពេលយើងទទួលស្គាល់ព្រះហស្តទ្រង់ នោះមិនចាំបាច់ភ័យខ្លាចអនាគតឡើយ ។ សូមចងចាំអ្វីដែលព្រះអម្ចាស់បានបង្រៀននីហ្វៃ ៖ « ហើយយើងក៏នឹងទៅជាពន្លឺរបស់អ្នករាល់គ្នានៅក្នុងទីរហោស្ថានដែរ ហើយយើងនឹងរៀបចំផ្លូវសម្រាប់អ្នករាល់គ្នាបើសិនជាអ្នករាល់គ្នាកាន់តាមបញ្ញត្តិទាំងឡាយរបស់យើង ហេតុដូច្នោះហើយ ដរាបណាអ្នករាល់គ្នាកាន់តាមបញ្ញត្តិទាំងឡាយរបស់យើង នោះអ្នករាល់គ្នានឹងត្រូវបាននាំទៅដែនដីសន្យា ហើយអ្នករាល់គ្នានឹងដឹងថា គឺយើងនេះហើយដែលបាននាំអ្នករាល់គ្នាទៅ » ( នីហ្វៃទី១ ១៧:១៣ ) ។

យើងមិនត្រូវដាក់សម្ពាធឥតឈប់ឈរលើខ្លួនឯងដោយសារតែការរំពឹងទុក ឬគោលដៅជាក់លាក់ទាំងឡាយដែលមិនបានសមប្រកបតាមពេលវេលារបស់យើងផ្ទាល់នោះឡើយ ។ តាមពិតទៅ ពេលវេលារបស់ព្រះវរបិតាសួគ៌គឺខុសពីរបស់យើង—វាគឺអស់កល្បជានិច្ច ។ ទ្រង់មានផែនការមួយសម្រាប់យើង ដើម្បីបំពេញរាល់ពរជ័យទាំងឡាយដែលយើងស្វែងរក ។ ហើយពេលយើងទុកចិត្តលើផែនការរបស់ទ្រង់ឲ្យអស់ពីសមត្ថភាព ហើយស្វែងរកការបំពេញនៅក្នុងកាលៈទេសៈណាក៏ដោយដែលយើងឃើញថាយើងស្ថិតនៅក្នុង *នោះហើយ*ជាពេលដែលយើងនឹងរកឃើញសុភមង្គលដ៏ពិត ។ ផែនការរបស់ទ្រង់តែងតែល្អជាងផែនការដែលយើងមានសម្រាប់ខ្លួនយើង ។ ■



***ដូមីនីកា ស្ទូអ៊ីកា*** *ជាម្តាយម្នាក់ដែលមានស្មារតីជាសហគ្រិន ។ នាងចូលចិត្តការចំអិនអាហារ រាំ និងធ្វើឲ្យគេសើច ។ នាងដំណើរការ lifestyle blog មួយ ហើយចូលចិត្តកែរូបថត ជិះកង់ និងចំណាយពេលនៅលើភ្នំ ។*





ដោយ លេនដុន ហរស៍

# រៀនមានភាពរីករាយពេលខ្ញុំនៅលីវ



ខ្ញុំបានដឹងថា ខ្ញុំមានទស្សនៈខុសឆ្គងអំពីការណាត់ជាគូ ។

« ហេតុអ្វីមនុស្សគ្រប់គ្នាផ្សេងទៀតណាត់ជាគូ ហើយមានភាពរីករាយ ? »

« ហេតុអ្វីខ្ញុំមិនទាន់រៀបការ ? »

« តើមានអ្វីខុសឆ្គងអំពីខ្ញុំឬ ? »

យុវមជ្ឈិមវ័យភាគច្រើនបំផុតប្រហែលជាបានសួរខ្លួនឯងនូវសំណួរទាំងនេះយ៉ាងហោចណាស់ម្តង ! ឧបសគ្គនៃការស្វែងរកដៃគូអស់កល្ប អាចធ្វើឲ្យសេចក្តីជំនឿ និងសេចក្តីសង្ឃឹមចុះខ្សោយ សូម្បីតែចំពោះពួកបរិសុទ្ធថ្ងៃចុងក្រោយដ៏មានចិត្តឧទ្ទិសភាគច្រើនក៏ដោយ ។ មែនហើយ ក្នុងករណីរបស់ខ្ញុំផងដែរ ការណាត់ជាគូគឺពិបាកខ្លាំងណាស់ ។

អាពាហ៍ពិពាហ៍តែងតែហាក់បីដូចជាការផ្សងព្រេងដ៏ធំមហិមាមួយចំពោះខ្ញុំ ហើយខ្ញុំបានទន្ទឹងរង់ចាំវាតាំងពីនៅក្មេង ។ ប៉ុន្តែខ្ញុំបានបាក់ទឹកចិត្ត ពេលវាហាក់បីដូចជាខ្ញុំកំពុងតែបរាជ័យក្នុងការណាត់ជាគូអំឡុងពេលរៀននៅមហាវិទ្យាល័យ ។ ទោះបីជាខ្ញុំបានទៅការណាត់ជាគូជាច្រើន បានមានចំណងទាក់ទងប្រាកដប្រជាមួយចំនួន ហើយបានជួបនឹងស្ត្រីដ៏មានជោគជ័យ និងគួរឲ្យចាប់អារម្មណ៍ក្តី ក៏ខ្ញុំមិនបានរៀបការដែរ ។ ហើយចំពោះខ្ញុំ ចំណងទាក់ទងបរាជ័យទាំងនោះធ្វើឲ្យមានអារម្មណ៍ថាជាសញ្ញាមួយដែលថា ខ្ញុំអន់ជាងគេ ឬមិនមានភាពទាក់ទាញ ។

អារម្មណ៍របស់ខ្ញុំចំពោះភាពនៅលីវរបស់ខ្ញុំកាន់តែអាក្រក់ថែមទៀត បន្ទាប់ពីការបែកគ្នាមួយចំនួន ពេលខ្ញុំបានចាប់ផ្តើមអាជីពការងាររបស់ខ្ញុំ ។ វាងាយស្រួលសម្រាប់ខ្ញុំដើម្បីសួរថា តើមានអ្វីខុសឆ្គងជាមួយខ្ញុំ ហើយមានអ្វីត្រឹមត្រូវជាមួយនឹងគ្រប់គ្នាផ្សេងទៀតដែលបានរៀបការ ។ ពររបស់លោកអយ្យកោរបស់ខ្ញុំជាមួយនឹងពរជ័យបុព្វជិតភាពមួយចំនួន បានបញ្ជាក់យ៉ាងខ្លាំង និងជាក់លាក់ថា ខ្ញុំនឹងបានផ្សារភ្ជាប់នៅក្នុងជីវិតរមែងស្លាប់នេះទៅនឹងស្ត្រីសុចរិតម្នាក់ ។ ចុះតើហេតុអ្វីវាមិនកើតឡើង ?

ខ្ញុំបានចាប់ផ្តើមឆ្ងល់ថា « តើខ្ញុំបានធ្វើអ្វីដែលធ្វើឲ្យខ្ញុំធ្លាក់ចេញពីផែនការរបស់ព្រះសម្រាប់ខ្ញុំឬ ? »

នៅទីបំផុត បន្ទាប់ពី « ការប្រយុទ្ធ » ពីមុខព្រះអស់ជាច្រើនឆ្នាំតាមរយៈការអធិស្ឋាន ការសិក្សាព្រះគម្ពីរ និងការចូលរួមនៅព្រះវិហារបរិសុទ្ធ ខ្ញុំបានទទួលវិវរណៈទាក់ទងនឹងស្ថានភាពរបស់ខ្ញុំតាមរយៈមិត្តភក្តិ និងទីប្រឹក្សារបស់ខ្ញុំ ប្រេដ ( ឈ្មោះត្រូវបានផ្លាស់ប្តូរ ) ។ អំឡុងការប្រជុំក្រុមប្រឹក្សាមួយ គាត់បាននិយាយថា ៖ « សុភមង្គលរបស់អ្នកអាស្រ័យទៅលើខ្លួនអ្នក—មិនមែនលើអ្នកណាម្នាក់ផ្សេងទៀតនោះទេ ។ ពេលអ្នកមានភាពរីករាយកាលអ្នកនៅលីវ នោះអ្នកអាចមានភាពរីករាយនៅក្នុងកាលៈទេសៈណាក៏បាន » ។ ដូចគ្នានោះដែរ ប្រធាន រ័សុល អិម ណិលសុន បានបង្រៀនថា « អំណរដែលយើងមាននោះ វាមានឥទ្ធិពលតិចតួចមកពីកាលៈទេសៈនៃជីវិតយើង ប៉ុន្តែវាមានឥទ្ធិពលខ្លាំងមកពីអ្វីដែលជីវិតយើងផ្តោតទៅលើ » ( « Joy and Spiritual Survival » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៦ ទំព័រ ៨២ ) ។

ទស្សនៈរបស់ខ្ញុំទាំងមូលបានផ្លាស់ប្តូរ កាលដែលព្រះវិញ្ញាណបានបំផុសយ៉ាងខ្លាំងនូវពាក្យពេចន៍ទាំងនេះដល់ព្រលឹងខ្ញុំ ។ ហើយខ្ញុំបានដឹងថា ខ្ញុំតែងតែបានណាត់ដើរលេងជាគូដើម្បីបំពេញសេចក្តីត្រូវការមួយ—ក្នុងករណីរបស់ខ្ញុំ សេចក្តីត្រូវការនោះគឺដើម្បីរៀបការ គ្រាន់តែដើម្បីមិនឲ្យខ្ញុំនៅឯកោទៀត ។

ការណ៍នេះពិតជាមិនមែនជារបៀបមួយដែលនឹងដឹកនាំទៅកាន់ដៃគូអស់កល្បដ៏ពោរពេញដោយក្តីស្រឡាញ់នោះទេ ។ តាមរយៈប្រេដ ព្រះអម្ចាស់បានបង្រៀនខ្ញុំដោយទន់ភ្លន់ថា ផែនការរបស់ទ្រង់សម្រាប់បុត្រាបុត្រីទ្រង់មិនមែនសម្រាប់ឲ្យពួកគេរៀបការដោយផ្អែកលើសេចក្តីត្រូវការ ឬសម្ពាធវប្បធម៌ និងការភ័យខ្លាចនោះទេ ។ អាពាហ៍ពិពាហ៍គឺផ្អែកលើសេចក្តីស្រឡាញ់ដូចព្រះគ្រីស្ទ ។ បន្ទាប់មកទ្រង់បានបង្រៀនខ្ញុំថា ស្ថានភាពនៅលីវរបស់ខ្ញុំអាចបន្តបង្រៀនខ្ញុំឲ្យរស់នៅក្នុងជីវិត ហើយស្វែករកអាពាហ៍ពិពាហ៍ដោយផ្អែកលើសេចក្តីស្រឡាញ់ដ៏បរិសុទ្ធ មិនមែនដោយភាពងាយស្រួលនោះទេ ។ ស្វែងរកអាពាហ៍ពិពាហ៍ដោយហេតុផលត្រឹមត្រូវ ។

តាមរយៈបទពិសោធន៍នេះ ខ្ញុំបានរៀនសេចក្តីពិតបីយ៉ាងដែលខ្ញុំគិតដល់ពេលណាដែលខ្ញុំមានអារម្មណ៍បាក់ទឹកចិត្តអំពីការណាត់ជាគូ ៖

១. **តម្លៃរបស់អ្នកមិនអាស្រ័យទៅលើស្ថានភាពរៀបការ ឬនៅលីវរបស់អ្នកនោះទេ ។** អេសាយបានបង្រៀនថា « គំនិត [ របស់ទ្រង់ ] មិនមែនដូចជាគំនិត [ របស់យើង ] ទេ » ( អេសាយ ៥៥:៨ ) ។ ខ្ញុំបានគិតថា ការនៅលីវគឺជាការឆ្លុះបញ្ចាំងពីការខ្វះតម្លៃរបស់ខ្ញុំ ។ ទោះជាយ៉ាងណា ព្រះបានជួយខ្ញុំឲ្យឃើញថា ការនៅលីវគឺជាការរៀបចំខ្ញុំសម្រាប់អាពាហ៍ពិពាហ៍មួយដែលកាន់តែប្រសើរជាងដែលខ្ញុំអាចមាន ប្រសិនបើខ្ញុំរៀបការទៅតាមពេលវេលារបស់ខ្ញុំនោះ ។ វាមិនមានអ្វីទាក់ទងនឹងតម្លៃរបស់ខ្ញុំនោះទេ ។

២. **ការរៀបចំកម្ចាត់ចោលនូវការអន្ទះសា និងការព្រួយចិត្ត ។** ព្រះអម្ចាស់ប្រាប់យើងថា « បើសិនជា [ យើង ] បានប្រុងប្រៀបទុកជាស្រេច នោះ [ យើង ] នឹងមិនត្រូវខ្លាចឡើយ » ( គោលលទ្ធិ និងសេចក្តីសញ្ញា ៣៨:៣០ ) ។ ការស្វែងរក ហើយបន្ទាប់មកធ្វើតាមព្រះរាជឆន្ទៈរបស់ព្រះ បានជួយខ្ញុំឲ្យទម្លាក់ចោលការភ័យខ្លាច និងការជុញថប់ពីមុនមកទាក់ទងនឹងស្ថានភាពអាពាហ៍ពិពាហ៍របស់ខ្ញុំ ។ វាក៏បានជួយខ្ញុំឲ្យផ្តោតលើការរៀបចំខ្លួនឯងសម្រាប់អ្នកក៏ដោយដែលនឹងចូលមកតាមផ្លូវរបស់ខ្ញុំនៅពេលអនាគតផងដែរ ។

៣. **មានអំណរនៅក្នុងការនៅលីវ ។** ការនៅលីវបានផ្តល់ពរដល់ខ្ញុំជាមួយនឹងឱកាសក្នុងការធ្វើដំណើរដ៏រំភើប ការអភិវឌ្ឍការងារ និងមធ្យោបាយដើម្បីបម្រើនៅក្នុងសាសនាចក្រ ។ ខណៈដែលខ្ញុំនៅតែមានបំណងប្រាថ្នាយ៉ាងជ្រាលជ្រៅដើម្បីរៀបការ ហើយមានកូនចៅ ព្រះបានជួយខ្ញុំឲ្យពេញចិត្តពីអ្វីៗជាច្រើនដែលត្រូវធ្វើនៅក្នុងនគររបស់ទ្រង់ឥឡូវនេះ ថ្វីបើខ្ញុំមានដៃគូនៅក្បែរខ្ញុំ ឬអត់ក៏ដោយ ។

ខ្ញុំនៅតែមិនទាន់រៀបការ ! ភរិយារបស់ខ្ញុំមិនទាន់ចេញមកទេ ទោះជានៅពេលនេះខ្ញុំបានផ្លាស់ប្តូរទស្សនៈរបស់ខ្ញុំអំពីការណាត់ជួបជាគូ និងអាពាហ៍ពិពាហ៍ ហើយខ្ញុំដឹងថា ពេលខ្លះខ្ញុំនឹងនៅតែមានភាពតានតឹងជាមួយនឹងការណាត់ជួបជាគូនៅពេលអនាគត ។ ប៉ុន្តែការភ័យខ្លាច និងការថប់បារម្ភជាច្រើនអំពីស្ថានភាពអាពាហ៍ពិពាហ៍របស់ខ្ញុំបានបាត់អស់ទៅហើយ ។ ហើយឥឡូវនេះខ្ញុំដឹងថា វាមិនថ្វីទេដើម្បីនៅលីវ ខណៈដែលព្រះអម្ចាស់ និងខ្ញុំធ្វើការរួមគ្នាដើម្បីបំពេញការសន្យា និងពរជ័យដ៏អស់កល្បទាំងឡាយ ដែលទ្រង់បានធ្វើសម្រាប់ខ្ញុំ—ទាំងនៅក្នុងជីវិតរមែងស្លាប់នេះ និងនៅក្នុងភាពអស់កល្បជានិច្ច ។ ■



*លេនដុន ហរស៍ ជាអ្នកធ្វើផែនការទីក្រុងនៅលើពិភពលោក ដែលចូលចិត្តការសរសេរពីអ្វីដែលល្អ សៀវភៅដ៏អស្ចារ្យ និងស្វែងយល់ពីពិភពលោក ។ អ្នកអាចរកឃើញគាត់នៅឯបណ្ណាល័យក្នុងតំបន់របស់គាត់ ស្រែកហ៊ោគាំទ្រដល់ក្រុមរបស់គាត់នៅទីលានវាយកូនបាល់បេស្បល ឬនៅតាមផ្លូវដែលបទរកមើលកន្លែងស្អាតៗដែលគ្មាននរណាម្នាក់បានគិតថានឹងមើល ។*

រូបថតដោយ ជូស៊ី ឌុងអ៊ឹម



## ហ្វូហ្វូអា វី ( ខាងឆ្វេង ) អាយុ ១៨ ឆ្នាំ
## អ៊ីទូអាលេ វី ( ខាងស្ដាំ ) អាយុ ១៦ ឆ្នាំ ទីក្រុងសាវ៉ាលី ប្រទេសសាម័រ

គ្រប់គ្នាជួយនៅក្នុងគ្រួសារយើង ។

**ហ្វូហ្វូអា ៖** គ្រួសារយើងជឿលើការធ្វើការជាមួយគ្នា ។ ប្អូនប្រុសខ្ញុំ អ៊ីទូអាលេ និងខ្ញុំប្រមូលឪសសម្រាប់ដុតចម្អិនម្ហូប ។ យើងក៏ជួយធ្វើម្ហូបលក់ផងដែរ ។ ខ្ញុំចាំបានពេលមួយកាលដែលគ្រួសារយើងពុំមានប្រាក់គ្រប់គ្រាន់ដើម្បីបង់ថ្លៃទឹកដ៏ថ្លៃ យើងទាំងអស់គ្នាបានធ្វើផ្នែករបស់យើងដើម្បីជួយ ។ បងស្រីខ្ញុំបានលក់សាច់អាំង ។ អ៊ីទូអាលេ និងខ្ញុំបានប្រមូលដូង និងម្ហូបផ្សេងៗទៀត ហើយបានជួយលក់ម្ហូបដើម្បីបានលុយ ។ ដោយការធ្វើការយ៉ាងខ្លាំងជាក្រុមគ្រួសារ ហើយទុកចិត្តលើព្រះ នោះយើងអាចមានលទ្ធភាពបង់ថ្លៃទឹក ហើយបានទឹកប្រើវិញ ។

**អ៊ីទូអាលេ ៖** ព្រះជួយខ្ញុំនូវអ្វីៗគ្រប់យ៉ាងនៅក្នុងជីវិតខ្ញុំ ។ ទ្រង់ប្រទានកម្លាំងដល់ខ្ញុំ ហើយប្រទានពរដល់ខ្ញុំរាល់ថ្ងៃ ។ ខ្ញុំចូលចិត្តរស់នៅក្នុងប្រទេសសាម័រ ។ វាមានភាពសុខសាន្តណាស់នៅទីនេះ ។ ក្ដីសុបិនដ៏ធំបំផុតរបស់ខ្ញុំគឺដើម្បីទៅបម្រើបេសកកម្មពេញម៉ោង ! ខ្ញុំចង់ថ្វាយពេលវេលាពីរឆ្នាំរបស់ខ្ញុំដល់ព្រះ ។



រូបថតដោយ ឡេស្លី និលសុន

# យុវវ័យ

## នៅក្នុងវគ្គនេះ




៥២ ការទទួលបានទីបន្ទាល់មួយនៅជុំវិញពិភពលោក
ដោយ វិលម័រ អាម៉ាយា មូណូហ្ស៍

៥៤ ខួបលើកទី ១៥០ នៃអង្គការយុវនារី
ដោយ ស៊ិស្ទើរ ប៊ូនី អេច ខ័រឌុន

៥៨ ក្រុមយុវនារី ៖ ប្រារព្ធខួប ១៥០ ឆ្នាំ
ដោយ អាម៉ានដា ដាន់

៦២ សំណួរ និងចម្លើយ ៖ ការធ្លាក់ទឹកចិត្ត ការប្រកាន់ពូជសាសន៍

៦៤ ពាក្យចុងក្រោយ ៖ ការបម្រើរួមគ្នាជាមួយនឹងអំណាចបព្វជិតភាព
ដោយប្រធាន អិម រ័សុល បាឡឺដ

# ការទទួលបានទីបន្ទាល់មួយ *នៅជុំវិញពិភពលោក*

ដោយ វិលម៉ា អាម៉ាយា មូណ្ហហ្ស៍

ខ្ញុំបានកើតនៅប្រទេសអេស្ប៉ាញ ហើយបានរស់នៅទីនោះអស់ប្រាំបីឆ្នាំ ។ យើងមិនបានទៅព្រះវិហារច្រើនទេ ដូច្នេះខ្ញុំពុំបានទទួលបុណ្យជ្រមុជទឹកពេលខ្ញុំអាយុប្រាំបីឆ្នាំនោះទេ ប៉ុន្តែខ្ញុំពិតជាចង់ជ្រមុជទឹក ។ ថ្ងៃមួយខ្ញុំបានសួរឪពុកម្ដាយខ្ញុំថាហេតុអ្វីយើងមិនទៅព្រះវិហារទៀត និងហេតុអ្វីខ្ញុំមិនទទួលបុណ្យជ្រមុជទឹក ។

កាលដែលខ្ញុំបានពន្យល់ពួកគាត់ពីបំណងប្រាថ្នារបស់ខ្ញុំដើម្បីទទួលបុណ្យជ្រមុជទឹក វាបានធ្វើឲ្យពួកគាត់រំជួលចិត្ត ហើយយើងបានចាប់ផ្ដើមទៅព្រះវិហារម្ដងទៀត ។ វាមានអារម្មណ៍ល្អ ។ ម៉ាក់របស់ខ្ញុំជាគំរូដ៏ល្អ ហើយជាអ្នកបំផុសគំនិតខ្ញុំ ។ គាត់មានទីបន្ទាល់ដ៏រឹងមាំមួយ ហើយអានព្រះគម្ពីរជាញឹកញាប់ ។

ក្រោយមក យើងបានប្ដូរទៅនៅប្រទេសវ៉េណេស៊ុយអេឡា ជាប្រទេសរបស់ប៉ាខ្ញុំ ។ យើងបានរស់នៅទីនោះពីរឆ្នាំ ហើយដោយសារតែការលំបាកផ្នែកសេដ្ឋកិច្ច យើងបានប្រឈមនឹងឧបសគ្គជាច្រើន ។ ប៉ុន្តែមានរឿងរ៉ាវល្អៗផងដែរ ។ ខ្ញុំចូលចិត្តម្ហូប ហើយខ្ញុំមានគ្រួសារនៅទីនោះ ដែលអន្ទះសាចង់ជួបខ្ញុំ ។ ពួកគាត់ជាមនុស្សដ៏រាបសា ហើយយើងបានទៅព្រះវិហារជាមួយគ្នា ហើយបានទទួលអារម្មណ៍ពីព្រះវិញ្ញាណ ។

ទោះបីជាយើងបានទៅព្រះវិហារ ហើយខ្ញុំអាចទទួលអារម្មណ៍ពីព្រះវិញ្ញាណ ខ្ញុំបានដឹងថា គ្រួសារខ្ញុំ និងខ្ញុំនៅខ្វះអ្វីមួយ ។ ខ្ញុំពិតជាមានអារម្មណ៍ថា យើងត្រូវផ្សារភ្ជាប់ជាក្រុមគ្រួសារអស់កល្បជានិច្ច ។ នៅព្រឹកថ្ងៃអាទិត្យមួយ ប៊ីស្សពបានអញ្ជើញអ្នកគ្រប់គ្នានៅក្នុងក្រុមជំនុំឲ្យអានព្រះគម្ពីរមរមនមុនដាច់ឆ្នាំ ។ ខ្ញុំបានដឹងថា ការណ៍នេះនឹងជួយឪពុកម្ដាយខ្ញុំ និងខ្ញុំរស់នៅតាមដំណឹងល្អកាន់តែពេញលេញ ។ បន្តិចម្ដងៗ កាលដែលយើងអានព្រះគម្ពីរមរមន ព្រះអង្គសង្គ្រោះ




រចនារូបភាពដោយ ផលលីន ហ្វេសុន

*នេះគឺជារឿងអំពីរបៀបដែលខ្ញុំបានចូលសាសនាចក្រ ហើយគ្រួសារខ្ញុំបានក្លាយជាអ្នកសកម្មនៅក្នុងដំណឹងល្អ ។*



បានចាប់ផ្ដើមប្រទានដល់យើងនូវការចេះដឹង និងពរជ័យបន្ថែមទៀត ហើយយើងបានបន្តអានព្រះគម្ពីរជារៀងទាត់ ។

មិនយូរប៉ុន្មាន ខ្ញុំបានទទួលបុណ្យជ្រមុជទឹក ។ ខ្ញុំពិតជាអាចទទួលអារម្មណ៍ពីព្រះវិញ្ញាណនៅក្នុងជីវិតខ្ញុំ ហើយឪពុកម្ដាយខ្ញុំក៏បានទទួលផងដែរ ។ ទីបន្ទាល់របស់ខ្ញុំចាប់ផ្ដើមលូតលាស់បន្ថែមទៀត ។ យើងបានប្ដូរមកនៅរដ្ឋហ្វ្លរីដា ស.រ.អា. ហើយយើងត្រូវតែធ្វើការផ្លាស់ប្ដូរ និងការលះបង់ជាច្រើនម្ដងទៀត គឺដូចជាពេលយើងបានចាកចេញពីប្រទេសអេស្ប៉ាញអញ្ចឹង ។ ប៉ុន្តែទីបន្ទាល់របស់យើងលូតលាស់កាន់តែរឹងមាំឡើងៗ ។ យើងបានទៅព្រះវិហារជារៀងរាល់សប្ដាហ៍ ហើយបន្តអានព្រះគម្ពីរ ។

បន្ទាប់ពីកិច្ចប្រឹងប្រែងជាច្រើន និងការអានព្រះគម្ពីរជាច្រើន អធិស្ឋាន និងជ្រើសរើសត្រូវ យើងចង់ផ្សារភ្ជាប់ជាគ្រួសារដ៏អស់កល្បជានិច្ចមួយ ។ យើងបាននិយាយជាមួយប៊ីស្សពយើង ហើយទោះបីជាវាត្រូវការពេលវេលាយ៉ាងច្រើនក្ដី ថ្ងៃនោះបានមកដល់ ។ យើងមានចិត្តរំភើបណាស់ក្នុងការចូលទៅក្នុងព្រះវិហារបរិសុទ្ធ ។

ខ្ញុំបានធ្វើបុណ្យជ្រមុជទឹក ពេលខ្ញុំរង់ចាំឪពុកម្ដាយខ្ញុំបញ្ចប់កិច្ចការព្រះវិហារបរិសុទ្ធសម្រាប់ខ្លួនពួកគាត់ ។ ខ្ញុំបានមានអារម្មណ៍ដូចជាខ្ញុំបានទទួលបុណ្យជ្រមុជទឹកម្ដងទៀតអញ្ចឹង ។ ខ្ញុំពិតជាសប្បាយចិត្តណាស់ ដែលខ្ញុំអាចជួយដល់មនុស្សដែលនៅម្ខាងទៀតនៃវាំងនន ។ ឥឡូវនេះគ្រួសារខ្ញុំ និងខ្ញុំទៅព្រះវិហារបរិសុទ្ធជារៀងរាល់សប្ដាហ៍ ។ ខ្ញុំធ្វើបុណ្យជ្រមុជទឹកជាទៀងទាត់ ព្រោះខ្ញុំចូលចិត្តជួយនៅកន្លែងនោះ ។ ខ្ញុំសប្បាយចិត្តខ្លាំងណាស់ ដែលខ្ញុំបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធនឹងឪពុកម្ដាយខ្ញុំអស់កល្បជានិច្ច ហើយមានឱកាសរស់នៅជាមួយពួកគាត់ជារៀងរហូត ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា.*





*ព្រះវរបិតាសួគ៌មានកិច្ចការដ៏អស្ចារ្យ
មួយសម្រាប់ក្មួយៗធ្វើ នៅក្នុង
ការរៀបចំសម្រាប់ការយាងមក
ជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។*

# ខួបលើកទី ១៥០

## នៃអង្គការយុវនារី

**ដោយ សិស្ទើរ ប៊ូនី អេច ខ័រឌុន**
ប្រធានយុវនារីទូទៅ

កាលដែលខ្ញុំគិតអំពីការណ៍អស្ចារ្យទាំងឡាយដែលព្រះវរបិតាសួគ៌បានធ្វើសម្រាប់បុត្រាបុត្រីទ្រង់ ដួងចិត្តខ្ញុំបានពោរពេញទៅដោយភាពអស្ចារ្យ និងការដឹងគុណទាំងស្រុងចំពោះក្ដីស្រឡាញ់ដ៏ច្រើនលើសលុបដែលព្រះអម្ចាស់មានចំពោះបុត្រីទ្រង់ ។ ទ្រង់ស្រឡាញ់ក្មួយៗ !

ហើយដោយសារតែទ្រង់ស្រឡាញ់ក្មួយៗ ១៥០ ឆ្នាំកន្លងមកនេះ ទ្រង់បានបំផុសគំនិតដល់ថ្នាក់ដឹកនាំសាសនាចក្រឲ្យបង្កើតអង្គការយុវនារី ដើម្បីជួយក្មួយៗក្លាយជាមនុស្សដែលព្រះចង់ឲ្យក្មួយប្រែក្លាយ ។ ព្យាការី ព្រិកហាំ យ៉ង់ ( ១៨០១–៧៧ ) បានលើកទឹកចិត្តយើងឲ្យពង្រឹងទីបន្ទាល់របស់យើងដោយការរស់នៅតាមដំណឹងល្អ ៖ « មានតម្រូវការមួយសម្រាប់បុត្រីវ័យក្មេងនៃវង្សអ៊ីស្រាអែល ដើម្បីទទួលបានទីបន្ទាល់ដ៏រស់រវើកមួយអំពីសេចក្ដីពិត ។ . . . ខ្ញុំមានបំណងចង់ឲ្យក្មេងស្រីរបស់យើងទទួលបាននូវចំណេះដឹងមួយអំពីដំណឹងល្អដោយខ្លួនពួកគេផ្ទាល់ » ។[1] លោកក៏បានមានប្រសាសន៍ផងដែរថា « ទីបន្ទាល់បន្ថែមទៀតត្រូវបានទទួលដោយបាតជើង ជាជាងដោយការលត់ជង្គង់ » ។[2]

អង្គការយុវនារីបានធ្វើការសម្របសម្រួលអស់រយៈពេលជាច្រើនឆ្នាំនេះដើម្បីបំពេញតាមតម្រូវការនៃគ្រានោះ ។ ប៉ុន្តែទោះបីជាកម្មវិធីរបស់វាត្រូវបានសម្របសម្រួល ក៏ទិសដៅរបស់វាសម្រាប់យុវនារីពុំបានផ្លាស់ប្ដូរឡើយ—គឺដើម្បីជួយក្មួយៗឲ្យទទួលបានទីបន្ទាល់ដ៏រស់រវើកមួយ ហើយឈានឆ្ពោះទៅមុខនៅផ្លូវនៃសេចក្ដីសញ្ញាជាមួយនឹងសេចក្ដីជំនឿ ។ កាលដែលក្មួយៗរៀនស្គាល់ថាខ្លួនឯងជានរណា ហើយប្រព្រឹត្តនៅក្នុងសេចក្ដីជំនឿ នោះក្មួយៗនឹងទទួលពរជ័យដែលព្រះវរបិតាសួគ៌មានក្នុងឃ្លាំងសម្រាប់ក្មួយៗ ។

### ថ្នាក់ទាំងឡាយនៃក្រុមយុវនារីអំឡុងពេលជាច្រើនឆ្នាំមកនេះ

ពេលថ្នាក់យុវនារីទើបតែចាប់ផ្ដើម វាត្រូវបានហៅថា « សមាគមន៍កាត់បន្ថយ » ដោយមានគោលដៅដើម្បី « ធ្វើឲ្យប្រសើរឡើងនៅក្នុងគ្រប់អ្វីៗដែលល្អ និងស្រស់ស្អាត » ។ មកទល់នឹងដើមទសវត្សរ៍ឆ្នាំ ១៩០០ វាបានក្លាយជាសមាគមន៍កែលម្អទៅវិញទៅមកសម្រាប់ស្ត្រីវ័យក្មេង ហើយមិនយូរប៉ុន្មានថ្នាក់ទាំងឡាយបានបញ្ចូលយុវនារីដែលមានអាយុ ១២ ដល់ ២៤ ឆ្នាំ ។ ឈ្មោះនៃថ្នាក់ទាំងឡាយបានផ្លាស់ប្ដូរក្នុងរយៈពេលកន្លងមកនេះ រួមមាន នារីបោះជំរុំភ្លើង ប៊ីហៃ ហ្កាដៀន និងគ្លីនន័រ ។ កាលដែលសាសនាចក្របានលូតលាស់ ហើយយុវនារីបានជួបជុំនៅប្រទេស និងភាសាផ្សេងៗ ពួកគេបានធ្វើអស់ពីសមត្ថភាពដើម្បីសម្របសម្រួល ឧទាហរណ៍ឈ្មោះដូចជា

រូបថតដោយ ឡេស្លី និលសុន

ម៉ែម៉េត ក្លាយទៅជា « Rosenmädchen » ( នារីផ្កាកូលាប ) ជាភាសាអាល្លឺម៉ង់ ។

សព្វថ្ងៃនេះ ដោយមានយុវនារីនៅស្ទើរតែគ្រប់ប្រទេស នោះថ្នាក់ទាំងឡាយត្រូវបានរៀបចំឡើងយោងទៅតាមតម្រូវការរបស់វួដ ឬសាខានីមួយៗ ហើយទាំងអស់នោះត្រូវបានស្គាល់ជាឈ្មោះរួមមួយថា យុវនារី ។

តម្រូវការសម្រាប់កម្មវិធីយុវនារី ក៏បានផ្លាស់ប្ដូរអស់ជាច្រើនឆ្នាំមកនេះផងដែរ ។ នេះជាការផ្លាស់ប្ដូរមួយចំនួន ។

## កម្មវិធីកុមារ និងយុវវ័យ

កាលដែលក្មួយៗមើលទៅលើតម្រូវការទាំងនេះតាមរយៈភ្នែកខាងវិញ្ញាណ នោះក្មួយៗនឹងកត់សម្គាល់ឃើញថា វាមាននូវគំនិតទូទៅមួយ ។ អតីតកាល និងបច្ចុប្បន្នមកជាមួយគ្នា រួមគ្នាជួយដល់យុវនារីឲ្យខិតមកកាន់តែជិតព្រះយេស៊ូវគ្រីស្ទ ហើយអភិវឌ្ឍខាងវិញ្ញាណ ខាងបញ្ញា ខាងសង្គម និងខាងរាងកាយ ។

នៅក្នុងឆ្នាំ ២០១៩ កម្មវិធីអភិវឌ្ឍផ្ទាល់ខ្លួនថ្មីមួយត្រូវបានណែនាំដើម្បីអញ្ជើញក្មួយៗឲ្យមានទាំងភាពខ្លួនទីពឹងខ្លួន និងទីពឹងព្រះអង្គសង្គ្រោះ ។ ក្មួយៗត្រូវបានអញ្ជើញឲ្យស្វែងរកព្រះវិញ្ញាណបរិសុទ្ធ ហើយដាក់គោលដៅខ្លួនឯងផ្ទាល់ កាលដែលក្មួយៗពុះពារដើម្បីប្រែក្លាយកាន់តែដូចព្រះអង្គសង្គ្រោះរបស់យើង ព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំចូលចិត្តការទុកចិត្តដែលកម្មវិធីនេះបង្ហាញនៅក្នុងខ្លួនក្មួយៗ ជាយុវនារីនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

ជាមួយនឹងការគាំទ្រពីគណៈប៊ីស្សព និងគណៈប្រធានយុវនារីរបស់ក្មួយៗ ក្មួយៗក៏ត្រូវបានដឹកនាំដោយគណៈប្រធានថ្នាក់ផងដែរ—មិត្តភក្ដិរបស់ក្មួយៗដែលត្រូវបានហៅ និងញែកចេញដើម្បីដាក់ផែនការ និងអនុវត្តកម្មវិធីយុវនារី ។ មានយុវនារីចំនួនច្រើនជាងកន្លះលាននាក់នៅជុំវិញពិភពលោកសព្វថ្ងៃនេះ ដែលកំពុងត្រូវបានដឹកនាំដោយមិត្តភក្ដិរបស់ពួកគេ !



**ក្នុងឆ្នាំ ១៩១៥ ៖**

- រៀនបំពាក់កែបសេះ និងគ្រប់គ្រងសេះមួយក្រុម ។
- ទន្ទេញវគ្គបទគម្ពីរ ។

**ចាប់ពីទសវត្សរ៍ឆ្នាំ ១៩៤០ ដល់ ១៩៦០ ៖**

- បង្កើនទំនុកចិត្តរបស់អ្នកដោយការមានឥរិយាបទល្អ ( ការអង្គុយ ការឈរ និងការដើរ ) ។
- អនុវត្តភាពរាបសាដែលជាសញ្ញាសម្គាល់របស់ស្ត្រី ។

**នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ៖**

- អានកូនសៀវភៅពួកអ្នកផ្សព្វផ្សាយសាសនាពីរក្បាល ហើយបង្រៀនមិត្តភក្ដិ ឬសាច់ញាតិម្នាក់ទៀតនូវអ្វីដែលអ្នកបានរៀន ។
- អនុវត្តលំហាត់ប្រាណយ៉ាងហោចណាស់ ៣០ នាទីក្នុងមួយថ្ងៃ ប្រាំថ្ងៃមួយសប្ដាហ៍ រយៈពេលបីសប្ដាហ៍ ។

**ក្នុងឆ្នាំ ២០០៩ ៖**

- សិក្សាអំពីសារៈសំខាន់នៃព្រហ្មចារីភាព និងគុណធម៌ ។
- អានព្រះគម្ពីរមរមនទាំងមូល ។ កត់ត្រាគំនិតរបស់អ្នកនៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក ។

**ក្នុងឆ្នាំ ២០២០ ៖**

- ណែនាំពីកម្មវិធីថ្មី

រចនារូបភាពដោយ ខូរី អេចបឺត

យុវនារីទាំងអស់ត្រូវបានបង្រួបបង្រួមគ្នាដោយបាវចនាមួយ ដែលមាននូវគោលការណ៍គ្រឹះទាំងនេះ ៖ ក្មួយគឺជាបុត្រីសំណព្វរបស់ព្រះបិតាមាតាសួគ៌ ក្មួយជាសិស្សក្នុងសេចក្ដីសញ្ញារបស់ព្រះយេស៊ូវគ្រីស្ទ ក្មួយស្វែងរក ហើយធ្វើតាមវិវរណៈផ្ទាល់ខ្លួនដែលបានមកតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ហើយក្មួយគឺជាសាក្សីដ៏ចែងចាំងនៃព្រះនៅពេលក្មួយព្យាយាមក្លាយដូចជាព្រះអង្គសង្គ្រោះរបស់យើង គឺព្រះយេស៊ូវគ្រីស្ទ ហើយផ្ដល់ការងារបម្រើដល់អ្នកដទៃទៀតនៅក្នុងព្រះនាមដ៏បរិសុទ្ធរបស់ទ្រង់ ។

## ក្មួយមានគេស្រឡាញ់ និងត្រូវការ !

ក្នុងនាមជាបុត្រីជាទីស្រឡាញ់របស់ព្រះវរបិតាសួគ៌ដែលមានព្រះជន្មរស់នៅ និងពោរពេញដោយក្ដីស្រឡាញ់ ក្មួយៗត្រូវបានរៀបចំជាពិសេសដើម្បីក្លាយជា « អ្នកសង្គ្រោះនៅលើភ្នំស៊ីយ៉ូន » ។[៣] ដូចដែលព្យាការី រ័សុល អិម ណិលសុន បានមានប្រសាសន៍ថា « ព្យាការីគ្រប់រូបបាននិយាយអំពីជំនាន់*របស់យើង* នៅពេលដែលអ៊ីស្រាអែលនឹងត្រូវបានប្រមូលផ្ដុំ ហើយពិភពលោកនឹងរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។ ចូរគិតពីចំណុចនេះ ! ក្នុងចំណោមមនុស្សទាំងអស់ដែលធ្លាប់រស់នៅលើផែនដីនេះ *ពួកយើង*គឺជាមនុស្សដែលបានចូលរួមនៅក្នុងព្រឹត្តការណ៍នៃការប្រមូលផ្ដុំដ៏អស្ចារ្យចុងក្រោយនេះ » ។[៤]

នេះគឺជាការអញ្ជើញដ៏ពិសិដ្ឋឲ្យចូលរួមក្នុងកិច្ចការព្រះវិហារបរិសុទ្ធ និងពង្សប្រវត្តិ បម្រើនៅក្នុងមុខតំណែងថ្នាក់ដឹកនាំ ផ្ដល់ការងារបម្រើដល់បងប្អូនស្រីរបស់ក្មួយៗ និងចែកចាយទីបន្ទាល់របស់ក្មួយៗជាមួយនឹងគ្រួសារ និងមិត្តរបស់ក្មួយៗ ។ ក្មួយមានគេស្រឡាញ់ និងក្មួយៗមានគេត្រូវការ !

មិត្តជាទីស្រឡាញ់របស់ខ្ញុំអើយ ព្រះវរបិតាសួគ៌មានកិច្ចការដ៏អស្ចារ្យមួយសម្រាប់ក្មួយៗធ្វើ នៅក្នុងការរៀបចំសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះរបស់យើងគឺព្រះយេស៊ូវគ្រីស្ទ ! ក្មួយៗគឺជាផ្នែកមួយដ៏សំខាន់នៃកិច្ចការនោះ ។ ទ្រង់ស្រឡាញ់ក្មួយៗ ទ្រង់មានព្រះទ័យចង់ឲ្យក្មួយៗរួមចំណែកក្នុងកិច្ចការរបស់ទ្រង់ ទ្រង់ទុកព្រះទ័យលើក្មួយៗ !

ខ្ញុំសូមបន្ថែមជំនឿ និងការទុកចិត្តរបស់ខ្ញុំលើក្មួយៗ ទៅលើអ្វីដែលព្យាការីជាទីស្រឡាញ់របស់យើង គឺប្រធានណិលសុន ដែលបានប្រកាសថា « ចៅៗគឺស្ថិតនៅក្នុងចំណោមមនុស្សល្អបំផុតដែលព្រះអម្ចាស់*ធ្លាប់បាន*បញ្ជូនមកកាន់លោកិយនេះ ។ ចៅៗមានសមត្ថភាពដើម្បីកាន់តែឆ្លាត និងកាន់តែឈ្លាសវៃ ហើយមានឥទ្ធិពលទៅលើពិភពលោកជាងជំនាន់មុនៗ ! »[៥]

ខ្ញុំសូមអធិស្ឋានថា ក្មួយៗនឹងអនុញ្ញាតឲ្យពាក្យពេចន៍នៃបាវចនាក្រុមយុវនារីជ្រាបចូលក្នុងដួងចិត្តរបស់ក្មួយៗ ហើយចូលរួម ហើយតាំងចិត្តធ្វើកម្មវិធីថ្មីនេះ ដោយឱបក្រសោបយកគ្រប់ឱកាសដើម្បីខិតកាន់តែជិតនឹងព្រះអង្គសង្គ្រោះ ហើយរៀនបន្ថែមទៀតពីទ្រង់ ។ ចូរក្លាយជាមនុស្សដែលទ្រង់សព្វព្រះទ័យឲ្យក្មួយៗប្រែក្លាយ ។ ខ្ញុំដឹងថាពេលដែលក្មួយៗធ្វើដូច្នោះ ជីវិតរបស់ក្មួយៗនឹងត្រូវបានបំពេញដោយឱកាសទាំងឡាយដើម្បីចែកចាយពន្លឺរបស់ទ្រង់ និងក្ដីស្រឡាញ់របស់ទ្រង់ជាមួយគ្រួសារក្មួយ មិត្តភក្ដិ និងគ្រប់គ្នានៅជុំវិញក្មួយ ។ កាលដែលក្មួយៗពុះពារធ្វើតាមទ្រង់ នោះទីបន្ទាល់របស់ក្មួយៗនឹងក្លាយកាន់តែរឹងមាំ ហើយមិនរង្គោះរង្គើឡើយ ។ ■

**កំណត់ចំណាំ**

១. ព្រិកហាំ យ៉ង់ នៅក្នុង A Century of Sisterhood: Chronological Collage, 1869–1969 ( ឆ្នាំ ១៩៦៩ ) ទំព័រ ៨ ។
២. ព្រិកហាំ យ៉ង់ នៅក្នុង ស៊ូសា យ៉ង់ ហ្គេតស៍ History of the Young Ladies' Mutual Improvement Association of the Church of Jesus Christ of Latter-day Saints from November 1869 to June 1910 ( ឆ្នាំ ១៩១១ ) ទំព័រ ៩ ។
៣. ឃ្វីនថិន អិល យុក សន្និសីទទូទៅខែ មេសា ឆ្នាំ ២០១៤ ( *Liahona* ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ៤៨ ) ។
៤. រ័សុល អិម ណិលសុន « សង្ឃឹមអ៊ីស្រាអែល » ( ការប្រជុំធម្មនិដ្ឋានទូទាំងពិភពលោកសម្រាប់យុវវ័យ ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១៨ ) ទំព័រ ៨ HopeofIsrael .ChurchofJesusChrist.org ។
៥. រ័សុល អិម ណិលសុន « សង្ឃឹមអ៊ីស្រាអែល » ទំព័រ ១៦–១៧ ។



រូបថតដោយ ម៉ាត់ រីអ៊ែ

# ក្រុមយុវនារី

## ប្រារព្ធខួប ១៥០ ឆ្នាំ

**ដោយ អាម៉ានដា ដាន់**
ទស្សនាវដ្ដីសាសនាចក្រ

អង្គការយុវនារីឈានចូលដល់ ១៥០ ឆ្នាំហើយនៅឆ្នាំនេះ ហើយវាដល់ពេលប្រារព្ធអបអរហើយ ! សូមក្រឡេកមើលការពិតទាំងនេះអំពីរបៀបដែលអង្គការនេះបានវិវត្តតាំងពីឆ្នាំ ១៨៧០ រហូតដល់សព្វថ្ងៃនេះ អ្វីដែលយុវវ័យដូចជាប្អូនៗកំពុងតែធ្វើដើម្បីចូលរួមនៅក្នុងក្រុមយុវនារីឥឡូវនេះ និងរបៀបដែលប្អូនៗអាចត្រូវបានបំផុសដោយពួកយុវនារីនៅក្នុងប្រវត្តិសាស្ត្រដែលបានបង្ហាញភាពក្លាហាន និងសេចក្ដីជំនឿ ។

### ឆ្នាំ ១៨៧០-១៩២០






**ឈ្មោះ ៖** ស្ថាប័នស្ត្រីវ័យក្មេងនៃសមាគមន៍សហការកាត់បន្ថយរបស់ស្ត្រី ត្រូវបានបង្កើតឡើងជាផ្លូវការនៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៨៧០ ក្រោមការដឹកនាំរបស់ព្រិកហាំ យ៉ង់ ។[១] ឈ្មោះនោះត្រូវបានផ្លាស់ប្ដូរទៅជាសមាគមន៍កែលម្អទៅវិញទៅមកសម្រាប់ស្ត្រីវ័យក្មេង នៅក្នុងឆ្នាំ ១៨៧៧ ។[២]

**អង្គការ និងថ្នាក់ទាំងឡាយ ៖** កម្មវិធីនារីប៊ីហៃ ត្រូវបានបង្កើតឡើងជាកម្មវិធីរដូវក្ដៅសម្រាប់ក្មេងស្រីអាយុ ១៤ ឆ្នាំ និងច្រើនជាងនោះ ។

**ការអភិវឌ្ឍ និងការទទួលស្គាល់ ៖** សៀវភៅក្បួនខ្នាតប៊ីហៃត្រូវបានបោះពុម្ពនៅក្នុងឆ្នាំ ១៩១៥ ដោយមានគូសបញ្ជាក់នូវ « ផ្នែក » ចំនួនប្រាំពីរនៃការអភិវឌ្ឍផ្ទាល់ខ្លួន ៖ សាសនា គេហដ្ឋាន សុខភាព សិល្បៈក្នុងស្រុក សកម្មភាពក្រៅផ្ទះ ជំនួញ និងសេវាកម្មសាធារណៈ ។[៣]

**ទស្សនាវដ្ដី និងកំណត់ហេតុ ៖** ច្បាប់ដំបូងនៃ *កំណត់ហេតុយុវនារី*ត្រូវបានបោះពុម្ពនៅក្នុងឆ្នាំ ១៨៨៩ ។[៤] សមាគមន៍កែលម្អទៅវិញទៅមកជាច្រើនក្នុងតំបន់ ( ឬ ស.ក.ទ. ) ផលិតសារព័ត៌មានដែលសរសេរដោយដៃ និងមានតែមួយ ឬពីរច្បាប់ប៉ុណ្ណោះដើម្បីឲ្យក្មេងស្រីទាំងឡាយចែកគ្នាអាន ។

### ឆ្នាំ ១៩២០-១៩៧០






**ឈ្មោះ ៖** សមាគមន៍កែលម្អទៅវិញទៅមកសម្រាប់ស្ត្រីវ័យក្មេង ផ្លាស់ប្ដូរទៅជា សមាគមន៍កែលម្អទៅវិញទៅមកសម្រាប់យុវនារី នៅក្នុងឆ្នាំ ១៩៣៤ ។[៥]

**អង្គការ និងថ្នាក់ទាំងឡាយ ៖** មានថ្នាក់ចំនួនពីរ គឺ នារីប៊ីហៃ សម្រាប់ក្មេងស្រីដែលក្មេងៗជាង និង គ្លីនន័រ សម្រាប់ក្មេងស្រីដែលមានអាយុច្រើនជាង ។ អាយុដើម្បីចូលក្នុងកម្មវិធីនោះផ្លាស់ប្ដូរពី ១៤ ទៅ ១២ ឆ្នាំ ។ នៅក្នុងឆ្នាំ ១៩៥០ ថ្នាក់ម៉ៃម៉េតត្រូវបានណែនាំឲ្យស្គាល់ ។

**ការអភិវឌ្ឍ និងការទទួលស្គាល់ ៖** ការទទួលស្គាល់គ្លីនន័រមាស កំណត់ពីការសម្រេចបានខ្ពស់បំផុតដែលយុវនារីអាចទទួលបាននៅក្នុងកម្មវិធីនោះ ។







## ឆ្នាំ ១៩៧០-២០១៩




**ទស្សនាវដ្ដី និងកំណត់ហេតុ ៖** *កំណត់ហេតុយុវនារី* បញ្ចូលជាមួយនឹងទស្សនាវដ្ដី *Improvement Era* សម្រាប់យុវវ័យទាំងអស់នៅក្នុងឆ្នាំ ១៩២៩ ។[៦]



**ឈ្មោះ ៖** សមាគមន៍កែលម្អទៅវិញទៅមកសម្រាប់យុវនារីផ្លាស់ប្ដូរទៅជា អង្គការយុវនារី នៅក្នុងឆ្នាំ ១៩៧៤ ។[៧]




**អង្គការ និងថ្នាក់ទាំងឡាយ ៖** មកដល់ត្រឹមឆ្នាំ ១៩៧២ អង្គការយុវនារីមានបីថ្នាក់គឺ ៖ ប៊ីហៃ ( អាយុ ១២–១៣ ឆ្នាំ ) ម៉ៃម៉េត ( អាយុ ១៤–១៥ ឆ្នាំ ) និងឡូរ៉េល ( អាយុ ១៦–១៧ ឆ្នាំ ) ។ ចាប់ផ្ដើមក្នុងឆ្នាំ ២០១៩ យុវនារីចូលរួមក្នុងថ្នាក់ប៊ីហៃនៅខែមករានៃឆ្នាំដែលពួកគេឈានចូលអាយុ ១២ ឆ្នាំ ។

**ការអភិវឌ្ឍ និងការទទួលស្គាល់ ៖** កម្មវិធីការអភិវឌ្ឍខ្លួន និងមេដាយត្រូវបានណែនាំឲ្យស្គាល់នៅក្នុងឆ្នាំ ១៩៧៧ ។ យុវនារីផ្ដល់តម្លៃដល់ សេចក្ដីជំនឿ និស្ស័យនៃព្រះ គុណសម្បត្តិផ្ទាល់ខ្លួន ចំណេះវិជ្ជា ការជ្រើសរើស និងការទទួលខុសត្រូវ កិច្ចការល្អ និងសេចក្ដីទៀងត្រង់ ត្រូវបានបន្ថែមនៅក្នុងឆ្នាំ ១៩៨៧ ។[៨] គុណធម៌ត្រូវបានបន្ថែមនៅក្នុងឆ្នាំ ២០០៨ ។[៩]

**ទស្សនាវដ្ដី និងកំណត់ហេតុ ៖ ទស្សនាវដ្ដី** *New Era* សម្រាប់យុវវ័យបានចាប់ផ្ដើមការបោះពុម្ពជាភាសាអង់គ្លេសនៅក្នុងឆ្នាំ ១៩៧១ ហើយ *លីអាហូណា* ផ្ដល់នូវអត្ថបទទាំងឡាយសម្រាប់យុវវ័យនៅក្នុងភាសាជាច្រើន ។[១០]



រូបថតយុវនារីពាក់មេដាយការអភិវឌ្ឍខ្លួន ដោយ អាលីស្សា ស័រវ៉ា
រូបថតរបស់យុវនារី ទទួលបានសិទ្ធិអនុញ្ញាតពីបណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ



### ការពិតសប្បាយៗ

១. សៀវភៅក្បួនខ្នាតប៊ីហៃឆ្នាំ ១៩១៥ អនុញ្ញាតឲ្យយុវនារីជ្រើសរើសគម្រោងចេញពីជម្រើសជាង ៣០០ ខុសៗគ្នា ។ គម្រោងមួយចំនួនទាំងនោះរួមមាន ការថែទាំសំបុកឃ្មុំអស់មួយរដូវ ការរក្សាផ្ទះសម្បែងកុំឲ្យមានរុយរយៈពេលពីរសប្ដាហ៍ ឬការគ្រួសដើមសេចប្រ័សចេញពីដីយ៉ាងហោចណាស់ ០.២០ ហិចតា ។[១២]



## ឆ្នាំ ២០២០









**ឈ្មោះ ៖** ឈ្មោះបន្តនៅជា អង្គការយុវនារី ។

**អង្គការ និងថ្នាក់ទាំងឡាយ ៖** ថ្នាក់ទាំងឡាយត្រូវបានរៀបចំឡើងនៅក្នុងវួដ ឬសាខានីមួយៗទៅតាមតម្រូវការរបស់វួដ ឬសាខានោះ ហើយត្រូវបានកំណត់ជាស្លាករួមថា « យុវនារី » ( ឧទាហរណ៍ « យុវនារី ១២ » « យុវនារី ១២–១៥ » ឬគ្រាន់តែ « យុវនារី » ប្រសិនបើពួកគេទាំងអស់គ្នាជួបក្នុងថ្នាក់តែមួយ ) ។

**ការអភិវឌ្ឍ និងការទទួលស្គាល់ ៖** កម្មវិធី កុមារ និងយុវវ័យ ជំនួសឲ្យកម្មវិធីការរីកចម្រើនផ្ទាល់ខ្លួន ។ កម្មវិធីថ្មីនេះជំរុញឲ្យមានឱកាសផ្ទាល់ខ្លួនដើម្បីលូតលាស់នៅក្នុងចំនុចទាំងឡាយនៃការអភិវឌ្ឍផ្ទាល់ខ្លួន ការរៀនសូត្រដំណឹងល្អ និងការបម្រើ ព្រមទាំងសកម្មភាពទាំងឡាយ ។[១១]

**ទស្សនាវដ្ដី និងកំណត់ហេតុ ៖** ទស្សនាវដ្ដី *New Era* ជិតដល់ខួប ៥០ ឆ្នាំរបស់វាហើយ ។ ■



**កំណត់ចំណាំ**
១. សូមមើល « Timeline of Young Women History » history.ChurchofJesusChrist.org/landing/a-brief-timeline-of-young-women-history ។
២. សូមមើល « Young Women’s Timeline » *Mormon Women’s Studies Resource* បណ្ណាល័យ ហារ៉ូល ប៊ី លី សាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ ទីក្រុងប្រូវ៉ូ រដ្ឋយូថាហ៍ mormonwomen.lib.byu.edu/young-womens-portal/young-women-timeline ។
៣. សូមមើល « History of Young Women Recognition » history.ChurchofJesusChrist.org ។
៤. សូមមើល « Young Women’s Timeline » ។
៥. សូមមើល « Young Women’s Timeline » ។
៦. សូមមើល « Young Women’s Timeline » ។
៧. សូមមើល « Young Women’s Timeline » ។
៨. សូមមើល « Young Women’s Timeline » ។
៩. សូមមើល « New Young Women Value: Virtue » ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០០៨ thechurchnews.com ។
១០. សូមមើល « Young Women’s Timeline » ។
១១. សូមមើល ChildrenAndYouth.ChurchofJesusChrist.org ។
១២. សូមមើល « History of Young Women Recognition » ។
១៣. សូមមើល « History of Young Women Recognition » ។
១៤. សូមមើល « Young Women Classes and Symbols » ChurchofJesusChrist.org/young-women/personal-progress ។
១៥. សូមមើល « History of Young Women Recognition » ។
១៦. សូមមើល « The Annual Report of the Church » *Ensign* ខែ កក្កដា ឆ្នាំ ១៩៧២ ទំព័រ ១៣១–៣៣ ។
១៧. សូមមើល « Worldwide Statistics » newsroom.ChurchofJesusChrist.org/facts-and-statistics ។



២. នារីប៊ីហៃពីដើមស្លៀកពាក់ឯកសណ្ឋានដែលផ្ទៃម៉ូតដោយសមាគមន៍ក្នុងតំបន់នីមួយៗ ហើយនៅក្នុងឆ្នាំ ១៩២២ ពណ៌ផ្លូវការរបស់សមាគមន៍កែលម្អទៅវិញទៅមក គឺជាពណ៌មាស និងបៃតង ។[១៣]



៣. ឈ្មោះប៊ីហៃបានមកពីពួកអ្នកត្រួសត្រាយផ្លូវ ដែលបានឃើញសំបុកឃ្មុំថាជាសញ្ញានៃការធ្វើការ និងភាពសុខដុម ។ ម៉ៃម៉េតបានមកពីអក្សរកាត់នៃ Mutual Improvement Association គឺ MIA ។ ឈ្មោះឡូរ៉េលសំដៅដល់កម្រងផ្កាឡូរ៉េលដែលមានន័យថាកិត្តិយស និងការសម្រេច ។[១៤]

៤. រវាងទសវត្សរ៍ឆ្នាំ ១៩៤០ និង ១៩៦០ យុវនារីអាចទទួលបាននូវវត្ថុតំណាងដែលពួកគេដេរជាប់នឹងបន្ទះធៀងមួយហៅថា bandelo ដែលពួកគេពាក់ធៀងកាត់ទ្រូងពួកគេ ។ តម្រូវការមួយដើម្បីទទួលបានវត្ថុតំណាងគឺ « ព្យាយាមគេងលក់ឲ្យស្រួលឲ្យបានប្រាំបួនម៉ោងរាល់យប់នៅខែនេះ » ។[១៥]



៥. សមាជិកភាពសាសនាចក្រទូទៅកើនឡើងពី ១១០០០០ នាក់នៅក្នុងឆ្នាំ ១៨៧០[១៦] ទៅដល់ច្រើនជាង ១៦ លាននាក់គិតត្រឹមឆ្នាំ ២០២០[១៧]—សូមគិតមើលថាតើមានយុវនារីប៉ុន្មាននាក់នៅជុំវិញពិភពលោកឥឡូវនេះ !

# ដៃជំនួយរបស់ហារិន

ហារិន អាយុ ១៤ ឆ្នាំមកពីរដ្ឋយូថា ស.រ.អា. បានសម្រេចចិត្តដើម្បីប្រារព្ធអបអរការក្លាយជាយុវនារីម្នាក់នៅក្នុងសាសនាចក្រដោយការបម្រើដល់អ្នកដទៃទៀត ។

នាងនិយាយថា « វាបានចាប់ផ្តើមពីគំនិតតូចមួយ » ។ « ពូរបស់ខ្ញុំបានទៅប្រទេសបង់ក្លាដែសដើម្បីធ្វើកិច្ចការមនុស្សធម៌ ហើយបានរៀនពីការលំបាកដែលប្រជាជននៅទីនោះកំពុងជួបប្រទះ ។ ខ្ញុំចង់ជួយពួកគេ—ដូច្នេះខ្ញុំបានមើលក្នុងកម្មវិធី JustServe ហើយបានមានគំនិតដើម្បីធ្វើកញ្ចប់ដែលធ្វើដោយដៃសម្រាប់ជនភៀសខ្លួននៅទីនោះ » ។

ហារិនបានប្រមូលការបរិច្ចាគនានានៅសាលានាង បង្កើតទំព័រ GoFundMe ហើយសូម្បីតែបានយកធុងសម្រាមរបស់អ្នកជិតខាងចេញក្រៅដើម្បីជួយរៃអង្គាសប្រាក់សម្រាប់កញ្ចប់ទាំងនោះ ។ នាងនិយាយថា « ខ្ញុំយកធុងសម្រាមប្រហែល ២២ ចេញក្រៅ និងធុងវត្ថុអាចកែច្នៃឡើងវិញ ១១ ធុង ជារៀងរាល់ថ្ងៃច័ន្ទ និងអង្គារ » ។ « ជាធម្មតាខ្ញុំប្រើប្រាស់ប្រាក់ដែលខ្ញុំរកបាននោះសម្រាប់កម្មវិធីក្រុមចម្រៀងរបស់ខ្ញុំ និងដើម្បីសន្សំសម្រាប់បេសកកម្ម ប៉ុន្តែខ្ញុំបានសម្រេចចិត្តដើម្បីប្រើប្រាស់ប្រាក់របស់ខ្ញុំនៅខែនោះដើម្បីជួយទិញសម្ភារជំនួសវិញ » ។

បន្ទាប់មកហារិនបានចេញទៅទិញសម្ភារទាំងអស់ដែលនាងត្រូវការសម្រាប់កញ្ចប់ទាំងនោះ រួមមានទាំងស្រោមជើង ស្រោមដៃ កន្សែងបង់ក និងមួក ។ នាងបានប្រចកកញ្ចប់នីមួយៗ ហើយក៏បានទាក់ទងជាមួយនឹងនាយក Lifting Hands International ដើម្បីសម្របសម្រួលបញ្ជូនកញ្ចប់ទាំងនោះទៅប្រទេសបង់ក្លាដែស ។

« ពេលវេលាភាគច្រើនបំផុតនៅក្នុងគម្រោងរបស់ខ្ញុំគឺចំណាយទៅលើការរៀបចំកញ្ចប់ទាំងនោះ ។ ប៉ុន្តែរាល់ពេលដែលខ្ញុំដាក់របស់មួយចូលទៅក្នុងកញ្ចប់នោះ ខ្ញុំបានដឹងថា វានឹងបានទៅដល់នរណាម្នាក់ដែលត្រូវការ ហើយថាពួកគេនឹងទទួលពរយ៉ាងយូរដោយសារសម្ភារៈទាំងនោះ » ។



មកទល់នឹងពេលបញ្ចប់គម្រោងរបស់នាង ហារិនបានមានអារម្មណ៍ថា ទំនុកចិត្តរបស់នាងក្នុងសមត្ថភាពរបស់នាងដើម្បីបម្រើត្រូវបានស្ថាបនាឡើង ។ « ខ្ញុំបានរៀនពីការណ៍នេះថាខ្ញុំអាចជួយបានច្រើនប៉ុណ្ណា បើខ្ញុំព្យាយាមអស់ពីសមត្ថភាពខ្ញុំនោះ ។ ខ្ញុំក៏មានអារម្មណ៍អាណិតអាសូរដល់មនុស្សដែលខ្ញុំកំពុងជួយផងដែរ ដែលបានជួយខ្ញុំឲ្យមានអារម្មណ៍កាន់តែខិតជិតនឹងព្រះអង្គសង្គ្រោះ ហើយស្គាល់អារម្មណ៍ខ្លះដែលទ្រង់មានចំពោះយើង » ។

កាលដែលយើងប្រារព្ធអបអរខួបរបស់អង្គការយុវនារី យើងម្នាក់ៗអាចចងចាំថាយើងជាគំរូនៃព្រះគ្រីស្ទ ។ ដូចជាហារិនដែរ យើងអាចធ្វើជាជំនួយដ៏ធំដល់មនុស្សដទៃទៀត ពេលយើងព្យាយាមអស់ពីសមត្ថភាពយើងដើម្បីបម្រើដូចជាទ្រង់ធ្វើ ។ ■

# តើខ្ញុំអាចជួយមិត្តភក្តិរបស់ខ្ញុំ ដែលហាក់ដូចជាមានការបាក់ទឹកចិត្តដោយរបៀបណា ?



*« ដូច្នេះតើអ្នកឆ្លើយតបបានល្អប៉ុណ្ណា ពេលបញ្ហាផ្លូវចិត្តកើតមានចំពោះអ្នក ឬមនុស្សដែលអ្នកស្រឡាញ់នោះ ? លើសពីនេះទៀត សូមកុំបាត់បង់ជំនឿអ្នកលើព្រះវរបិតាអ្នកដែលទ្រង់ស្រឡាញ់អ្នកលើសពីអ្នកអាចយល់បានទៅទៀតនោះឡើយ ។ . . .*

*« . . . អ្វីក៏ដោយដែលអ្នកអាច ឬមិនអាចផ្ដល់ឲ្យបាន អ្នកអាចផ្ដល់ការអធិស្ឋាន ហើយអ្នកផ្ដល់ ‹ ការស្រឡាញ់ស្មោះត្រង់ › » ។*

អែលឌើរ ជេហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Like a Broken Vessel »*Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ៤០, ៤១ ។



**អញ្ជើញពួកគេឲ្យនៅជាមួយអ្នក**

សូមអញ្ជើញពួកគេឲ្យធ្វើអ្វីសប្បាយៗជាមួយអ្នក ។ សូមកុំបាក់ទឹកចិត្ត បើពួកគេមិនឆ្លើយតបតាមរបៀបដែលអ្នកចង់បាននោះ ។ ជួនកាល គ្រាន់តែការអញ្ជើញឲ្យធ្វើអ្វីមួយ ឬសូម្បីតែការដឹងថាអ្នកចង់នៅជាមួយពួកគេ នឹងជួយពួកគេឲ្យមានអារម្មណ៍ប្រសើរឡើង ។

*អាលីស្សា ហ្វេស អាយុ ១៦ ឆ្នាំ រដ្ឋ វ៉ាស៊ីនតោន ស.រ.អា.*



**បញ្ជាក់អះអាងដល់ពួកគេ**

ពេលខ្ញុំនៅជាមួយមិត្តភក្ដិដែលធ្លាក់ទឹកចិត្ត ខ្ញុំមិនមើលស្រាលចំពោះបញ្ហារបស់ពួកគេទេ ។ ប៉ុន្តែខ្ញុំជួយសម្រាលការលំបាករបស់ពួកគេ ។ ខ្ញុំព្យាយាមបញ្ជាក់អះអាងជាថ្មីដល់ពួកគេ ហើយបង្ហាញក្ដីស្រឡាញ់ដល់ពួកគេ ។ ខ្ញុំផ្ដល់ឱកាសដល់ពួកគេឲ្យបញ្ចេញភាពតានតឹងរបស់ពួកគេ ។

*អែងបូ យេ អាយុ ១៨ ឆ្នាំ ប្រទេសកូតឌីវ័រ*

**កុំឲ្យខ្លួនអ្នកធ្លាក់ទឹកចិត្តដូចពួកគេ**

របៀបដ៏ល្អបំផុតដើម្បីជួយពួកគេ និងខ្លួនអ្នក គឺដោយមានភាពស្មោះត្រង់ ។ និយាយអ្វីដែលផ្ដល់អំណរដល់អ្នក ។ ប្រសិនអ្នកមានការលំបាកនឹងមានភាពរីករាយ សូមឲ្យពួកគេដឹងថាអ្នកនៅទីនោះសម្រាប់ពួកគេ ប៉ុន្តែសូមថែទាំខ្លួនឯង ។ វាប្រសើរជាងដែលអ្នកមិនមានបញ្ហាជាជាងមានការធ្លាក់ទឹកចិត្តដែរ ។

*ឃីរ៉ា ដាប់បលយូ អាយុ ១៦ ឆ្នាំ រដ្ឋកានសាស ស.រ.អា.*



**គិតពីចំនុចវិជ្ជមាន**
អ្នកអាចបន្តមានភាពវិជ្ជមាននៅជុំវិញមិត្តរបស់អ្នកដែលហាក់ដូចជាធ្លាក់ទឹកចិត្ត ដោយគិតពីរឿងវិជ្ជមានដែលអ្នកបានមានបទពិសោធន៍ ឬនឹងមានបទពិសោធន៍ឆាប់ៗនៅក្នុងជីវិតអ្នក ។ គ្រាន់តែគិតពីរឿងដែលអ្នកពេញចិត្តដូចជាបទពិសោធន៍សប្បាយៗ ។

***លូក ភី អាយុ ១៤ ឆ្នាំ រដ្ឋនូវ មិុកស៊ីកូ ស.រ.អា.***

រូបថតមកពី GETTY IMAGES

**រំឭកពួកគេពីអ្វីដែលល្អ**
ពេលខ្ញុំមានមិត្តម្នាក់ដែលធ្លាក់ទឹកចិត្ត ខ្ញុំព្យាយាមនិយាយទៅកាន់ពួកគេអំពីអ្វីដែលពួកគេចាប់អារម្មណ៍ ដើម្បីពួកគេអាចត្រូវបានរំឭកពីរឿងរ៉ាវល្អៗអំពីថ្ងៃ ឬជីវិតរបស់ពួកគេ ។ ជួនកាលខ្ញុំនឹងព្យាយាមធ្វើឲ្យពួកគេសើច ឬផ្ដល់ការសរសើរដើម្បីធ្វើឲ្យពួកគេមានអារម្មណ៍ល្អ ហើយជួនកាលខ្ញុំសុំពួកគេឲ្យធ្វើអ្វីដែលសំខាន់ ដើម្បីពួកគេដឹងថា ពួកគេមានគោលបំណងមួយ ។

***ខារសុន ឌី អាយុ ១៥ ឆ្នាំ រដ្ឋតិចសាស ស.រ.អា.***

*កំណត់ចំណាំអ្នកនិពន្ធ ៖ យោបល់ដែលផ្ដល់ឲ្យនៅទីនេះគឺមានប្រយោជន៍ ប៉ុន្តែអាចនឹងមិនជួយភ្លាមៗ ឬព្យាបាលជំងឺធ្លាក់ទឹកចិត្តនោះទេ ។ ជំនួយពីអ្នកជំនាញអាចជាការចាំបាច់ក្នុងករណីធ្ងន់ធ្ងរ ។*

*ចម្លើយអាចនឹងត្រូវបានកែសម្រួលឡើងវិញ ប្រសិនបើវាវែងពេក ឬមិនសូវច្បាស់លាស់ ។ ការឆ្លើយតបទាំងឡាយធ្វើឡើងក្នុងគោលបំណងទុកជាជំនួយ និងទស្សនវិស័យមិនមែនជាសេចក្ដីប្រកាសអំពីគោលលទ្ធិសាសនាចក្រជាផ្លូវការនោះទេ ។*

***តើអ្នកគិតដូចម្ដេច ?***

**« តើខ្ញុំអាចឈប់គិតពីភាសាដែលមិនស្អាតស្អំដែលខ្ញុំឮដោយរបៀបណា ? »**

ប្រសិនបើអ្នកមានបំណងឆ្លើយនឹងសំណួរនេះ សូមផ្ញើចម្លើយរបស់អ្នក និងរូបថតមានគុណភាពច្បាស់មួយសន្លឹកឲ្យបានត្រឹមថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០២០ ទៅកាន់គេហទំព័រ liahona@ChurchofJesusChrist.org ។



# តើសាសនាចក្រមានគោលជំហរយ៉ាងដូចម្ដេចចំពោះការប្រកាន់ពូជសាសន៍ ?

យើងជឿថា ព្រះជាព្រះវរបិតានៃមនុស្សលោកទាំងអស់ ហើយថា « ទ្រង់ពុំបដិសេធអ្នកណាម្នាក់ ដែលមករកទ្រង់ឡើយ [ ទាំង ] ខ្មៅ និងស . . . មនុស្សទាំងអស់ដូចគ្នានៅចំពោះព្រះ » ( នីហ្វៃទី ២ ២៦:៣៣ ) ។ ដោយសារមនុស្សទាំងអស់គ្នាគឺស្មើគ្នាចំពោះព្រះ នោះយើងជឿថា គ្មានមនុស្សណាម្នាក់អាចមានសិទ្ធិប្រកាសថាខ្ពស់ជាងម្នាក់ផ្សេងទៀតដោយសារតែសារតាពូជសាសន៍ ឬជនជាតិរបស់ពួកគេឡើយ ។ ជាងនោះទៀត យើងជឿថា វាជាអំពើបាបក្នុងការបន្ទាបបន្ថោក និយាយមើលងាយ ឬរើសអើងទាស់នឹងមនុស្សផ្សេងទៀតដោយសារតែពូជសាសន៍របស់ពួកគេនោះ ។

ព្យាការី និងសាវកសម័យទំនើបបានថ្កោលទោសលើការប្រកាន់ពូជសាសន៍ក្នុងលក្ខខណ្ឌដ៏ខ្លាំងក្លាបំផុតដែលអាចធ្វើទៅបាន ។ ឧទាហរណ៍ ៖

- ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( ១៩១០–២០០៨ ) ៖ « គ្មានមនុស្សណា ដែលបាននិយាយបន្តុះបង្អាប់ដល់អ្នកទាំងឡាយដែលមានជាតិសាសន៍ផ្សេង ហើយនៅតែអាចគិតថាខ្លួនគាត់ជាសិស្សពិតមួយរូបរបស់ព្រះគ្រីស្ទឡើយ ។ ហើយគាត់ក៏មិនអាចចាត់ទុកខ្លួនគាត់ថាបានរស់នៅស្របនឹងការបង្រៀននៃសាសនាចក្រនៃព្រះគ្រីស្ទដែរ » ។[១]
- ប្រធាន អិម រ័សុល បាឡឺដ ប្រធានស្ដីទីក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖ « យើងត្រូវឱបក្រសោបបុត្រាបុត្រីនៃព្រះដោយក្ដីមេត្តា ហើយលប់បំបាត់ចោលនូវការរើសអើងគ្រប់រូបភាពរួមមានទាំងការប្រកាន់ពូជសាសន៍ ការប្រកាន់ភេទ និងជាតិសាសន៍ » ។[២]
- ប្រធាន ដាល្លិន អេក អូក ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ ៖ « ការប្រកាន់ពូជសាសន៍គឺប្រហែលជាប្រភពនៃការរើសអើងដែលគេដឹងឮយ៉ាងច្រើនបំផុតនៅសព្វថ្ងៃនេះ ហើយយើងទាំងអស់គ្នាត្រូវបានហៅឲ្យប្រែចិត្តពីការណ៍នោះ » ។[៣]

**កំណត់ចំណាំ**
១. ហ្គរដុន ប៊ី ហ៊ីងគ្លី « The Need for Greater Kindness » *Liahona* ខែ ឧសភា ឆ្នាំ ២០០៦ ទំព័រ ៥៨ ។
២. អិម រ័សុល បាឡឺដ « ដំណើរមានបន្តទៅមុខទៀត ! » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៧ ទំព័រ ១០៦ ។
៣. ដាល្លិន អេក អូក « A Cause for Celebration » *Liahona* ខែ ធ្នូ ឆ្នាំ ២០១៩ ទំព័រ ៤៩ ។

# ការបម្រើរួមគ្នាជាមួយនឹង អំណាចបព្វជិតភាព

**ដោយប្រធាន អិម រ័សុល បាឡឺដ**
ប្រធានស្ដីទីកូរ៉ុមនៃពួកសាវកដប់ពីរនាក់

កាលពីបីបួនឆ្នាំមុន ភរិយារបស់ខ្ញុំ បាបារ៉ា និងខ្ញុំ បានសម្លឹងមើលទៅមេឃនាពេលរាត្រីដោយភាពអស្ចារ្យ ។ មានផ្កាយរាប់លានហាក់ដូចជាមានពន្លឺភ្លឺស្រស់ស្អាតខុសប្លែកពីធម្មតា ។ ក្រោយមកខ្ញុំបានបើកទៅគម្ពីរមុក្ដាដ៏មានតម្លៃមហិមា ហើយអានម្ដងទៀតទាំងងឿងឆ្ងល់ពីអ្វីដែលព្រះអម្ចាស់ជាព្រះបានមានបន្ទូលទៅកាន់ម៉ូសេថា ៖ « ហើយពិភពលោកដ៏ច្រើនឥតគណនា នោះយើងបានបង្កើតឡើង ហើយយើងបានបង្កើតរបស់ទាំងនោះឡើងសម្រាប់គោលបំណងរបស់យើងផ្ទាល់ ហើយដោយសារព្រះរាជបុត្រា នោះយើងបានបង្កើតរបស់ទាំងនោះមក គឺជាព្រះរាជបុត្រាបង្កើតតែមួយរបស់យើង » ( ម៉ូសេ ១:៣៣ ) ។

អំណាចដែលបង្កើតស្ថានសួគ៌ និងផែនដីគឺជាបព្វជិតភាព ។ ប្រភពនៃអំណាចបព្វជិតភាពនេះគឺជាព្រះដ៏មានមហិទ្ធិឫទ្ធិ និងព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ ។ វាជាអំណាចដែលព្រះអង្គសង្គ្រោះបានប្រើដើម្បីធ្វើអព្ភូតហេតុ ដើម្បីផ្ដល់នូវដង្វាយធួនដែលគ្មានដែនកំណត់ និងដើម្បីយកឈ្នះសេចក្ដីស្លាប់ខាងរូបកាយតាមរយៈការរស់ឡើងវិញ ។

នៅក្នុងផែនការរបស់ព្រះវរបិតាសួគ៌យើង បុរសមានទំនួលខុសត្រូវដ៏ពិសេសក្នុងការគ្រប់គ្រងបព្វជិតភាព តែពួកគេពុំមែនជាបព្វជិតភាពនោះទេ ។ ការយល់ដឹងថាព្រះវរបិតាសួគ៌ បានផ្ដល់វិធីមួយសម្រាប់បុត្រាបុត្រីទ្រង់គ្រប់រូបអាចទទួលបានពរជ័យ និងទទួលការពង្រឹងនៃបព្វជិតភាព វាជារឿងសំខាន់ណាស់សម្រាប់យើង ។

អំណាចបព្វជិតភាពដូចគ្នាដែលបានបង្កើតពិភពលោក កាឡាក់ស៊ី និងសកលលោក អាច ហើយគួរតែជាផ្នែកមួយនៃជីវិតយើងក្នុងការជួយពង្រឹង ហើយផ្ដល់ពរដល់គ្រួសារយើង មិត្តភក្ដិយើង និងអ្នកជិតខាងយើង—និយាយម្យ៉ាងទៀតគឺត្រូវធ្វើកិច្ចការដែលព្រះអង្គសង្គ្រោះនឹងធ្វើ បើទ្រង់កំពុងបម្រើក្នុងចំណោមពួកយើងសព្វថ្ងៃនេះ ( សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា ៨១:៥ ) ។

គោលបំណងចម្បងរបស់អំណាចបព្វជិតភាពគឺដើម្បីផ្ដល់ពរ ស្អាង និងបន្សុទ្ធយើង ដើម្បីយើងអាចរស់នៅជាមួយគ្នាជាមួយគ្រួសារយើងនៅក្នុងវត្តមានរបស់ព្រះបិតាព្រះមាតាសួគ៌យើងជារៀងរហូត ។ តាមរបៀបនេះ បុរស ស្ត្រី និងកុមារទាំងអស់—មិនថាអ្វីជាកាលៈទេសៈរបស់យើងនោះទេ—អាចចូលរួមនៅក្នុងកិច្ចការដ៏អស្ចារ្យរបស់ព្រះ និងព្រះយេស៊ូវគ្រីស្ទ ( សូមមើល ម៉ូសេ ១:៣៩ ) ហើយរីករាយនឹងពរជ័យទាំងឡាយនៃបព្វជិតភាព ។

សូមឲ្យយើងឈ្លាសវៃ ហើយព្យាយាមពង្រឹងជីវិតយើង ជីវិតគ្រួសារយើង និងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ តាមរយៈអំណាចនៃបព្វជិតភាពនៃព្រះ ។ ■

*ដកស្រង់ចេញពីសុន្ទរកថានៅក្នុងសន្និសីទទូទៅខែ មេសា ឆ្នាំ ២០១៣ ។*

តួអង្គចេញពីព្រះគម្ពីរមរមន

# អប៊ីស





ទង្វើស្មោះត្រង់របស់នាងបាននាំឲ្យ
មាននូវ **ការប្រែចិត្តជឿនៃពួក
សាសន៍លេមិនដ៏ច្រើន ។**



បានរស់នៅប្រមាណ៩០ឆ្នាំ
**មុនកំណើតរបស់
ព្រះគ្រីស្ទ ។**

**រក្សាជំនឿរបស់នាងជាសម្ងាត់**
រហូតដល់ពេលដែលសក្តិសម ។





ជាស្ត្រីសាសន៍លេមិន
ម្នាក់ដែល
**បានបម្រើដល់
ម្ចាស់ក្សត្រី ។**



បាន **ប្រែចិត្តជឿដល់ដំណឹងល្អ**
ដោយសារតែ « ការនិមិត្តមួយដ៏អស្ចារ្យ
នៃឪពុកនាង »
( អាលម៉ា ១៩:១៦ ) ។

រូបក្រដាសកាត់ដោយ ហ្គេល អាមស្ត្រង រូបភាពបន្ថែមដោយ ខេធី ដុក្រៀល



**មានអារម្មណ៍តានតឹងអំពីការនៅលីវ ?**

*សូមអានបទពិសោធន៍មកពី*
*យុវមជ្ឈិមវ័យដទៃទៀតពីរបៀបដក*
*ភាពតានតឹងចេញពីការស្វែងរក*
*ដៃគូអស់កល្ប ។*

៤២

យុវនារី

ការប្រារព្ធអបអរ ១៥០ ឆ្នាំ

៥៤, ៥៨

យុវវ័យ

ការជួយមិត្តភក្តិរបស់ខ្ញុំ ដែលមានការបាក់ទឹកចិត្ត

៦២

កូនចៅ

លេងល្បែងផ្គូផ្គងព្រះគម្ពីរមរមននេះ

ខ១២

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

CAMBODIAN
4 02167 21258 4

ខែ មិថុនា ឆ្នាំ ២០២០

# ប្រិយមិត្ត



រៀនអំពី
អាប៊ីស !
ទំព័រ ២២០–២២៣

វគ្គរបស់កុមារនៅក្នុងទស្សនាវដ្ដី *លីអាហូណា* ដែលបោះពុម្ពដោយ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

មកពីគណៈប្រធានទីមួយ



ដោយប្រធាន ហិនរី ប៊ី អាវរិង
ទីប្រឹក្សាទីពីរក្នុងគណៈប្រធាន
ទីមួយ

# ទីបន្ទាល់ និង ព្រះគម្ពីរមរមន

រាល់ពេលដែលខ្ញុំអានពីព្រះគម្ពីរមរមន
សូម្បីតែពីរបីបន្ទាត់ក៏ដោយ
ខ្ញុំមានអារម្មណ៍ថា ទីបន្ទាល់របស់ខ្ញុំត្រូវបានពង្រឹង
ថាគម្ពីរនោះ គឺពិត
ថាព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ហើយ
ថាយើងអាចដើរតាមទ្រង់ត្រឡប់ទៅផ្ទះវិញ ។
ព្រះគម្ពីរនេះ បានក្លាយជាគម្ពីរនៃអស់ទាំងគម្ពីរចំពោះខ្ញុំ ។
វាគឺជាព្រះបន្ទូលរបស់ព្រះ ។

*សម្របសម្រួលមកពី « ព្រះគម្ពីរមរមនជាការដឹកនាំផ្ទាល់ខ្លួន »*
Ensign *ខែ កញ្ញា ឆ្នាំ ២០១០ ទំព័រ ៤–៦ ។*



## ទីបន្ទាល់របស់ប្អូនផ្ទាល់

ទីបន្ទាល់មួយគឺជាអារម្មណ៍ល្អមកពីព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលប្រាប់យើងថា អ្វីមួយគឺពិត ។ ប្អូនមិននៅក្មេងពេកដើម្បីមានទីបន្ទាល់មួយឡើយ ។ កាត់បន្ទះទាំងនេះ ហើយដាក់វាក្នុងចានគោម ឬក្រឡមួយ ដើម្បីប្អូនអាចជ្រើសយកមួយជារៀងរាល់ថ្ងៃ ។ ពេលប្អូនទទួលអារម្មណ៍នៃទីបន្ទាល់មួយនៅក្នុងដួងចិត្តអ្នក សូមប្រាប់នរណាម្នាក់អំពីវា !

សូមច្រៀង « ខ្ញុំស្គាល់ក្ដីស្នេហ៍ព្រះសង្គ្រោះ » ( *សៀវភៅចម្រៀងកុមារ* ទំព័រ ៤២–៤៣ ) ។

សូមច្រៀង « គែតសេម៉ានី » ( លីអាហូណា ខែ មីនា ឆ្នាំ ២០១៨ ទំព័រ ៧៤–៧៥ ) ។

សូមមើលទៅរូបភាពព្រះវិហារបរិសុទ្ធមួយ ។

សូមស្ដាប់សន្ទរកថាមួយដោយប្រធាន រ័សុល អិម ណិលសុន ។

សូមមើលទៅរូបភាពនៃព្រះយេស៊ូវ ឬមើលវីដេអូព្រះគម្ពីរប៊ីបមួយអំពីទ្រង់ ។

សូមអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ ហើយស្ដាប់រកមើលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ ។

« សូមទទួលទាននូវព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ ... ព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ នឹងប្រាប់ដល់អ្នកនូវគ្រប់អ្វីទាំងអស់ដែលអ្នកត្រូវធ្វើ » ( នីហ្វៃ ទី២ ៣២:៣ ) ។

### ខ្ញុំទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធពេល . . .

ខ្ញុំអធិស្ឋានទៅព្រះវរបិតាសួគ៌ ។



ខ្ញុំគិតអំពីព្រះវិហារបរិសុទ្ធ ។



ខ្ញុំជួយមនុស្សដទៃ ។



តើនៅពេលណាដែលប្អូនបានទទួលអារម្មណ៍នៃទីបន្ទាល់មួយពីព្រះវិញ្ញាណបរិសុទ្ធ ?

រូបគំនូរដោយ ជេស ម៉ាកខេន

# ការអធិស្ឋានរបស់ខេលលី



ដោយ ឡូរី ហ្វូលើរ ស៊ូសា
ទស្សនាវដ្ដីសាសនាចក្រ
( ផ្អែកទៅលើដំណើររឿងពិត )

ខេលលី និងម៉ាក់របស់នាងបានដើរទៅកាន់អគារសាសនាចក្រ ហើយមើលជុំវិញ ។ វាស្រស់ស្អាត ដោយមានដើមត្នោតដុះទេរនៅខាងក្រៅ ។ ស្លាកសញ្ញានៅលើអគារនោះបានសរសេរថា « សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ » ។ ជាបីភាសាខុសៗគ្នា—ម៉ាឡេ ចិន និងអង់គ្លេស !

ខេលលីមិនបានដឹងច្រើនទេអំពីព្រះយេស៊ូវគ្រីស្ទ ។ ហើយនាងពុំដែលបានទៅព្រះវិហារពីមុនមកឡើយ ។ មិត្តភក្តិម៉ាក់នាង លី លីន បានទៅព្រះវិហារនៅទីនោះ ។ គាត់បានអញ្ជើញខេលលី និងម៉ាក់នាងឲ្យមកជាមួយគាត់ ។

ពេលពួកគេបានដើរចូលទៅខាងក្នុង មនុស្សម្នាបានញញឹមដាក់ពួកគេ ហើយបាននិយាយថាសួស្ដី ។ គ្រប់គ្នាល្អណាស់ ។ ខេលលី និងម៉ាក់បានដើរតាម លី លីន ទៅខាងលើទៅបន្ទប់ធំមួយ ។ លី លីន បានប្រាប់ថា គេហៅបន្ទប់នោះថារោងជំនុំ ។

ខេលលីបានអង្គុយចុះនៅក្បែរម៉ាក់ និងលីលីន នៅនឹងកៅអីមួយជួរ ហើយមិនយូរប៉ុន្មានព្រះវិហារបានចាប់ផ្ដើម ។ នាងបានស្ដាប់តន្ត្រី ។ នាងចូលចិត្តពីរបៀបដែលវាធ្វើឲ្យនាងមានអារម្មណ៍ សូម្បីតែនាងមិនស្គាល់ពាក្យក្នុងចម្រៀងក្តី ។

នៅចុងបញ្ចប់នៃការប្រជុំ ស្ត្រីម្នាក់បានក្រោកឈរឡើងដើម្បីអធិស្ឋានបិទ ។ ខេលលីសម្លឹងជុំវិញពេលដែលមនុស្សគ្រប់គ្នាផ្សេងទៀតបានឱបដៃ ហើយបិទភ្នែកពួកគេ ។ នាងនៅតែមានអារម្មណ៍អ្វីមួយល្អណាស់នៅក្នុងចិត្ត ។ តើនោះគឺជាអ្វី ? វាខុសពីអ្វីៗដែលនាងធ្លាប់មានអារម្មណ៍ពីមុនមក !

កាលដែលពួកគេចាកចេញពីព្រះវិហារក្រោយមក ខេលលីបានប្រាប់ម៉ាក់អំពីអារម្មណ៍របស់នាងដែលនាងបានមានអំឡុងការអធិស្ឋាន ។

ម៉ាក់បាននិយាយថា « ម៉ាក់មិនមានអារម្មណ៍ពិសេសអ្វីនោះទេ » ។

ប៉ុន្តែខេលលីបន្តគិតពីអារម្មណ៍ដែលនាងបានមាននៅព្រះវិហារ ។ នាងបានចូលចិត្តការអធិស្ឋាននោះ ។ ហើយនាងចូលចិត្តឮពីព្រះយេស៊ូវ ។

« តើពួកអ្នកផ្សព្វផ្សាយសាសនាអាចមកបង្រៀនខ្ញុំបានទេ ? » ខេលលីបានសួរម៉ាក់ ។ « ខ្ញុំចង់រៀនបន្ថែមទៀត » ។

ម៉ាក់បាននិយាយថា « បើនោះជាអ្វីដែលកូនចង់ធ្វើ វាមិនថ្វីទេ » ។

ពួកអ្នកផ្សព្វផ្សាយសាសនាបានបង្រៀនខេលលីពីរបៀបអធិស្ឋាន ហើយអានព្រះគម្ពីរ ។ ពួកគេបានបង្រៀននាងអំពីព្រះយេស៊ូវ និងរបៀបដែលទ្រង់ស្រលាញ់យើង ។ ខេលលីចូលចិត្តអ្វីដែលនាងកំពុងរៀន ។

ថ្ងៃមួយពួកអ្នកផ្សព្វផ្សាយសាសនាបានផ្ដល់ការអញ្ជើញដ៏ពិសេសមួយដល់នាង ។

អែលឌើរ ផាកកឹបានសួរថា « តើប្អូនអាចព្យាយាមអធិស្ឋាននៅសប្ដាហ៍នេះដែរឬទេ ? »

រហូតមកដល់ពេលនេះ ខេលលីគ្រាន់តែអធិស្ឋានជាមួយពួកអ្នកផ្សព្វផ្សាយសាសនាប៉ុណ្ណោះ ។ ប៉ុន្តែនាងចង់សាកល្បងវាដោយខ្លួនឯង ។ នាងបានដឹង

ថា ព្រះវរបិតាសួគ៌តែងតែស្ដាប់ ហើយទ្រង់មានព្រះទ័យចង់ឮពីនាង ។

នាងបានសន្យាថា « ខ្ញុំនឹងធ្វើវា » ។

ស្អែកឡើងនៅសាលាជាថ្ងៃដ៏ពិសេសមួយ ។ ខេលលីនឹងច្រៀងនៅក្នុងការប្រកួតមួយ ! នាងបានរៀនចម្រៀងចិនដ៏ពិរោះមួយ ។ ការរៀនពីណោតចម្រៀង និងសំឡេងជាកិច្ចការដ៏ពិបាក ! នាងបានហាត់ ហើយហាត់ទៀត ។

ឥឡូវនេះវាដល់ពេលត្រូវច្រៀងហើយ ខេលលីមានអារម្មណ៍ភ័យ ។ នាងបានទាញរូបព្រះយេស៊ូវដែលនាងបានដាក់ក្នុងហោប៉ៅឯកសណ្ឋានសាលារបស់នាងនៅព្រឹកនោះ ។ នាងសម្រេចចិត្តដើម្បីអធិស្ឋាន ដូចដែលពួកអ្នកផ្សព្វផ្សាយសាសនាបានបង្ហាញនាង ។ នាងបានអធិស្ឋានថា « ព្រះវរបិតាសួគ៌ សូមជួយកូនឲ្យបាត់ភ័យ » ។ « នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន » ។

បន្ទាប់មកខេលលីបានឈានជើងទៅលើឆាក ។ នាងបានសម្លឹងមើលទៅអ្នកទស្សនា និងមេប្រយោគ ។ នាងបានគិតអំពីរូបព្រះយេស៊ូវនៅក្នុងហោប៉ៅនាង ហើយមានអារម្មណ៍ប្រសើរឡើងបន្តិច ។ នាងបានដកដង្ហើមធំ ហើយបានចាប់ផ្ដើមច្រៀង ។

នាងបានច្រៀងគ្រប់ពាក្យដូចដែលនាងបានហាត់ ។ កាលដែលនាងបានច្រៀងដល់ណោតចម្រៀងចុងក្រោយ ហើយឱនក្បាល នោះខេលលីបានដឹងថាព្រះវរបិតាសួគ៌បានឮការអធិស្ឋានរបស់នាង ហើយបានជួយនាង ។

ខេលលីបានដើរចុះពីឆាកដោយញញឹម ។ នាងទន្ទឹងរង់ចាំដើម្បីប្រាប់ពួកអ្នកផ្សព្វផ្សាយសាសនាអំពីអ្វីដែលបានកើតឡើង ! នាងបានដឹងថា នាងចង់បន្តអធិស្ឋានជារៀងរាល់ថ្ងៃ ។ ●







# សួស្ដីមកពីប្រទេសអាល្លឺម៉ង់ !




ប្រទេសអាល្លឺម៉ង់មានប្រាសាទថ្មប្រហែលជា ២០០០០ ប្រាសាទ ។ ប្រាសាទជាច្រើនមានអាយុរាប់រយឆ្នាំ ។ នេះគឺជាប្រាសាទដ៏ល្បីមួយហៅថា ណឺសវ៉ានស្ទេន ។

**ប្រទេសអាល្លឺម៉ង់** ឬ *Deutschland* គឺជាប្រទេសមួយនៅតំបន់អឺរ៉ុបកណ្ដាល ។ វាមានព្រៃ និងស្ទឹង ភ្នំ និងមាត់សមុទ្រ ព្រមទាំងភូមិ និងទីក្រុងធំៗ ។ មានកុមារប្រហែលជា ១៣ លាននាក់រស់នៅប្រទេសអាល្លឺម៉ង់ ។







ជ្រក់ស្ពៃក្ដោបសរសៃ។ សាច់ក្រក និង *Spätzle* ( មី ) ជាម្ហូបដ៏មានប្រជាប្រិយនៅក្នុងប្រទេសអាល្លឺម៉ង់ ។



មានព្រះវិហារបរិសុទ្ធពីរនៅក្នុងប្រទេសអាល្លឺម៉ង់ ។ មួយគឺនៅក្នុងទីក្រុងហ្វ្រីបើក និងមួយទៀតនៅក្នុងទីក្រុងហ្វ្រែងហ្វើត ជាកន្លែងដែលក្មេងប្រុសនេះនៅ ។ ស្លាកនោះសរសេរថា « *Tempel der Kirche Jesu Christi der Heiligen der Letzten Tage* » ( ព្រះវិហារបរិសុទ្ធនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ) ។



កុមារី និងកុមាររីករាយក្នុងការចូលរួមនៅថ្នាក់បឋមសិក្សា ។



ប្រទេសអាល្លឺម៉ង់ល្បីខាងផ្សារគ្រីស្ទម៉ាសរបស់គេ ។ គ្រួសារចូលចិត្តមើលភ្លើងស្អាតៗ និងញ៉ាំចំណីឆ្ងាញ់ៗ !








នេះជា *សៀវភៅណែនាំសម្រាប់កុមារ* ជាភាសាអាល្លឺម៉ង់ ។ កុមារៗនៅក្នុងប្រទេសអាល្លឺម៉ង់កំពុងប្រើប្រាស់វាដើម្បីរៀន និងរីកចម្រើនៗ តើប្អូនៗកំពុងប្រើប្រាស់សៀវភៅណែនាំសម្រាប់កុមារយ៉ាងដូចម្ដេចដែរ នៅកន្លែងដែលប្អូនៗរស់នៅ ?



នៅថ្ងៃដំបូងនៃសាលាបឋមសិក្សា កុមារម្នាក់ៗទទួលបានកាបូបស្ពាយមួយ កូនកាបូបដាក់ខ្មៅដៃមួយ និង « កញ្ចប់រាងសាជីរបស់សាលា » មួយ ( *Schultüte* ឬ *Zuckertüte* ) ដែលមានពេញដោយនំចំណី និងអំណោយតូចៗ ។




## សូមជួបជាមួយមិត្តភក្តិមួយចំនួនរបស់យើងមកពីប្រទេសអាល្លឺម៉ង់ !



រឿងដែលខ្ញុំចូលចិត្តជាងគេមកពីព្រះគម្ពីរមរមន គឺពេលដែលព្រះគ្រីស្ទយាងមក ហើយបង្រៀនប្រជាជន ។ ខ្ញុំចង់ធ្វើតាមបទបញ្ញត្តិរបស់ព្រះគ្រីស្ទដែលមិនឲ្យធ្វើការវិនិច្ឆ័យ ។ កាលដែលខ្ញុំអានការបង្រៀនរបស់ព្រះអម្ចាស់កាន់តែច្រើន នោះខ្ញុំកាន់តែទទួលអារម្មណ៍នៃក្ដីស្រឡាញ់របស់ទ្រង់ និងភាពសុខសាន្ត ។

លេឡា អេ អាយុ ១០ ឆ្នាំ ទីក្រុងហ្វ្រេនខូនៀ ប្រទេសអាល្លឺម៉ង់



ខ្ញុំដឹងថា ប្រសិនបើខ្ញុំរក្សាបទបញ្ញត្តិទាំងឡាយ នោះខ្ញុំមាននូវការអះអាងបញ្ជាក់ និងសុវត្ថិភាពនៃការបន្តនៅលើផ្លូវដែលនាំទៅរកព្រះ ។ ខ្ញុំតែងតែអាចដឹងថា ខ្ញុំបានធ្វើអ្វីមួយត្រឹមត្រូវពេលខ្ញុំទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ ។

ខេលិប អេ អាយុ ១២ ឆ្នាំ ទីក្រុងហ្វ្រេនខូនៀ ប្រទេសអាល្លឺម៉ង់

**តើប្អូនមកពីប្រទេសអាល្លឺម៉ង់ឬ ? សូមសរសេរមកកាន់ពួកយើង ! ពួកយើងចង់ឮពីប្អូនៗ ។**

រចនារូបភាពដោយ ខាធី ម៉ាក់ឌី រូបថតនៃក្មេងប្រុសនៅខាងមុខព្រះវិហារបរិសុទ្ធហ្វ្រេងហ្វើតអាល្លឺម៉ង់ ចុះហត្ថលេខាដោយ ហ្វើរណានដារូជឡូហ្វ រូបថតស្ដុកដោយ ADOBESTOCK និង GETTY IMAGES

# ហែលដូចជា សេះសមុទ្រ

**ដោយ ដេវីឌ ឌីកសុន**
ទស្សនាវដ្ដីសាសនាចក្រ
( ផ្អែកទៅលើដំណើររឿងពិត )

« *ព្រះវិញ្ញាណបរិសុទ្ធនឹងបង្ហាញដល់អ្នកនូវគ្រប់អ្វីទាំងអស់ដែលអ្នកត្រូវធ្វើ។* » ( នីហ្វៃទី ២ ៣២:៥ ) ។

រ៉ូប៊ីនបានសម្លឹងទៅក្នុងអាងហែលទឹក ។ គាត់បានព្យាយាមមិនគិតពីចម្ងាយឆ្ងាយប៉ុណ្ណាដែលគាត់ត្រូវហែលនោះទេ ។ អ្វីដែលសំខាន់គឺការទទួលបានស្លាកកិត្តិយស ។ ស្លាកកិត្តិយស *seepferdchen* ( សេះសមុទ្រ ) នឹងបង្ហាញគ្រប់គ្នានៅប្រទេសអាល្លឺម៉ង់ថា គាត់បានចេះហែលទឹកដោយខ្លួនឯង ។

*ខ្ញុំអាចធ្វើកិច្ចការនេះបាន !* រ៉ូប៊ីនបានគិត ។ គាត់បានដកដង្ហើមធំមួយ ហើយលោតចូលទៅ ។

ទឹកខ្វាតខ្វាយ !

ទឹកត្រជាក់ធ្វើឲ្យស្រួលខ្លួនណាស់នៅថ្ងៃដ៏ក្ដៅ ។

ប៉ាបានប្រាប់គាត់ថា *ហែលមួយម៉ែត្រម្ដងៗ ។ កុំគិតពី ២៥ ម៉ែត្រទាំងអស់ក្នុងពេលតែមួយ ។*

រ៉ូប៊ីនបន្ដមុជក្បាលចុះ ។ គាត់បានបោះដៃ និងជើងតាមដែលគាត់បានហាត់អស់ជាច្រើនខែ ។ គាត់ងើបដកដង្ហើមរៀងរាល់ពីរបីវិនាទីម្ដង ។

*ធាក់ ។ កាយ ។ ធាក់ ។ កាយ ។*

រំពេចនោះ គ្រូបង្រៀនហែលទឹកបានផ្លុំកញ្ចែរបស់គាត់ ។ រ៉ូប៊ីនបានងើយមើលដោយការងឿងឆ្ងល់ ។

គ្រូគាត់បាននិយាយថា « ល្អណាស់ » ។

គាត់ធ្វើវាបានហើយ !

រ៉ូប៊ីនបានសើច ហើយបានដាំដូងក្នុងទឹកពីរបីដងដើម្បីបង្ហាញនូវចិត្តត្រេកអរ ។ គាត់គឺជាសេះសមុទ្រ !

ពេលរ៉ូប៊ីនមកដល់ផ្ទះ គាត់ប្រញាប់ទៅរកប៉ា ។

« ប៉ា មើលនេ៎ ! »

ប៉ារបស់រ៉ូប៊ីនបានដាក់ញញួរគាត់ចុះ ។ គ្រាន់តែបានឃើញស្លាកកិត្តិយស *seepferdchen* ភ្លាមប៉ាញញឹមបិទមាត់មិនជិត ។

« កូនធ្វើវាបាននៅលើកទីមួយ ? » ប៉ាបានឱបរ៉ូប៊ីនយ៉ាងណែន ។ « តើកូនចង់ធ្វើអ្វីដើម្បីអបអរ ? »

រ៉ូប៊ីនបានគិតមួយសន្ទុះ ។ « អ្វីដែលខ្ញុំពិតជាចង់ធ្វើនោះគឺទៅអាងហែលទឹកជាមួយប៉ា ។ កូនចង់បង្ហាញប៉ានូវអ្វីដែលកូនអាចធ្វើបាន » ។







ប៉ាបានញញឹមកាន់តែខ្លាំងឡើង ។ « ឥឡូវ *នោះ*ជាការអបអរសម្រាប់យើងទាំងពីរនាក់ ។ ពេលប៉ាមានពេលភ្លាម យើងនឹងទៅភ្លាម » ។

រ៉ូប៊ីនក្តាប់ដៃលើកគ្រវីឡើងលើ ។ គាត់អន្ទះសាចង់ដេរស្លាកកិត្តិយសទៅនឹងសម្លៀកបំពាក់ហែលទឹករបស់គាត់ ហើយទៅហែលទឹកជាមួយប៉ា ។

បីបួនថ្ងៃកន្លងទៅ ។ រ៉ូប៊ីនចេះតែសួរប៉ាអំពីអាងហែលទឹក ប៉ុន្តែតែងតែមានអ្វីមករារាំង ។ ប៉ាហាក់ដូចជារវល់រហូត ។

ព្រឹកមួយរ៉ូប៊ីនបានលុតជង្គង់ចុះអធិស្ឋាននៅក្បែរគ្រែគាត់ ។ នៅចុងបញ្ចប់នៃការអធិស្ឋានរបស់គាត់ គាត់បានបន្ថែមរឿងមួយទៀត ។

« សូមប្រទានពេលបន្ថែមទៀតដល់ប៉ាកូន ដើម្បីយើងអាចទៅអាងហែលទឹក ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន » ។

ពេលរ៉ូប៊ីនបើកភ្នែកគាត់ គាត់បានឮប៉ាគោះទ្វារ ។

« តោះទៅអាងហែលទឹក ។ ប៉ាចង់ឃើញកូនហែលទឹកផ្ទាល់ ! »

រ៉ូប៊ីនចំហរមាត់ដោយភ្ញាក់ផ្អើល ។ « ប៉ា ! ប៉ានឹងមិនជឿវាទេ ។ កូន*ទើបតែបានអធិស្ឋាន*ថា ប៉ានឹងមានពេលបន្ថែមទៀតដើម្បីយើងអាចទៅ » ។

ប៉ាឱបដៃគាត់ ហើយផ្អែកទៅនឹងមាត់ទ្វារ ។ « ឥឡូវ តើនោះមិនគួរឲ្យចាប់អារម្មណ៍ទេឬ ? កូនឃើញទេ *ប៉ា*ទើបតែបានឮសារដ៏ស្ងៀមស្ងាត់ តែច្បាស់ពីព្រះវិញ្ញាណបរិសុទ្ធថា ប៉ាត្រូវតែនាំកូនទៅអាងហែលទឹក ។ តោះយើងទៅល្អជាង ! »

ពួកគេបានមានពេលដ៏អស្ចារ្យ ។ រ៉ូប៊ីនបានបង្ហាញប៉ាពីរបៀបដែលគាត់អាចហែល ២៥ ម៉ែត្រដោយមិនឈប់ ។ ប៉ាមានការស្ងើចសរសើរណាស់ ។ ហើយរ៉ូប៊ីនក៏បានស្ងើចចំពោះការដាំដូងនៅក្រោមទឹករបស់ប៉ាដែរ ។ ប៉ាអាចដាំដូងប្រាំដងជាប់គ្នា ។

រ៉ូប៊ីនបាននិយាយថា « កូនសប្បាយចិត្តណាស់ ដែលព្រះវរបិតាបានប្រទានពេលបន្ថែមទៀតនៅថ្ងៃនេះ » ។

ប៉ាបាននិយាយថា « តាមពិតទៅ ប៉ាគិតថា ប៉ាធ្វើឲ្យខ្លួនឯងរវល់ពេក ។ ប៉ាគិតថា ព្រះវិញ្ញាណបរិសុទ្ធបានរំឭកប៉ាថា យើងត្រូវតែ*ផ្តល់*ពេលវេលាដល់គ្នាទៅវិញទៅមក មិនអញ្ចឹងកូន ? ប៉ាសន្យាថា នឹងធ្វើផ្នែករបស់ប៉ា » ។

រ៉ូប៊ីនបានញញឹម ។ « ខ្ញុំក៏ដូចគ្នាដែរ ! »

ភ្នែកប៉ាឡើងជ្រួញដោយការញញឹម ។ « មានរឿងមួយទៀត ។ តើប៉ាធ្លាប់ប្រាប់កូនដែរឬទេ ថាប៉ាមិនដែលចាញ់ល្បែងបាចទឹកដាក់គ្នានោះ ? »

រ៉ូប៊ីនបានញញឹមតបវិញ ។ « ថ្ងៃនេះមិនទាន់ចប់នៅឡើយទេ ! » ●

**រឿងនេះកើតឡើងនៅក្នុងប្រទេស អាល្លឺម៉ង់ ។ សូមអានបន្ថែម អំពីប្រទេសអាល្លឺម៉ង់នៅ ទំព័រ ២៦–២៧ ។**

រូបគំនូរដោយ ម៉ាក រ៉ូបិនសុន



# បញ្ជាប់លំនាំ

នេះជារបៀបប្អូនយ៉ាងដែលយើងអាចអញ្ជើញមនុស្សដទៃទៀតឲ្យរៀនអំពីដំណឹងល្អ ។
សូមគូររូបភាពនៅក្នុងចន្លោះទំនេរដើម្បីបំពេញលំនាំនៅលើបន្ទាប់នីមួយៗ ។

សូមអញ្ជើញមិត្តម្នាក់ឲ្យស្ដាប់ប្អូនឡើងនិយាយនៅក្នុងថ្នាក់កុមារ ។





សូមបង្រៀនមិត្តរបស់ប្អូនម្នាក់នូវបទចម្រៀងកុមារដែលប្អូនចូលចិត្តមួយ ហើយច្រៀងជាមួយគ្នា ។

សូមចែកចាយទស្សនាវដ្ដី *ប្រិយមិត្ត* មួយច្បាប់ ។





ប្រាប់នរណាម្នាក់ថាព្រះ និងព្រះយេស៊ូវស្រឡាញ់ពួកគេខ្លាំងប៉ុណ្ណា ។



# កម្មវិធីបង្ហាញ ហើយនិទានប្រាប់



កាលពីខ្ញុំនៅក្មេងជាងនេះ ខ្ញុំបានមានជំងឺស្បែក ។ ខ្ញុំបានអធិស្ឋានសូមព្រះវរបិតាសួគ៌ជារៀងរាល់ថ្ងៃដើម្បីព្យាបាលខ្ញុំ ។ ខ្ញុំបានរៀនអត់ធ្មត់ ហើយប្រាំឆ្នាំក្រោយមកខ្ញុំបានជាសះស្បើយ ។ ខ្ញុំដឹងថា ព្រះវរបិតាសួគ៌ឮការអធិស្ឋានរបស់យើង ។

**ដូយុង យេ អាយុ ១២ ឆ្នាំ**
**ខេត្តហ្គីយ៉ុងហ្គី ប្រទេសកូរ៉េខាងត្បូង**



ប្អូនស្រីមិត្តរបស់ខ្ញុំខ្លាចផ្លេ ។ ពេលមានផ្លេខ្លះបានមកជិតយើង ខ្ញុំបានធ្វើសំឡេងស៊ូៗឲ្យផ្លេទៅឲ្យឆ្ងាយដើម្បីកុំឲ្យនាងខ្លាច ។

**ហៃរុម ហ្វេស អាយុ ៧ ឆ្នាំ ទីក្រុងម៉ាពុតូ ប្រទេសម៉ូហ្សាមប៊ីត**



ខ្ញុំចូលចិត្តយកសត្វល្អិតធ្វើជាសត្វចញ្ចឹម ។ សត្វល្អិតមួយបានឈឺខ្លាំងណាស់ ។ ខ្ញុំបានអធិស្ឋានថា វានឹងបានជា ។ នៅព្រឹកបន្ទាប់ ខ្ញុំបានមើលទៅក្នុងទ្រុងរបស់វា ហើយវាបានជាសះស្បើយ ។ ខ្ញុំដឹងថា ព្រះវរបិតាសួគ៌បានឮការអធិស្ឋានរបស់ខ្ញុំ ។

**ថានី ស៊ី អាយុ ៨ ឆ្នាំ ទីក្រុងវែលលីងថុន ប្រទេសនូវែលហ្សេឡង់**



ប៉ារបស់ខ្ញុំបានដាច់សរសៃឈាមខួរក្បាល ហើយបានទៅមន្ទីរពេទ្យពេលខ្ញុំអាយុប្រាំពីរឆ្នាំ ។ គាត់នៅតែស្នាក់នៅមន្ទីរពេទ្យ ពេលខ្ញុំបានឈានចូលអាយុប្រាំបីឆ្នាំ ។ ខ្ញុំបានសម្រេចចិត្តរង់ចាំរហូតដល់ប៉ាខ្ញុំចេញពីមន្ទីរពេទ្យដើម្បីធ្វើបុណ្យជ្រមុជទឹក និងបញ្ជាក់ ។ វាគឺជាថ្ងៃដ៏សប្បាយបំផុតសម្រាប់ខ្ញុំ ។

**វៀល្លៀម អិម អាយុ ៩ ឆ្នាំ ទីក្រុងឃ្វីនស្លេនដ៍ ប្រទេសអូស្ត្រាលី**



**មីហ្គែល ធី អាយុ ៧ ឆ្នាំ ទីក្រុងន្យូលេអន ប្រទេសម៉ិកស៊ិក**




**« កុមារនៅជុំវិញពិភពលោក »**
**អាលេកហ្សា ដាប់បលយូ អាយុ ១០ ឆ្នាំ**
**ទីក្រុងអេរ៉ាឌៀ ប្រទេសកូស្តារីកា**



ពេលខ្ញុំទៅសាលារៀន សិស្សខ្លះចូលចិត្តកម្រងរឿងគួរឲ្យខ្លាច ។ ពួកគេបានប្រាប់រឿងមួយដល់ខ្ញុំ ដែលពិតជាបានចាប់ផ្តើមរំខាន ដល់ខ្ញុំនៅពេលយប់ ។ យប់មួយ ខ្ញុំបានសម្រេចចិត្តអធិស្ឋានទៅព្រះវរបិតាសួគ៌ដើម្បីកុំឲ្យខ្ញុំគិតពីវា ហើយទ្រង់បានជួយខ្ញុំគេងលក់ជារៀងរាល់យប់ ។ ពេលនោះហើយដែលខ្ញុំបានដឹងថា ខ្ញុំអាចអធិស្ឋានទៅកាន់ទ្រង់នៅកន្លែងណាក៏បាន និងពេលណាក៏បាន ។

**អេនើរែល ធី អាយុ ១១ ឆ្នាំ ទីក្រុងអូឡានបាតា ប្រទេសម៉ុងហ្គោលី**

រូបភាពផ្ដល់ដោយក្រុមគ្រួសារ GETTY IMAGES

មិនមែន ខ្ញុំទេ !

មិនមែន ខ្ញុំទេ !

មិនមែន ខ្ញុំទេ !

មិនមែន ខ្ញុំទេ !

មិនមែន ខ្ញុំទេ !

មិនមែន ខ្ញុំទេ !

មិនមែន ខ្ញុំទេ !

មិនមែន ខ្ញុំទេ !

មិនមែន ខ្ញុំទេ !

មិនមែន ខ្ញុំទេ !

មិនមែន ខ្ញុំទេ !

មិនមែន ខ្ញុំទេ !

# តើខ្ញុំជានរណា?

*នេះជាល្បែងមួយដើម្បីលេងជាមួយគ្រួសារ ឬមិត្តភក្តិ ។ តើប្អូនអាចស្គាល់មនុស្សប៉ុន្មាន នាក់ចេញពីគម្ពីរអាលម៉ា ?*

១. សូមកាត់ប៊ូតុង « មិនមែនខ្ញុំទេ ! » នៅខាងឆ្វេង និងកាតនៅ ទំព័រ ២១៥ ។ សូមកុំកាត់រូបភាពនៅខាងស្ដាំ ។

២. ដើម្បីចាប់ផ្ដើមលេង សូមជ្រើសយកកាតមួយពីទំព័រ ២១៥ ។ កុំបង្ហាញនរណាម្នាក់នូវកាតដែលអ្នកបានជ្រើសរើសឡើយ ! មនុស្សផ្សេងទៀតនៅក្នុងក្រុមនឹងព្យាយាមដោះស្រាយវា ។

៣. ដើម្បីដោះស្រាយកាតអាថ៌កំបាំងនេះ ក្រុមត្រូវមើលទៅរូបភាពនៅលើទំព័រ ២១៣ ។ បន្ទាប់មកពួកគេដាក់វេនគ្នាសួរសំណួរ បាទ/ចាស-ឬ-ទេ ថាតើមនុស្សនៅក្នុងកាតនោះយ៉ាងម៉េច ឬអ្វីដែលគេបាន ។

៤. ពេលដែលក្រុមរៀនអ្វីៗដែលបង្ហួមព័ត៌មានថាមនុស្សអាថ៌កំបាំងនោះជានរណា ពួកគេអាចប្រើប្រាស់ប៊ូតុង « មិនមែនខ្ញុំទេ ! » ដើម្បីគ្របលើរូបភាពដែលមិនមែនជាមនុស្សនោះ ។ ឧទាហរណ៍ បើពួកគេសួរថា « តើមនុស្សរបស់អ្នកមានសក់ពណ៌ត្នោតឬ ? » ហើយអ្នកដែលកាន់កាតនិយាយថា ទេ នោះពួកគេអាចគ្របរូបមនុស្សទាំងអស់ដែលមានសក់ពណ៌ត្នោតជាមួយនឹងប៊ូតុង « មិនមែនខ្ញុំទេ ! » ។

៥. បន្ទាប់ពីរកឃើញថាមនុស្សអាថ៌កំបាំងនោះជានរណាហើយ សូមអានរឿងចេញពីកាតនោះឲ្យឮៗដល់ក្រុម ។ បន្ទាប់មកលេងម្ដងទៀត ដោយប្រមូលប៊ូតុងចេញពីរូបទាំងអស់ ហើយឲ្យម្នាក់ទៀតជ្រើសយកកាតថ្មីមួយ ។

**ជំនួយ ៖** មុននឹងអ្នកចាប់ផ្ដើម អ្នកអាចអាន ទំព័រ ២១៥ ទាំងអស់ឲ្យឮៗ ដើម្បីឲ្យគ្រប់គ្នាចងចាំពីរឿងទាំងនោះ !



អាលម៉ាជាកូន



អាំម៉ូន



ពួកសាសន៍អាន់ទៃ-
នីហ្វៃ-លីហៃ



ម្ចាស់ក្សត្រី



ស្ដេចឡាម៉ូណៃ



អ័ប៊ីស



អើរ៉ុន



កូរីហូរ



អាម៉ាលិកាយ



មេទ័ពម៉ូរ៉ូណៃ



ស្ត្រីបម្រើ



ពលទ័ពកំឡោះ

រចនារូបភាពដោយ ដេហ្វ ហាប់

មិត្តទៅកាន់មិត្ត



ដោយអែលឌើរ ហ្គេរី ប៊ី សាប៊ីន
ក្នុងពួកចិតសិបនាក់

# មិនមាននរណា ម្នាក់ត្រូវបានទុកចោលឡើយ

« *ចូរឲ្យគ្រប់គ្នាមានគំនិតតែ១ ព្រមទាំងមានចិត្តអាណិតអាសូរ ហើយស្រឡាញ់គ្នាជាបងប្អូន* » ( *ពេត្រុស ទី១ ៣:៨* ) ។

ចាស្ទីន កូនប្រុសរបស់យើងបានធំឡើងជាមួយនឹងជំងឺដ៏ពិបាកមួយ ។ ជួនកាលគាត់ខ្សោយណាស់ ។ គាត់មិនតែងតែអាចធ្វើអ្វីៗដូចមនុស្សគ្រប់គ្នាធ្វើឡើយ ទោះជាគាត់បានព្យាយាមក្តី ។ គាត់បានដឹងថាវាមានអារម្មណ៍យ៉ាងណាដែលខុសពីគេនោះ ។

ថ្ងៃមួយ ចាស្ទីន និងមិត្តភក្តិរបស់គាត់បានជួបជុំគ្នាដើម្បីលេងល្បែងមួយ ។ ពួកគេត្រូវវាយបាល់ជាមួយនឹងដៃពួកគេ ដើម្បីកុំឲ្យបាល់នោះធ្លាក់ចុះ ។ មានក្មេងស្រីបាក់ដៃម្នាក់បានមកលេងជាមួយ ។



វាងាយស្រួលដើម្បីនិយាយថា « មែនហើយ យើងទាំងអស់គ្នានឹងលេង ហើយនាងនឹងមើល » ។

ផ្ទុយទៅវិញ ចាស្ទីនបាននិយាយថា « ខ្ញុំមានគំនិតល្អមួយ ។ យើងទាំងអស់គ្នានឹងលេងជាមួយគ្នាដោយប្រើដៃតែម្ខាងប៉ុណ្ណោះ » ។ គ្រប់គ្នាបានលេងដោយប្រើដៃតែម្ខាង រួមទាំងក្មេងស្រីដែលមានពាក់រណបនៅនឹងដៃនោះផងដែរ ។ មិនមាននរណាម្នាក់ត្រូវទុកចោលឡើយ ។

ចាស្ទីនគឺជាវីរបុរសរបស់ខ្ញុំ ។ គាត់តែងតែមើលទៅមនុស្សផ្សេងទៀត ហើយគិតថា *តើពួកគេមានអារម្មណ៍យ៉ាងណា ?* ចាស្ទីនឈឺភាគច្រើនបំផុតនៃជីវិតរបស់គាត់ ប៉ុន្តែគាត់រីករាយដោយសារគាត់បានជួយមនុស្សដទៃទៀត ហើយធ្វើតាមព្រះយេស៊ូវគ្រីស្ទ ។

យើងទាំងអស់គ្នាមានឧបសគ្គ ប៉ុន្តែយើងមានអ្វីៗជាច្រើនដែលធ្វើឲ្យយើងសប្បាយ ។ ធ្វើអ្វីដែលអ្នកអាចធ្វើបាន ។ សូមទុកចិត្តលើព្រះ ។ សុភមង្គលដ៏អស្ចារ្យបំផុតមិនមែនបានមកពីការផ្តោតលើខ្លួនឯងទេ ប៉ុន្តែបានមកពីការផ្តោតលើអ្នកដទៃទៀត ។ ●





## អ័ប៊ីស

ខ្ញុំបានប្រែចិត្តជឿលើព្រះជាច្រើនឆ្នាំមកហើយ ពេលឪពុករបស់ខ្ញុំបានមានការនិមិត្តមួយ ។ ពេលធ្វើការឲ្យស្ដេចឡាម៉ូណៃ ខ្ញុំបានជួយមនុស្សជាច្រើនឲ្យរៀនអំពីអំណាចនៃព្រះ ។



## ស្ដេចឡាម៉ូណៃ

ពេលខ្ញុំបានរៀនអំពីដំណឹងល្អ ខ្ញុំបានមានការនិមិត្តមួយ ។ ខ្ញុំបានឃើញព្រះយេស៊ូវ ! ខ្ញុំបានចែកចាយទីបន្ទាល់របស់ខ្ញុំជាមួយព្រះបិតាខ្ញុំ ហើយបានជួយរំដោះពួកអ្នកផ្សព្វផ្សាយសាសនាពីគុក ។



## កូរីហូរ

ខ្ញុំបានព្យាយាមបញ្ឆោតបញ្ចូលមនុស្សថា ព្រះយេស៊ូវមិនពិតទេ ហើយបានទាមទាររកភស្ដុតាងដែលបង្ហាញថាមានព្រះ ។ រំពេចនោះខ្ញុំមិនអាចនិយាយឬស្ដាប់ឮទេ !



## អាំម៉ូន

ខ្ញុំជាបុត្រាម្នាក់របស់ម៉ូសាយ ។ អំឡុងពេលបេសកកម្មរបស់ខ្ញុំ ខ្ញុំបានការពារហ្វូងសត្វរបស់ស្ដេចឡាម៉ូណៃ ។ ខ្ញុំបានបង្រៀនស្ដេចឡាម៉ូណៃ និងម្ចាស់ក្សត្រីអំពីដំណឹងល្អ ។



## ពួកសាសន៍អាន់ទៃ-នីហ្វៃ-លីហៃ

យើងធ្លាប់ជាពួកសាសន៍លេមិនដែលបានធ្វើចម្បាំងជាច្រើន ប៉ុន្តែយើងបានសម្រេចចិត្តដើម្បីធ្វើតាមព្រះ ។ យើងបានកប់អាវុធរបស់យើង ហើយបានសន្យាថា នឹងមិនប្រយុទ្ធទៀតទេ ។



## អាលម៉ាជាកូន

ខ្ញុំត្រូវបានដាក់ឈ្មោះតាមឪពុកខ្ញុំដែលជាព្យាការី ។ មិត្តខ្ញុំ និងខ្ញុំបានធ្វើការជ្រើសរើសដ៏អាក្រក់ ។ តែយើងបានប្រែចិត្តក្រោយមក ហើយបានក្លាយជាពួកអ្នកផ្សព្វផ្សាយសាសនាចក្រ ។

# តើខ្ញុំជានរណា ?—រើសយកកាតមួយ

*សូមប្រើកាតទាំងនេះ ដើម្បីលេងល្បែងនៅលើ ទំព័រ ២១២-២១៣ ។*



## ម្ចាស់ក្សត្រី

ខ្ញុំបានការពារព្រះស្វាមីខ្ញុំពេលអ្នកដទៃទៀតបានគិតថា ទ្រង់បានសុគត ។ បន្ទាប់ពីខ្ញុំបានរៀនអំពីព្រះ អ្នកបម្រើខ្ញុំអ័ប៊ីសបានជួយខ្ញុំឲ្យក្រោកឈរឡើង ហើយបង្រៀនអ្នកផ្សេងទៀត ។



## មេទ័ពមរ៉ូណៃ

ខ្ញុំជាមេទ័ពរបស់កងទ័ពសាសន៍នីហ្វៃ ប៉ុន្តែខ្ញុំមិនចូលចិត្តធ្វើឲ្យមនុស្សឈឺចាប់ទេ ។ ខ្ញុំបានធ្វើទង់ឥស្សរភាព ដើម្បីរំឭកដល់ប្រជាជនឲ្យចាំពីអ្វីដែលសំខាន់បំផុតដើម្បីការពារ ។



## ពលទ័ពកំឡោះ

យើងបានរៀនអំពីសេចក្ដីជំនឿពីម្ដាយយើង ។ ពេលយើងត្រូវការពារគ្រួសារយើង យើងបានទុកចិត្តថាព្រះនឹងជួយយើង ។ ហើយទ្រង់ពិតជាបានជួយយើងមែន !



## អើរ៉ុន

ខ្ញុំជាបុត្រាម្នាក់របស់ម៉ូសាយ ។ នៅក្នុងបេសកកម្មរបស់ខ្ញុំ ខ្ញុំបានបង្រៀនបិតា និងមាតារបស់ស្ដេចឡាម៉ូណៃ ។ បន្ទាប់មកពួកទ្រង់បានបង្កើតច្បាប់ដើម្បីការពារពួកអ្នកផ្សព្វផ្សាយសាសនានៅក្នុងដែនដីរបស់ទ្រង់ ។



## អាម៉ាលិកាយ

ខ្ញុំចង់ក្លាយជាស្ដេចខ្លាំងណាស់ ។ ខ្ញុំបានបំពុលមេទ័ពសាសន៍លេមិន ហើយបានគ្រប់គ្រងទ័ពរបស់គាត់ជំនួសវិញ ។ ខ្ញុំបានបញ្ឆោតបញ្ចូលប្រជាជនឲ្យប្រយុទ្ធ ហើយវាយប្រហារគ្នាទៅវិញទៅមក ។



## ស្ត្រីបម្រើ

ពេលនរណាម្នាក់ធ្វើឲ្យខ្ញុំឈឺចាប់ ខ្ញុំមានភាពក្លាហានគ្រប់គ្រាន់ដើម្បីប្រាប់នរណាម្នាក់អំពីវា ហើយសូមជំនួយ ។ ខ្ញុំបានធ្វើការជាមួយមេទ័ពមរ៉ូណៃដើម្បីការពារប្រជាជនរបស់លោក ។

# ដៃជំនួយរបស់អេលី

ដោយ រេបេកា រាយស៍ បេឺកយិន
( ផ្អែកទៅលើដំណើររឿងពិត )

« *There is plenty indeed for my two hands to do* » ( Children’s Songbook *ទំព័រ ២៧២* ) ។



វាជាពេលព្រឹកថ្ងៃសៅរ៍ ហើយអេលីបានត្រៀមខ្លួនជាស្រេចនៅឯទីចាំគោលដៅ ដើម្បីការពារបាល់កុំឲ្យចូលទីគោលដៅ ។ គាត់បានលោតចុះឡើងប្រឹងអស់ពីសមត្ថភាពគាត់ដើម្បីការពារបាល់កុំឲ្យចូលក្នុងសំណាញ់របស់ទី ។ ប៉ុន្តែវាពិបាកណាស់ ! បន្ទាប់មក មុនពេលនឹងការប្រកួតនោះចប់ បាល់បានរអិលធ្លាក់ផុតពីដៃគាត់ ។ ក្រុមផ្សេងទៀតបានពិន្ទុ ! ក្រុមរបស់អេលីបានចាញ់ ។ គាត់សោកសៅខ្លាំងណាស់ ។

ថ្ងៃបន្ទាប់ទៀតនៅព្រះវិហារ អេលីបានដើរយឺតៗទៅថ្នាក់កុមាររបស់គាត់ទាំងមានអារម្មណ៍ស្រពាប់ស្រពោននៅឡើយ ។

អេលីបានឃើញមិត្តរបស់គាត់ខេតខាងក្រៅថ្នាក់ ។ ម៉ាក់របស់ខេតបានរុញរទេះពណ៌ផ្កាឈូករបស់ខេតទៅខាងក្នុង ។ គាត់បានឱបខេតមុននឹងចេញទៅថ្នាក់គាត់ ។

អេលីបាននិយាយថា « សួស្ដី ខេត » ។

ខេតមិនអាចឆ្លើយតប ឬគ្រវីដៃត្រឡប់វិញបានទេ ប៉ុន្តែនាងតែងតែសម្លឹងទៅចំភ្នែករបស់អេលី ដើម្បីឲ្យគាត់ដឹងថានាងបានឮគាត់ ។

ធម្មតាខេតញញឹមពេលអេលីនិយាយសួស្ដី ប៉ុន្តែថ្ងៃនេះអត់ទេ ។ *តើខេតសោកសៅឬ ?* អេលីបានឆ្ងល់ ។ *ខ្ញុំ ដឹងថាវាមានអារម្មណ៍យ៉ាងណា* ។ គាត់នៅតែមានអារម្មណ៍សោកសៅដែលគាត់មិនអាចការពារបាល់ពីក្រុមមួយទៀតបាន ។

អេលីបានអង្គុយក្បែរចេន និងម៉ាឃេល ពេលសិស្ទើរយ៉ង់បានចាប់ផ្ដើមថ្នាក់ ។ បន្ទាប់មកខេតបានថ្ងូរ ។ ជួនកាលវាពិបាកសម្រាប់ខេតដើម្បីអង្គុយនៅស្ងៀម ដោយសាររាងកាយនាងឈឺចាប់ ។

« ខេត តើប្អូនឈឺឬថ្ងៃនេះ ? » សិស្ទើរយ៉ង់បានសួរ ។

ខេតបានចាប់ផ្ដើមយំ ។

សិស្ទើរយ៉ង់បាននិយាយថា « ប្រហែលជាចម្រៀងថ្នាក់កុមារមួយនឹងជួយ ។

កុមារក្នុងថ្នាក់បានចាប់ផ្ដើមច្រៀង ។ ខេតចូលចិត្តដន្ត្រី ។ ធម្មតានាងច្រៀងតាមដោយធ្វើជាសំឡេងសប្បាយៗ ។ ប៉ុន្តែថ្ងៃនេះ ខេតគ្រាន់តែយំប៉ុណ្ណោះ ។

*តើយើងអាចជួយខេតឲ្យមានអារម្មណ៍ប្រសើរឡើងយ៉ាងដូចម្ដេច ?* អេលីបានឆ្ងល់ ។

បន្ទាប់មកមានគំនិតមួយបានផុសឡើង ។ « ខ្ញុំដឹង ! » អេលីបានប្រាប់សិស្ទើរយ៉ង់ ។ « ខ្ញុំនឹងរុញរទេះរបស់ខេតបន្តិច » ។

អេលីបានឃើញម៉ាក់របស់ខេតរុញរទេះនាងថ្នមៗ ពេលខេតត្រូវការមានអារម្មណ៍ប្រសើរឡើង ។ គាត់បានប្រញាប់ដើរទៅកាន់ខេត ហើយបានចាប់ផ្ដើមរុញរទេះនាងយឺតៗទៅវិញទៅមក ។

ខេតបានឈប់យំ ។

ចនបានសួរ « តើខ្ញុំសូមធ្វើដែរបានទេ ? »

« ខ្ញុំដែរ ! » ម៉ាឃេលបាននិយាយ ។

កាលដែលសិស្ទើរយ៉ង់បានបង្រៀនមេរៀន អេលី និងមិត្តរបស់គាត់បានដាក់វេនគ្នារុញរទេះរបស់ខេត ។ ខេតបានញញឹម ។ បន្ទប់ទាំងមូលហាក់ដូចជាមានពន្លឺចែងចាំងជាងមុន ។

ទម្រាំដល់ថ្នាក់បញ្ចប់ គ្រប់គ្នាញញឹម ។

អេលីបាននិយាយថា « ការជួយខេតធ្វើឲ្យខ្ញុំសប្បាយចិត្ត » ។

សិស្ទើរយ៉ង់បាននិយាយថា « ខ្ញុំរីករាយណាស់ ។ « វាធ្វើ



រចនារូបភាពដោយ មេលីស្សា មែនវីល



ឲ្យព្រះវរបិតាសួគ៌សប្បាយព្រះទ័យផងដែរ ។ ទ្រង់ស្រឡាញ់ខេត ហើយមានព្រះទ័យចង់ឲ្យនាងមានអារម្មណ៍ប្រសើរឡើង ។ ជួនកាលយើងបានធ្វើជាអ្នកជួយរបស់ទ្រង់ » ។

អេលីបានសម្លឹងទៅខេត ។ គាត់បានប្រាប់នាងថា « ឯងជួយខ្ញុំផងដែរ ។ រាល់ពេលដែលឯងញញឹម » ។

ខេតបានញញឹម ។

ពេលអេលីបានត្រឡប់ទៅផ្ទះពីព្រះវិហារវិញ គាត់បានមានអារម្មណ៍កក់ក្ដៅមួយដូចជាទីវាលបាល់ទាត់នៅក្រោមកម្ដៅថ្ងៃខែប្រាំងអញ្ចឹង ។ គាត់បានគិតថា *ប្រហែលជាខ្ញុំពុំអាចចាប់បាល់បានទាំងអស់ទេ ។ ប៉ុន្ដែខ្ញុំនៅតែអាចប្រើដៃខ្ញុំជួយមនុស្សបាន ។* ●

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា. ។*



« តាមរយៈសេចក្ដីសប្បុរស និងការបម្រើចេញពីដួងចិត្តរបស់យើង យើងអាចធ្វើមិត្តជាមួយអស់អ្នកដែលយើងបម្រើបាន » ។

ប្រធាន អិម រ័សុល បាឡឺដ ប្រធានស្ដីទីក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Finding Joy through Loving Service » *Liahona* ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៤៨ ។

# ព្រះយេស៊ូវស្រឡាញ់គ្រប់គ្នា !



រចនារូបភាពដោយ អេនថូនី វ៉ាណាសខេល

# គោលដៅធ្វើម្ហូបរបស់ខ្ញុំ

ដោយ ហ្វើរណាន់ដា ដី អាយុ ១០ ឆ្នាំ ទីក្រុងប៉ារ៉ាណា ប្រទេសប្រេស៊ីល

ខ្ញុំចង់ធ្វើឲ្យកាន់តែប្រសើរលើផ្នែកធ្វើម្ហូប ។ ដូច្នេះ ខ្ញុំបានយក *សៀវភៅណែនាំសម្រាប់កុមារ* របស់ខ្ញុំមក ខ្ញុំបានដាក់គោលដៅមួយដើម្បីធ្វើម្ហូបជាមួយប៉ាខ្ញុំ ។ ពេលណាដែលប៉ាខ្ញុំធ្វើម្ហូប ខ្ញុំមើលគាត់ ហើយបានឃើញថាវាអស្ចារ្យណាស់ ។ ខ្ញុំចង់រៀនធ្វើម្ហូបដូចគាត់ដែរ ។

ប៉ាខ្ញុំ និងខ្ញុំបានទៅផ្សារដើម្បីទិញគ្រឿងម្ហូប ។ បន្ទាប់មកគាត់បានបង្រៀនខ្ញុំមួយជំហានម្ដងៗពីរបៀបដើម្បីធ្វើឲ្យម្សៅក្លាយទៅជានំខេកមួយដ៏ស្រស់ស្អាត ។ ក្រោយមកគាត់ក៏បានបង្រៀនខ្ញុំពីរបៀបធ្វើម្ហូបផ្សេងៗទៀត ។





ការធ្វើគោលដៅនេះបានជួយខ្ញុំឲ្យកាន់តែស្និតស្នាលនឹងប៉ាខ្ញុំ ។ ខ្ញុំចូលចិត្តចំណាយពេលជាមួយប៉ាខ្ញុំ ។ គាត់គឺជាគ្រូដ៏អស្ចារ្យម្នាក់ ។ រឿងមួយដែលគាត់បានបង្រៀនខ្ញុំគឺថា ពេលយើងធ្វើម្ហូប ខ្ញុំមិនអាចរំខានដោយទូរសព្ទដៃរបស់ខ្ញុំនោះទេ ។



ឥឡូវនេះពេលខ្ញុំគិតអំពីការធ្វើម្ហូប អារម្មណ៍នៃអំណរពុះកញ្ជ្រោលនៅក្នុងខ្លួនខ្ញុំ ព្រោះខ្ញុំចូលចិត្តការធ្វើម្ហូបខ្លាំងណាស់ ! គោលដៅនេះមិនត្រឹមតែជួយខ្ញុំឲ្យធ្វើអ្វីដែលខ្ញុំស្រឡាញ់ប៉ុណ្ណោះទេ តែវាថែមទាំងជួយខ្ញុំលូតលាស់ខាងវិញ្ញាណផងដែរ ។ ខ្ញុំចូលចិត្តដែល ខ្ញុំអាចជ្រើសរើសគោលដៅខ្លួនឯងផ្ទាល់ ។ ព្រះវរបិតាសួគ៌មានព្រះទ័យចង់ជួយយើងជាមួយគោលដៅនេះ ដោយសារទ្រង់មានព្រះទ័យចង់ឲ្យយើងពង្រីកជំនាញរបស់យើង ។ ទ្រង់មានព្រះទ័យចង់ជួយខ្ញុំ ដោយសារទ្រង់ដឹងថាវាធ្វើឲ្យខ្ញុំសប្បាយចិត្ត ។ ●








*សៀវភៅណែនាំសម្រាប់កុមារ* របស់អ្នក អាចជួយអ្នកឲ្យដាក់គោលដៅ ដើម្បីលូតលាស់កាន់តែជិតនឹងព្រះយេស៊ូវ ។

សូមដល់ឪពុក/ម្ដាយម្នាក់ ឬមនុស្សម្នាក់ផ្សេងទៀតដែលអ្នកកោតសរសើរឲ្យបង្រៀនអ្នកនូវអ្វីៗដែលថ្មី !

ថតរូបដោយ ឡេស្លី នីលសិន

# អ័ប៊ីសបានចែកចាយដំណឹងល្អ



ស្ត្រីម្នាក់ឈ្មោះអ័ប៊ីសបានធ្វើការឲ្យស្ដេច ។ នាងជឿលើព្រះ ។ មនុស្សភាគច្រើននៅជុំវិញនាងពុំជឿលើព្រះទេ ។ ថ្ងៃមួយនាងបានឃើញអ្នកផ្សព្វផ្សាយសាសនាម្នាក់ឈ្មោះអាំម៉ូនកំពុងបង្រៀនស្ដេច និងម្ចាស់ក្សត្រីអំពីព្រះ និងព្រះយេស៊ូវគ្រីស្ទ ។



ពេលស្តេច និងម្ចាស់ក្សត្រី
រៀនអំពីដំណឹងល្អ ពួកទ្រង់
មានព្រះទ័យរីករាយណាស់ !
ពួកទ្រង់បានដួលចុះ ហើយមិន
កម្រើកឡើយ ។ អ័ប៊ីសបានដឹង
ថា ពួកទ្រង់កំពុងទទួលអារម្មណ៍
ពីព្រះចេស្តានៃព្រះ ។



អ័ប៊ីសចង់ឲ្យគ្រប់គ្នារៀនអំពីព្រះ ។ ដូច្នេះនាងបានរត់ពី
ផ្ទះមួយទៅផ្ទះមួយ ហើយបានប្រាប់ប្រជាជនឲ្យមក
មើលអ្វីដែលបានកើតឡើងនោះ ។

បន្ទាប់ពីមនុស្សម្នាមកជុំគ្នាហើយ អ័ប៊ីសបានជួយ
ម្ចាស់ក្សត្រីឲ្យឈរឡើង ។ បន្ទាប់មកម្ចាស់ក្សត្រីបាន
ជួយឲ្យស្តេចឈរឡើង ។ ពួកទ្រង់បានចាប់ផ្ដើម
បង្រៀនមនុស្សអំពីដំណឹងល្អ ។



រចនារូបភាពដោយ អាប៊្រីល ស្តុត



ខ្ញុំអាចក្លាយដូចជាអ័ប៊ីស ។ ខ្ញុំអាចជួយមនុស្សដទៃទៀតឲ្យរៀនអំពី
ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ។●

*សូមអានអំពីរឿងនេះនៅក្នុង អាលម៉ា ១៨–១៩ ។*

# អ័ប៊ីសមានជំនឿលើព្រះ



តើប្អូនៗអាចជួយមនុស្សឲ្យរៀនអំពីព្រះយ៉ាងដូចម្ដេច ?

រចនារូបភាពដោយ អាប៊ែល ស្កុត

សាសនាចក្រនៃ
**ព្រះយេស៊ូវគ្រីស្ទ**
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

# ជូនចំពោះមាតាបិតា

ខែនេះយើងអានអំពីពួកអ្នកផ្សព្វផ្សាយសាសនាដូចជា អាលម៉ាជាកូន អ័ប៊ីស និងពួកបុត្រារបស់ម៉ូសាយ ។ អ្នកអាចប្រើប្រាស់ ល្បែងនៅទំព័រ ខ១២-១៣ ឬ រឿងនៅទំព័រ ខ២០ ដើម្បីនិយាយអំពីបុរស និងស្ត្រីទាំងនេះនៅក្នុងព្រះគម្ពីរមរមន ។ ពួកគេម្នាក់ៗបានចែកចាយដំណឹងល្អតាមរបៀបផ្សេងៗគ្នា ។ តើគ្រួសាររបស់អ្នកអាចចែកចាយដំណឹងល្អដោយរបៀបណា ? សូមសរសេរគោលដៅផ្សព្វផ្សាយសាសនាមួយដើម្បីសាកល្បងធ្វើនៅខែនេះ—អ្នកអាចចម្លងគំនិតដែលអ្នកចូលចិត្តមកពីទំព័រ ខ១០ ផងដែរ ។

សូមបន្តចែកចាយ !
ទស្សនាវដ្ដី *ប្រិយមិត្ត*

**របៀបដើម្បីផ្ញើរបគំនូរ ឬបទពិសោធន៍នានារបស់កូនលោកអ្នកមកកាន់ទស្សនាវដ្ដី *លីអាហូណា***
សូមចូលទៅ liahona.ChurchofJesusChrist.org ហើយចុចលើ « Submit an Article or Feedback » ។ ឬ អ៊ីម៉ែលវាមកកាន់យើងតាម liahona@ChurchofJesusChrist.org ដោយដាក់ឈ្មោះ អាយុកូនរបស់បងប្អូន ទីក្រុងដែលរស់នៅ ព្រមទាំងសេចក្ដីថ្លែងការណ៍អនុញ្ញាតនេះថា ៖ « ខ្ញុំ [ សរសេរឈ្មោះរបស់បងប្អូន ] ផ្ដល់ការអនុញ្ញាតឲ្យ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ប្រើប្រាស់ការដាក់បញ្ជូនរបស់កូនខ្ញុំនៅក្នុងទស្សនាវដ្ដីសាសនាចក្រ នៅលើគេហទំព័រសាសនាចក្រ និងកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម ព្រមទាំងអាចមាននៅក្នុងរបាយការណ៍របស់សាសនាចក្រ ផលិតផលបោះពុម្ព វីដេអូ ការបោះពុម្ពផ្សាយ និងសម្ភារបំពាក់បំប៉ននានា » ។ ពួកយើងទន្ទឹងរង់ចាំឮពីបងប្អូន !



សូមស្វែងរករូបលីអាហូណាដែលលាក់នៅខាងក្នុង !

## មាតិកា


ខ២ មកពីគណៈប្រធានទីមួយ ៖ ទីបន្ទាល់ និងព្រះគម្ពីរមរមន
ខ៤ ការអធិស្ឋានរបស់ខេលលី
ខ៦ សួស្ដីមកពីប្រទេសអាល្លឺម៉ង់ !
ខ៨ ហែលដូចជាសេះសមុទ្រ
ខ១០ គ្រឿងសប្បាយ ៖ បញ្ចប់លំនាំ
ខ១១ កម្មវិធីបង្ហាញ ហើយនិទានប្រាប់
ខ១២ តើខ្ញុំជានរណា?
ខ១៤ មិត្តទៅកាន់មិត្ត ៖ មិនមាននរណាម្នាក់ត្រូវទុកចោលឡើយ
ខ១៥ តើខ្ញុំជានរណា ?—រើសយកកាតមួយ
ខ១៦ ដៃជំនួយរបស់អេលី
ខ១៨ គំនិតឆ្លាតវៃ
ខ១៩ គោលដៅធ្វើម្ហូបរបស់ខ្ញុំ
ខ២០ រឿងក្នុងព្រះគម្ពីរ ៖ អ័ប៊ីសបានចែកចាយដំណឹងល្អ
ខ២៣ ទំព័រផាត់ពណ៌ ៖ អ័ប៊ីសមានជំនឿលើព្រះ


នៅលើក្របទស្សនាវដ្ដី *ប្រិយមិត្ត*
រចនារូបភាពដោយ ឌីលីន ម៉ាស្ស


© ២០២៦ BY INTELLECTUAL RESERVE, INC. ALL RIGHTS RESERVED.


CAMBODIAN

4 02167 21258 4